ក

# មាតិកា

## I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៣-៦-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦៥៣ ស្តីពី ការកាត់ផ្ទៃដី ទំហំ ២..៦៩៨ ហិកតា ចេញពីដែនជម្រកសត្វព្រៃរនាមដូនសំ ដែលកំណត់ដោយព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៣/២៩១ ចុះថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ ២០០៣ ៦៣១៦

១៣-៦-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦៦១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ និងសប្បុរសជន ចំនួន ៦២ រូប ៦៣១៧

១៣-៦-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦៦២ ស្តីពី ការតែងតាំងឯកឧត្តម ឈួរ លាងហួត ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នីតិកាលទី ៣ មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ៦៣១៩

១៣-៦-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦៦៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ ឧកញ៉ា ម៉ៅ ចំណាន ៦៣២០

១៧-៦-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦៦៤ ស្តីពី ការកាត់ផ្ទៃដី ទំហំ ៦៨,០៨២៨ ហិកតា ចេញពីដីឧទ្យានជាតិព្រះមុនីវង្ស នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ១ លេខរៀងទី ២ ៦៣២១

១៧-៦-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦៦៥ ស្តីពី ការកាត់ផ្ទៃដី ទំហំ ១២០,៩០៦៧ ហិកតា ចេញពីដីឧទ្យានជាតិព្រះមុនីវង្ស នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ១ លេខរៀងទី ២ ៦៣២២

១៧-៦-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦៦៦ ស្តីពី ការកាត់ផ្ទៃដី ទំហំ ១៦០,៦៩១៩ ហិកតា ចេញពីដីឧទ្យានជាតិព្រះមុនីវង្ស នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ១ លេខរៀងទី ២ ៦៣២៣

១៧-៦-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦៦៧ ស្តីពី ការកាត់ផ្ទៃដី ទំហំ ៥៥៥,៥១ ហិកតា ចេញពីដីឧទ្យានជាតិបូទុមសាគរ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ១ លេខរៀងទី ៥ ៦៣២៤

១៧-៦-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦៦៨ ស្តីពី ការកាត់ផ្ទៃដី ទំហំ ៥២៧ ហិកតា ចេញពីដីឧទ្យានជាតិបូទុមសាគរ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ១ លេខរៀងទី ៥ ៦៣២៥

១៧-៦-២០១៣ ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦៦៩ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហ្វុង យ៉ឿន តាត់ វិចទ័រ** (FONG YUEN TAK VICTOR) ជនជាតិចិន សញ្ជាតិចិន កើតនៅទីក្រុងសៀងហៃ សាធារណរដ្ឋប្រជាមានិតចិន ៦៣២៦

១៧-៦-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦៧០ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ សប្បុរសជន ចំនួន ០៤ រូប ៦៣២៧

១៩-៦-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦៧១ ស្ដីពី ការតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ឯក ជូនឧត្តមសេនីយ៍ទោ **ហ៊ុន ម៉ាណែត** នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ៦៣២៨

១៩-៦-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦៧២ ស្ដីពី ការកាត់ផ្ទៃដី ទំហំ ២.០០០,៣០ ហិកតា ចេញពីដីជម្រកសត្វព្រៃបឹងពែរ ដែលកំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ១៣ ៦៣២៩

១៩-៦-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦៧៣ ស្ដីពី ការតម្លើងឋានន្តរស័ក្តិ ដល់នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៨ រូប ៦៣៣០

១៩-៦-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦៧៤ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ ឯកឧត្តម **អ៊ាង សុផល្លែត** ៦៣៣១

១៩-៦-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦៧៥ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ប្រគេន ចំពោះ ព្រះញាណវង្ស **ឃឹម សន** ៦៣៣២

១៩-៦-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦៧៦ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ព្រះសង្ឃ និងសប្បុរសជន ចំនួន ៦៨ អង្គ/រូប ៦៣៣៣

១៩-៦-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦៧៧ ស្ដីពី ការផ្ទេរមុខងារ និងតម្លើងឋានៈជូនឯកឧត្តម **ធន វិមានច័ន្ទ** ពីជំនួយការ មកជាទីប្រឹក្សាសម្ដេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី ៣ មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៦៣៣៥

១៩-៦-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦៧៨ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ ឯកឧត្តម **ហាត់ សុខណ្ណា** ៦៣៣៦

១៩-៦-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦៧៩ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ ឧកញ៉ា **គិត ហ្វុងយី** ៦៣៣៧

១៩-៦-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦៨០ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ ឧកញ៉ា **ស៊ាង លីម** ៦៣៣៨

# II-រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

០៦-៦-២០១៣ -អនុក្រឹត្យលេខ ៣២៦ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ៣៦៦,៥៨ ហិកតា នៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ក្នុងនោះចេញពី (១) ដីគម្របព្រៃឈើឆ្នាំ ២០០២ (២) ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន Fortuna Plantation Cambodia Limited និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៤២ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៦៣៣៩

០៦-៦-២០១៣ -អនុក្រឹត្យលេខ ៣២៧ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៦១១,៤៦ ហិកតា នៅឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកសម្រាប់ធ្វើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការផ្តល់សិទ្ធិលើក្បាលដី ៦៣៤២

០៦-៦-២០១៣ -អនុក្រឹត្យលេខ ៣២៨ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៥២៣,៥១៨៨ ហិកតា នៅស្រុកទឹកឈូ ខេត្តកំពត ចេញពីដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើស្ទឹងកែវ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២១២ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៦៣៤៥

០៦-៦-២០១៣ -អនុក្រឹត្យលេខ ៣២៩ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៤៨៩,២៧៩៤ ហិកតា នៅស្រុកទឹកឈូ ខេត្តកំពត ចេញពីដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើស្ទឹងកែវ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤០៧ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៦៣៤៨

០៦-៦-២០១៣ -អនុក្រឹត្យលេខ ៣៣០ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ២០៧,៧៧៩៦ ហិកតា នៅស្រុកទឹកឈូ ខេត្តកំពត ចេញពីដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើស្ទឹងកែវ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៥ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៦៣៥១

០៦-៦-២០១៣ -អនុក្រឹត្យលេខ ៣៣១ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ១.៣០៦,២៥ ហិកតា នៅស្រុករវៀង ខេត្តព្រះវិហារ ក្នុងនោះកាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ ក្រុមហ៊ុន ហ្គ្រីន ឈ័យ (ខេមបូឌា) ខូ លីមីធីត សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ៤៧៩ គ្រួសារ និងរក្សាទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ៦៣៥៤

០៦-៦-២០១៣ -អនុក្រឹត្យលេខ ៣៣២ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ១២៥,៧៦ ហិកតា នៅ ស្រុកជ័យសែន ខេត្តព្រះវិហារ ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១០២ គ្រួសារ ៦៣៥៧

០៦-៦-២០១៣ -អនុក្រឹត្យលេខ ៣៣៣ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ១៨០,៦៩ ហិកតា នៅ ស្រុកជ័យសែន ខេត្តព្រះវិហារ ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៤៤ គ្រួសារ ៦៣៦០

១៧-៤-២០១៣ -អនុក្រឹត្យលេខ **៤៤៧ ដល់ លេខ ៤៦២ អនក្រ.តត** ស្តីពី ការតែងតាំងមន្ត្រីរាជការ ៦៣៦៣

## ២_សេចក្តីសម្រេច

២៨-៦-២០១៣ -សេចក្តីសម្រេចលេខ ២៦ សសរ ស្តីពី ការតែងតាំងសមាសភាពក្រុមប្រឹក្សាសកម្មភាព ជនពិការ ៦៣៩៥

## ៣_សេចក្តីណែនាំ

២១-៦-២០១៣ -សេចក្តីណែនាំលេខ ០៣ សណន របស់គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ ៦៣៩៨

## ៤_គោលការណ៍ណែនាំ

០៥-៧-២០១៣ -គោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលលេខ ០១ គកន ស្តីពី ការគ្រប់គ្រងកម្លាំងពលកម្ម និងលំហូរពលករទេសន្តរប្រវេសន៍កម្ពុជា ៦៤០១

## III_ការងារបណ្តាក្រសួង

## ១_ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៣-៦-២០១៣ -ប្រកាសណែនាំលេខ ៥៨៣ សហវ.ហម ស្តីពី ការរៀបចំ អនុម័ត និងអនុវត្តថវិកា ក្រុង ស្រុក ៦៤០៦

១៣-៦-២០១៣ -សារាចរណែនាំលេខ ០០២ សហវ.ហម ស្តីពី ការអនុវត្តនីតិវិធីប្រព័ន្ធទូទាត់ និងប្រព័ន្ធ គណនេយ្យរបស់រដ្ឋបាលក្រុង ស្រុក ៦៤២៤

## ២_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១២-៦-២០១៣ -ប្រកាសលេខ ៤៨៦ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ូ អ៊ីភើរីល (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៦៤៤០

១២-៦-២០១៣ -ប្រកាសលេខ ៤៨៧ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ណានុកស៊ី (ខេមបូឌា) អ៊ិន បង្កើតរោងចក្រ ផលិតស្បែកជើង, ថង់ផ្លាស្ទិក ៦៤៤៤

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៦៥៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៣/២៩១ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៣
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** កាត់ផ្ទៃដីទំហំ ២.៦៩៨ ហិកតា ចេញពីដែនជំរកសត្វព្រៃនាមជុនសំ ដែលកំណត់ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៩០៣/២៩១ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៣ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរល.១៣០៦.៦៦៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣

លេខ: ៧៣៩ ស.ណ
**សំណៅដែលមាន[illegible]ការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៣
**អគ្គលេខាធិការ[illegible]ទីស្តីការគណៈរដ្ឋាភិបាល**
**[illegible] សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៦៦១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការ និងសប្បុរសជន ចំនួន ៦២រូប ដែលមានស្នាដៃល្អ
និងគុណបំណាច់យ៉ាងធំធេង ក្នុងការបម្រើជាតិ មាតុភូមិ

នូវ

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- ព្រឹទ្ធាចារ្យ ឡឿង សេដ្ឋា
២- លោកជំទាវ ថែម សារ៉ៃ
៣- លោកជំទាវ អ៊ុយ ដារ៉ា
៤- លោក អ៊ុំភឿង គុណវឌ្ឍ
៥- លោក ខួយ វីដា
៦- លោក លឹម សៀងហេង
៧- លោក យូ ហេង
៨- លោក លី ប៊ុនសុង

ខ- គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- ឯកឧត្តម ចាន់ ធឿន
២- ឯកឧត្តម ហ៊ុយ ហានសុង
៣- ឯកឧត្តម ម៉ុង ដាវន
៤- ឯកឧត្តម អ៊ុយ សំអាត
៥- លោកជំទាវ សុខ កែវ ច័ន្ទ សារុន
៦- ឧកញ៉ា លឹម ហាវទី
៧- ឧកញ៉ា អ៊ឹង គុងហៃ
៨- ឯកឧត្តម ទូន ភក្តី
៩- លោក សុខ សុហេម៉ា
១០- លោកស្រី នាង ជួនអេង
១១- លោក ភួង ម៉ាល័យ

គ- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- លោក សំ វណ្ណា
២- វរសេនីយ៍ទោ សេង វ៉ាន់ធូ អត្ត. ០១១៧៨
៣- លោក សិរិទ្ធ សុខហួន

ឃ- គ្រឿងឥស្សរិយយស សេនាជ័យសិទ្ធ :

១- វរសេនីយ៍ទោ ខាន់ លីណា , អត្ត.៥៤២៥៧
២- វរសេនីយ៍ទោ កែវ សុចិន្តា អត្ត.១១២៩៤០
៣- វរសេនីយ៍ទោ សំ ស៊ីវីនណា អត្ត.០២៤៥២៩
៤- វរសេនីយ៍ទោ ឡុត ប៊ុនធឿន អត្ត.០៤៤៥៦២

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ង- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១- លោកស្រី ជាម អេង
២- លោក សួង សុខបាន
៣- លោក សួង សេងហួត
៤- លោក សួង សីហា
៥- លោកស្រី ជាង សុខនាង
៦- លោកស្រី យ៉ាង ស្រីល័ក្ខ
៧- លោក ឌិ ចាន់ធូ
៨- លោក សាត់ សុខុន
៩- លោក ស៊ិន ស៊ីមលី
១០- លោក ឈឹន រតនា
១១- លោក សឹម យ៉ារីន
១២- លោក សោម ទីន
១៣- លោក ឡាត់ គីមសាន
១៤- វរសេនីយ៍ទោ អ៊ុំ ឆានរិទ្ធិ អត្ត.០៥២៩៨
១៥- លោក ហ៊ី ឱណារត្ន
១៦- លោក ឈិច ថេង
១៧- លោក ឌួង ទ្រី
១៨- លោក ប៉ែន ច័ន្ទសេង
១៩- លោក ខ្លួត ណារ៉ា
២០- លោក ទុច សុផល
២១- លោក ចាន់ ម៉ៅ
២២- អនុសេនីយ៍ទោ ផន ថន អត្ត.២១៩៤០

ច- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

១- ព្រះតេជគុណ ទេព ផាន
២- លោក សោម ឆាត
៣- លោក ព្រាប ឬរី
៤- លោក សោម សុខុន
៥- លោក មឿន ឃឿន
៦- លោក ញ៉ិត តេន
៧- លោក ព្រុំ នីល
៨- លោក ជា រ៉ាឌី
៩- លោក នេត ណាត
១០- លោក សំ ទីរៈ
១១- លោក ពាន ចសនា
១២- លោក ឆួង សំណាង
១៣- លោក តៅ យុត
១៤- លោក ម៉ត់ ហ៊ាន់

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត. ១៣០៦. ៦៣៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣

លេខៈ ៦១៧/ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ មិថុនា ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្ដីការរាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៥៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកដំបូង នីតិកាលទី៣ នៃព្រឹទ្ធសភា នាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តម **ឈួរ លាងហួត** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី៣ មានឋានៈស្មើ **ទេសរដ្ឋមន្ត្រី** ។

**មាត្រា២ :** សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចនល.១៣០៦.៥៧៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០១៣

លេខ: ៦៥៥ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៦៦៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

ឧកញ៉ា ម៉ៅ ចំណាន

ដែលមានស្នាដៃល្អ និងគុណបំណាច់ធំៗជាច្រើន
ក្នុងការចូលរួមចំណែកកសាងអភិវឌ្ឍន៍ប្រទេសជាតិ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចារ.ល. ១៣០៦.៦៧៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣

លេខៈ ៧៥៦ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

ស៊យ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៦៦៤

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** កាត់ផ្ទៃដីទំហំ ៦៨,០៨២៨ ហិកតា ចេញពីដីឧទ្យានជាតិព្រះមុនីវង្ស នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ១ លេខរៀងទី ២ ។

**មាត្រា ២:** សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ដលេខាតទៅ ។

**ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ**
**នរោត្ដម សីហមុនី**

៣៩៧-១៣០៦-៦៦៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣

លេខៈ ៦៥៨ ស.ណ
**សំណៅ[illegible]ជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ២០១៣
**អគ្គលេ[illegible]ទីស្ដីការរាជរដ្ឋាភិបាល**

**[illegible] សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៦៦៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** កាត់ផ្ទៃដីទំហំ ១២០,៩០៦៧ ហិកតា ចេញពីដីឧទ្យានជាតិព្រះមុនីវង្ស នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ១ លេខរៀងទី ២ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

[illegible] **នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣

លេខៈ ៦៥៩ ស.ណ
**សំណៅដែលមានកម្មវត្ថុជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៦៦៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**: កាត់ផ្ទៃដីទំហំ ១៦០,៦៩១៩ ហិកតា ចេញពីដីឧទ្យានជាតិព្រះមុនីវង្ស នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ១ លេខរៀងទី ២ ។

**មាត្រា ២**: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣**: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣៤៧. ១៣០៦. ៦៧៧

**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣

លេខ: ៦៦០ ស.ណ
**សំណៅដែលមានតម្កល់ជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការ[illegible]រាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៦៦៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** កាត់ផ្ទៃដីទំហំ ៥៥៥,៥១ ហិកតា ចេញពីដីឧទ្យានជាតិ បូទុមសាគរ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ១ លេខរៀងទី ៥ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

៣៩៧.១៣០៦.៦៧៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣

លេខ: ៦៦១ ស.ណ
**សំណៅដែលមានវិញ្ញាបនការចេញឲ្យ**
**រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣**
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៦៤៨

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** កាត់ផ្ទៃដីទំហំ ៥២៧ ហិកតា ចេញពីដីឧទ្យានជាតិ បូទុមសាគរ នៃព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ១ លេខរៀងទី ៥ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៧.១៣០៦.៦៧៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣

លេខ [illegible] ស.ណ
**សំណៅចម្លងចេញពីច្បាប់ដើម សម្រាប់ការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៦៦៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហ្វុង យៀន តាក់ វិចទ័រ** (FONG YUEN TAK VICTOR) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៤៦ នៅទីក្រុងសៀងហៃ សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៧.១៣០៦.៦៨០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៣

លេខៈ ៧៥៧ ស.ណ
**សំណៅដែលមានសេចក្តីថាការចែកផ្សាយ**
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែមិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល**
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៦៧០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ដែលបានលះបង់កំលាំងកាយ ចិត្ត ប្រាជ្ញា ពេលវេលា និងធនធានយ៉ាងច្រើន
ដើម្បីបម្រើសកម្មភាពមនុស្សធម៌ របស់កាកបាទក្រហមកម្ពុជា

នូវ

គ្រឿងឥស្សរិយយស **ជាតូបការ**

១- លោកជំទាវ ម៉ុត ប៉ូប៉ុននិរិទ្ធិ

២- លោកជំទាវ មាស សុភា

៣- លោកជំទាវ គួ គីមឡុង

៤- ឧកញ៉ា សោម សុផល

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ការ.ល ១៣០៦-៦៨១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣

លេខៈ ៦៥៣ ស.ណ
**សំណៅដែលមាន[illegible]ជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣
**[illegible]រាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៦៧១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្ននខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ដំឡើងឋានន្តរសក្តិ ថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូន ឧត្តមសេនីយ៍ទោ **ហ៊ុន ម៉ាណែត** អត្តលេខ ០៣៣៨៨៣ នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចានល.១៣០៦.៦៥២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០១៣

លេខ: ៦៦៤ ស.ណ
**សំណៅចម្លងចេញពីច្បាប់ដើម ដើម្បីជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី**
**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៦៧៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្នត្រ័យ ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-** កាត់ផ្ទៃដីទំហំ ២.០០០,៣០ ហិកតា ចេញពីដីជម្រកសត្វព្រៃបឹងពែរ ដែលកំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ១៣ ។

**មាត្រា ២.-** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣១៧ល. ១៣០៦.៦៤៣

លេខៈ ៦៧៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ខែមិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**
**ស៊ុយ សុខា**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៦៧៣

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្ដីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ដំឡើងឋានន្តរសក្តិ ដល់ នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ៖

**ក-ដំឡើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ទោ :**

| | | | |
|---|---|---|---|
| ១-ឧត្តមសេនីយ៍ត្រី | **សុខ** | **ខន** | អត្តលេខ ០០៤៨៣៩ |
| ២-ឧត្តមសេនីយ៍ត្រី | **ឡាច** | **វ៉ាន់** | អត្តលេខ ០០៣៣៨៥ |
| ៣-ឧត្តមសេនីយ៍ត្រី | **ហួត** | **ឈាងអន** | អត្តលេខ ០២០០៥៩ |

**ខ-ដំឡើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ត្រី :**

| | | | |
|---|---|---|---|
| ១-វរសេនីយ៍ឯក | **កោះ** | **សុវណ្ណ** | អត្តលេខ ០២០៨៧៤ |
| ២-វរសេនីយ៍ឯក | **ប៉ាល់** | **សាន្ត** | អត្តលេខ ០០៤៨៧៩ |
| ៣-វរសេនីយ៍ឯក | **ស៊ូ** | **ស៊ីផាន** | អត្តលេខ ០០២៣៣៣ |
| ៤-វរសេនីយ៍ឯក | **ជា** | **សុខស៊ីម** | អត្តលេខ ០០២៣៨៤ |
| ៥-វរសេនីយ៍ឯក | **រិទ្ធ** | **សុវណ្ណារ៉េត** | អត្តលេខ ០០៣៣៨០ |

**មាត្រា២ :** សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០១៣

លេខៈ [illegible] ស.ណ
[illegible] ការចែកផ្សាយ
រាជធានី [illegible] ខែមិថុនា ឆ្នាំ២០១៣
អគ្គលេខា [illegible] ទី១រាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៦៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រត្នត្តយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

ឯកឧត្តម អ៊ាង សុផល្លែត

ដែលបានចំណាយធនធានផ្ទាល់ខ្លួន និងខិតខំស្វែងរកជំនួយ

ចូលរួមសាងសង់សាលារៀន នៅអនុវិទ្យាល័យគ្រួស ឃុំរលាប្អៀរ ស្រុករលាប្អៀរ និងនៅសាលាបឋមសិក្សាពន្លៃ

ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំងកន្លងមក

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៦៤.១៣០៦.៦៤៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣

លេខៈ ៦៦៣ ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣

អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៦៩៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ប្រគេនចំពោះ

ព្រះញាណវង្ស ឃឹម សន

ព្រះមេគណរាជធានីភ្នំពេញ ដែលព្រះអង្គមានគុណបំណាច់ និងស្នាព្រះហស្ថជាច្រើន
ក្នុងការអភិវឌ្ឍវិស័យព្រះពុទ្ធសាសនា និងសង្គមជាតិកន្លងមក

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល. ១៣០៦.៦៥៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣*

លេខៈ ៦៦៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**
**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៦៧៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ព្រះសង្ឃ និងសប្បុរសជន ចំនួន ៦៨ អង្គ/រូប មានគុណបំណាច់ខ្ពស់ ដោយបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធានផ្ទាល់ខ្លួន ចូលរួមក្នុងការកែលម្អរមណីយដ្ឋានធម្មជាតិ និងសាងសង់ ផ្សារ វត្តកៀនស្វាយក្រៅ និងផ្លូវបេតុង ស្ថិតនៅក្នុងភូមិធំ ឃុំភូមិធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល សម្រេចបានលទ្ធផលល្អប្រសើរ

នូវ

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍**

| | | | | | |
|---|---|---|---|---|---|
| ១- | ព្រះវិសុទ្ធវង្សា | ខឹម សុផន | ៥- | ឯកឧត្តម | សុខ សុភ័ក្ត្រ |
| ២- | ព្រះគ្រូឃោសាចារ្យ | ពៅ រតនា | ៦- | លោក | ស៊ុំ ណារុន |
| ៣- | លោកជំទាវ | ក្រូច រ៉ា | ៧- | លោក | ឡឹក ម៉ុក |
| ៤- | កញ្ញា | ម៉ក់ បូលី | ៨- | លោក | ព្រហ្ម ដូលីន |

**ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍**

| | | | | | |
|---|---|---|---|---|---|
| ១- | លោក | ម៉ក់ ពេជ្ររុន | ៥- | លោក | ឃ្លោក ជួន |
| ២- | លោក | ស៊ូ សុខុម | ៦- | លោក | ហេង សាយ |
| ៣- | លោក | ហេង ស៊ីថា | ៧- | លោក | លាង បូរ៉ា |
| ៤- | លោក | ង៉ែត ចេក | ៨- | លោក | អ៊ុំ ម៉ារិទ្ធ |

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**

| | | | | | |
|---|---|---|---|---|---|
| ១- | លោក | អ៊ុត សុភាព | ៨- | កញ្ញា | សេក ស្រីម៉ៅ |
| ២- | លោក | ខាន់ រ៉ាត់ | ៩- | លោកស្រី | ហួត ស៊ីណា |
| ៣- | លោក | លី ឡាធី | ១០- | លោក | ស៊ាន ស៊ីណាត |
| ៤- | លោក | លឿង សុភា | ១១- | លោក | ហាក់ សុខរិន |
| ៥- | លោក | សៀង ពុទ្ធា | ១២- | លោក | ម៉េង ថានី |
| ៦- | លោក | ហេង ណន | ១៣- | លោក | ចាន់ រិទ្ធី |
| ៧- | លោក | ណាល់ វិចិត្រ | ១៤- | លោក | ជា ប៊ុនធឿន |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

ឃ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

| | | | | | |
|---|---|---|---|---|---|
| ១- | ឯកឧត្តម | ចេន ចាន់តុង | ៩- | លោក | ប៉ា សំរិត |
| ២- | លោក | ហោ នាយ | ១០- | លោកស្រី | ណែត ពេជ្រលក្ខិណា |
| ៣- | លោក | ម៉ាង ស៊ីណេត | ១១- | លោក | ឈឹម ខាសនា |
| ៤- | លោក | ឡាយ សុខសៅគន្ធា | ១២- | លោក | ប៊ុន សាម៉េត |
| ៥- | លោក | ខួន សុមុល្លីចន្ទ | ១៣- | លោក | នី ស៊ីធុត្តា |
| ៦- | លោក | ង៉ោ លាងគង់ | ១៤- | លោក | ប៊ុន សុភ័ក្ត្ររិទ្ធ |
| ៧- | លោក | ឡេង សំនិត | ១៥- | លោក | ហេង មាលី |
| ៨- | លោក | លេង ទុទ្ធី | ១៦- | លោក | គិន រាជ |

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

| | | | | | |
|---|---|---|---|---|---|
| ១- | លោក | កែប ច័ន្ទសូនី | ៩- | លោកស្រី | សាត វ័ត្តមុនី |
| ២- | លោក | ស្រួយ សុបញ្ញា | ១០- | លោកស្រី | យស សុខា |
| ៣- | លោក | ហុង លីមហ៊ុន | ១១- | លោក | សេង ធូក |
| ៤- | លោក | ឃីច ចាន់សុខុម | ១២- | លោក | កើត ស៊ីណាត |
| ៥- | លោក | ឈុន ណា | ១៣- | លោក | ខូយ ចណ្ណារ៉ា |
| ៦- | លោក | ស៊ិន សុផន | ១៤- | លោក | ជា ប៊ុណ្ណារ៉ា |
| ៧- | លោក | ង៉ែត ត្រីស្នា | ១៥- | លោក | ជាន ឡេង |
| ៨- | លោក | គុយ ញ៉ី | ១៦- | លោក | ឌិត្យ ច័ន្ទមុនី |

ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

| | | | | | |
|---|---|---|---|---|---|
| ១- | លោក | សោម សាម៉ុល | ៤- | លោក | ច័ន្ទ សាទ៊ុន |
| ២- | លោកស្រី | គ្រុះ ចាន់លន់ | ៥- | លោក | ថៃ សុផល |
| ៣- | លោក | ប៊ិច អាយ | ៦- | លោក | គីម សូជា |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស.រ.ក.ត ១៣០៦.៥៤៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣

លេខៈ ៦៦៥ ស.ណ

**សំណៅចម្លងមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១៣

**អគ្គលេខាធិការរងទីស្ដីការគណៈរដ្ឋមន្ត្រី**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៦៧៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកដំបូង នីតិកាលទី៣ នៃព្រឹទ្ធសភា នាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្ទេរមុខងារ និងដំឡើងឋានៈជូនឯកឧត្តម **ធន វិមានច័ន្ទ** ពីជំនួយការ មកជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី ៣ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២ :** សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរណ. ១៣០៦.៦៥៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១៣

លេខ ៧០៦ ស.ណ
**សំណៅ[illegible]ការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែមិថុនា ឆ្នាំ២០១៣
**[illegible]រាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៦៧៨

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា**
**សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាគួបគារ

ចំពោះ

ឯកឧត្តម **ហាត់ សុខណ្ណា**

ដែលមានស្នាដៃល្អ និងមានគុណបំណាច់យ៉ាងធំធេង
ក្នុងការចូលរួមចំណែកកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៧. ១៣០៦. ៦៤៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣

លេខ [illegible]០៥ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមិថុនា ឆ្នាំ២០១៣
[illegible]រាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៦៧៩

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

ឧកញ៉ា គិត ហុងយី

ដែលមានស្នាដៃល្អ និងមានគុណបំណាច់យ៉ាងធំធេង
ក្នុងការចូលរួមចំណែកកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

តានស.១៣០៦.៦៩០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១៣

លេខ [illegible] ស.ណ
សំណៅ[illegible]ការចែកផ្សាយ
រាជធានី[illegible] ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៣
អគ្គលេខា[illegible]រដ្ឋាភិបាល
[illegible] សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៦៤០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា**
**សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

ឧកញ៉ា ស៊ាង លីម

ដែលមានស្នាដៃល្អ និងមានគុណបំណាច់យ៉ាងធំធេង

ក្នុងការចូលរួមចំណែកកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចានល.១៣០៦.៦៩១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៣

លេខ: ៧០៣ ស.ណ
**សំណៅដែលមានត្រឹមត្រូវជាការចែកផ្សាយ**
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧៦៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ៣៦៦,៥៨ ហិកតា នៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ក្នុងនោះ កាត់ចេញពី (១) ដីគម្របព្រៃឈើឆ្នាំ ២០០២ (២) ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន Fortuna Plantation Cambodia Limited និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៤២ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នស ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ



8

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៨៨អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៣៧៤អបខ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីសរុបទំហំ ៣៦៦,៥៨ ហិកតា ក្នុងនោះ (១) ទំហំ ៣៦,៣៤ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និង (២) ទំហំ ៣៣០,២៤ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន Fortuna Plantation Cambodia Limited និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មដីទំហំ ៣៤៧,៥២ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ១៩,០៦ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិព្រៃទទឹង ឃុំហោងសំណំ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី ១ ទី ២ និងទី ៣ នៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១៩២ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិព្រៃទទឹង ឃុំហោងសំណំ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែងនិងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៧២៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី

## ការកាត់ដីទំហំ ៦១១,៤៦ ហិកតា នៅឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ ចេញពីដី គម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកសម្រាប់ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការផ្តល់សិទ្ធិលើក្បាលដី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នស ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ២៣០ ស.ណ.ក.ធ ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីទំហំ ៦១១,៤៦ ហិកតា ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ ៦០០,៤០ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១១,០៦ ហិកតា រក្សាទុកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិបង្គីតាំងផន ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិបង្គីតាំងផន ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ ។

**មាត្រា ៣.-**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ២០៣ ក្បាលដី ជូនប្រជាពលរដ្ឋ ១៣៥ គ្រួសារ ។

**មាត្រា ៤.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦.-**

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុងនិងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច

**មាត្រា ១.-**

តែងតាំងមន្ត្រីរាជការចំនួន ០៥រូប ជាអភិបាលរង នៃគណៈអភិបាលខេត្តកំពត សម្រាប់អាណត្តិទី២ នៅក្នុងដែនសមត្ថកិច្ចដដែល ដូចមានរាយនាមខាងក្រោម :

១- លោក **សុត យា** ជា អភិបាលរង

២- លោក **អ៊ុំ ម៉េងហួរ** ជា អភិបាលរង

៣- លោកស្រី **កង សៅរ៉េន** ជា អភិបាលរង

៤- លោក **ហេង ចន្ថា** ជា អភិបាលរង

៥- លោក **ជួង ស៊ីចន្ទន្ត** ជា អភិបាលរង ។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៥៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច

**មាត្រា ១.-**

តែងតាំងមន្ត្រីរាជការចំនួន ០៦រូប ជាអភិបាលខណ្ឌ នៃរាជធានីភ្នំពេញ សម្រាប់អាណត្តិទី២ នៅក្នុងដែនសមត្ថកិច្ចដដែល ដូចមានរាយនាមខាងក្រោម :

១- លោក **សោម សុខណ្ណ** អភិបាលខណ្ឌ៧មករា

២- លោក **គិត សុផា** អភិបាលខណ្ឌពោធិ៍សែនជ័យ

៣- លោក **គួច ចំរើន** អភិបាលខណ្ឌមានជ័យ

៤- លោក **ឃ្លាំង ហួត** អភិបាលខណ្ឌឫស្សីកែវ

៥- លោក **សុខ សម្បត្តិ** អភិបាលខណ្ឌដូនពេញ

៦- លោក **ឡូ យុយ** អភិបាលខណ្ឌចំការមន ។

**មាត្រា ២.-**

ត្រូវបានតែងតាំងលោក **ឯក យុនឿន** ជាអភិបាលខណ្ឌទួលគោក នៃរាជធានីភ្នំពេញ ។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងមាត្រា១ និងមាត្រា២ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៥៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុងនិងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច

**មាត្រា ១.-**

តែងតាំងមន្ត្រីរាជការចំនួន **០៥រូប** ជាអភិបាលក្រុង ស្រុក នៃខេត្តកំពង់ឆ្នាំង សម្រាប់អាណត្តិទី២ នៅក្នុងដែនសមត្ថកិច្ចដែល ដូចមានរាយនាមខាងក្រោម :

១- លោក **ហៃ មនោរម្យ** អភិបាលក្រុងកំពង់ឆ្នាំង

២- លោក **មាន់ អ៊ានលី** អភិបាលស្រុកកំពង់លែង

៣- លោក **ហ៊ុល ចំន្ធថូ** អភិបាលស្រុកកំពង់ត្រឡាច

៤- លោក **យិន សាទ័ន** អភិបាលស្រុកជលគីរី

៥- លោក **ឈឹម ធុន្ធា** អភិបាលស្រុករលាប្អៀរ ។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: [illegible] អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុងនិងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច

**មាត្រា ១.-**

តែងតាំងមន្ត្រីរាជការចំនួន **០៥រូប** ជាអភិបាលស្រុក នៃខេត្តកោះកុង សម្រាប់អាណត្តិទី២ នៅក្នុងដែនសមត្ថកិច្ចដដែល ដូចមានរាយនាមខាងក្រោម :

១- លោក **ស៊ុន គឿន** អភិបាលស្រុកមណ្ឌលសីមា

២- លោក **អន តារះ** អភិបាលស្រុកបូទុមសាគរ

៣- លោក **ឌួន សីលា** អភិបាលស្រុកស្រែអំបិល

៤- លោក **សោម សុធីរ** អភិបាលស្រុកកោះកុង

៥- លោក **ឌូ សាឌុឧ** អភិបាលស្រុកថ្មបាំង ។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ [illegible] ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៤៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុងនិងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច

**មាត្រា ១.-**

តែងតាំងមន្ត្រីរាជការចំនួន ១១រូប ជាអភិបាលក្រុង ស្រុក នៃខេត្តសៀមរាប សម្រាប់អាណត្តិទី២ នៅក្នុងដែនសមត្ថកិច្ចដែល ដូចមានរាយនាមខាងក្រោម ៖

| | |
|---|---|
| ១- លោក **ទេព ប៊ុនឆាយ** | អភិបាលក្រុងសៀមរាប |
| ២- លោក **នាក់ ណេរ៉ុន** | អភិបាលស្រុកវ៉ារិន |
| ៣- លោក **គូ សំអាត** | អភិបាលស្រុកប្រាសាទបាគង |
| ៤- លោក **អ៊ាន ឃុន** | អភិបាលស្រុកក្រឡាញ់ |
| ៥- លោក **វ៉ែន ជុំ** | អភិបាលស្រុកអង្គរជុំ |
| ៦- លោក **ឆោត សេរីរត្នមុនី** | អភិបាលស្រុកជីក្រែង |
| ៧- លោក **ម៉ុខ ឌុធី** | អភិបាលស្រុកបន្ទាយស្រី |
| ៨- លោក **ឡៀន ខាន** | អភិបាលស្រុកអង្គរធំ |
| ៩- លោក **ខិត ជន** | អភិបាលស្រុកសូទ្រនិគម |
| ១០- លោក **ម៉ក់ សំភារ** | អភិបាលស្រុកស្រីស្នំ |
| ១១- លោក **ពេជ្រ សុខាល័យ** | អភិបាលស្រុកពួក ។ |

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ [illegible] ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> ៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៤៥៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុងនិងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច

**មាត្រា ១.-**

តែងតាំងមន្ត្រីរាជការចំនួន **០៩រូប** ជាអភិបាលក្រុង ស្រុក នៃខេត្តតាកែវ សម្រាប់អាណត្តិទី២នៅក្នុងដែនសមត្ថកិច្ចដដែល ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១- លោក | **អ៊ូច តា** | អភិបាលក្រុងដូនកែវ |
| ២- លោក | **តឹក គុនលីម** | អភិបាលស្រុកគីរីវង់ |
| ៣- លោកស្រី | **តា សុគុ** | អភិបាលស្រុកត្រាំកក់ |
| ៤- លោក | **ស៊ុត ខុន** | អភិបាលស្រុកបូរីជលសារ |
| ៥- លោក | **កេត ម៉ៅ** | អភិបាលស្រុកទ្រាំង |
| ៦- លោក | **នាង ស៊ន** | អភិបាលស្រុកកោះអណ្តែត |
| ៧- លោក | **អ៊ិត សារ** | អភិបាលស្រុកព្រៃកប្បាស |
| ៨- លោក | **ឡាយ សុខា** | អភិបាលស្រុកបាទី |
| ៩- លោក | **ញៀម ស្រស់** | អភិបាលស្រុកសំរោង ។ |

**មាត្រា ២.-**

ក្នុងរយៈពេលមកបំពេញភារកិច្ចក្នុងមុខតំណែងខាងលើនេះ លោក **ញៀម ស្រស់** ត្រូវដាក់ពាក្យស្នើសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ [illegible] ឆ្នាំ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

__កន្លែងទទួល__ :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៦០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុងនិងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច

**មាត្រា ១.-**

តែងតាំងមន្ត្រីរាជការចំនួន **០៦រូប** ជាអភិបាលក្រុង ស្រុក នៃខេត្តកំពង់ស្ពឺ សម្រាប់អាណត្តិទី២នៅក្នុងដែនសមត្ថកិច្ចដែល ដូចមានរាយនាមខាងក្រោម :

១- លោក **ហ៊ុយ ស៊ីធឿន** អភិបាលក្រុងច្បារមន

២- លោក **ថែម សារឹម** អភិបាលស្រុកឱរ៉ាល់

៣- លោក **ពូល នៅ** អភិបាលស្រុកឧដុង្គ

៤- លោក **ហងៀ គីមញៀន** អភិបាលស្រុកសំរោងទង

៥- លោក **ឆេត មាន** អភិបាលស្រុកភ្នំស្រួច

៦- លោក **ឈុម គីមស្រេង** អភិបាលស្រុកបរសេដ្ឋ ។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ៤ ៧ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៦១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំង និងផ្ទេរភារកិច្ចមន្ត្រីរាជការ

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុងនិងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

តែងតាំងមន្ត្រីរាជការចំនួន **០៩រូប** ជាអភិបាលក្រុង ស្រុក នៃខេត្តកំពង់ចាម សម្រាប់អាណត្តិទី២ នៅក្នុងដែនសមត្ថកិច្ចដែល ដូចមានរាយនាមខាងក្រោម :

១- លោក **អ៊ុត ថៅត** អភិបាលក្រុងកំពង់ចាម
២- លោក **ជា សុខរិទ្ធិ** អភិបាលក្រុងសួង
៣- លោក **ឡោ ចាន់លី** អភិបាលស្រុកបាធាយ
៤- លោក **ហេង ចណ្ណានី** អភិបាលស្រុកស្រីសន្ធរ
៥- លោក **កៅ សុខអាន** អភិបាលស្រុកស្ទឹងត្រង់
៦- លោក **ង៉ម សោភ័ណរត្ន** អភិបាលស្រុកជើងព្រៃ
៧- លោក **ឡុង នាម** អភិបាលស្រុកពញាក្រែក
៨- លោក **គីម ឌី** អភិបាលស្រុកកំពង់សៀម
៩- លោក **ង៉ិច ពិសិដ្ឋ** អភិបាលស្រុកតំបែរ ។

**មាត្រា ២.-**

ផ្ទេរភារកិច្ចលោក **គីម នុតនិត្យា** ពីអភិបាលស្រុកចំការលើ ឱ្យទៅបម្រើការងារនៅសាលាខេត្តកំពង់ចាម ។

**មាត្រា ៣.-**

តែងតាំងមន្ត្រីរាជការចំនួន **០៣រូប** ជាអភិបាលស្រុក នៃខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :

១- លោក **ខ្លូត ចិន្តា** អភិបាលស្រុកចំការលើ
២- លោក **ម៉ឿន ផា** អភិបាលស្រុកកងមាស
៣- លោក **ឆេត រាមមុនី** អភិបាលស្រុកព្រៃឈរ ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងមាត្រា១ មាត្រា ២ និងមាត្រា៣ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ០៧ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុងនិងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច

**មាត្រា ១.-**

តែងតាំងមន្ត្រីរាជការចំនួន **០៥រូប** ជាអភិបាលក្រុង ស្រុក នៃខេត្តពោធិ៍សាត់ សម្រាប់អាណត្តិទី២ នៅក្នុងដែនសមត្ថកិច្ចដដែល ដូចមានរាយនាមខាងក្រោម :

| | |
|---|---|
| ១- លោក **ទឹម សារិន** | អភិបាលស្រុកក្រគរ |
| ២- លោក **សុខ លីមុត** | អភិបាលស្រុកកណ្តៀង |
| ៣- លោក **សៅ ជាវឿន** | អភិបាលស្រុកបាកាន |
| ៤- លោក **ឆេ ឈីម** | អភិបាលស្រុកវាលវែង |
| ៥- លោក **ឆាយ ម៉ាឌីណាល់** | អភិបាលក្រុងពោធិ៍សាត់ ។ |

**មាត្រា ២.-**

តែងតាំងលោក **សូ សាហុន** ជាអភិបាលស្រុកភ្នំក្រវាញ នៃខេត្តពោធិ៍សាត់ ។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងមាត្រា១ និងមាត្រា២ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៦ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការតែងតាំងសមាសភាពក្រុមប្រឹក្សាសកម្មភាពជនពិការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## សម្រេច

**ប្រការ ១**: ត្រូវបានតែងតាំងសមាសភាពរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការដូចខាងក្រោម៖

- សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ប្រធានកិត្តិយស
- ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រធាន
- ឯកឧត្តម **សែម សុខា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អនុប្រធាន
- ឯកឧត្តម **សេង លីមនៅ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន

| | | |
|---|---|---|
| - ឯកឧត្តម **តែ គុយស៊ាង** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| - ឯកឧត្តម **តេង សាវង្ស** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| - ឯកឧត្តម **នាង ផាត** | រដ្ឋលេខាធិការក្រសួងការពារជាតិ | អនុប្រធាន |
| - ឯកឧត្តម **យី វាសនា** | ទីប្រឹក្សារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងជានាយកប្រតិបត្តិមជ្ឈមណ្ឌលជាតិនៃជនពិការ | អនុប្រធាន |
| - ឯកឧត្តម **ឯម ច័ន្ទមករា** | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **ក.ស.ជ** | សមាជិកអចិន្ត្រៃយ៍ |
| - ឯកឧត្តម **ចាន់ រដ្ឋា** | អគ្គលេខាធិការរង ទទួលបន្ទុកកិច្ចសង្គ្រោះជនពិការដោយសារមីន នៃអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន | សមាជិក |
| - ឯកឧត្តម **គុយ ម៉ារ៉ាឌី** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| - ឯកឧត្តម **ជា អឿង** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| - ឯកឧត្តម **ហាប់ អូម៉ាលី** | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| - ឯកឧត្តម **រិន ធីរៈ** | អនុរដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| - ឯកឧត្តម **ហ៊ុយ សារ៉ាឌុច** | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| - ឯកឧត្តម **មាស ម៉ូនីកា** | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និង ដឹកជញ្ជូន | សមាជិក |
| - លោកជំទាវ **និត្យ ច័ន្ទតារីន** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| - លោកជំទាវ **ញ៉ែម មរកត** | អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិក |
| - ឯកឧត្តម **ចាប ឫទ្ធី** | អនុរដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| - ឯកឧត្តម **ពៅ ស៊ីង** | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| - ឯកឧត្តម **ម៉ិន ខេង** | អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | សមាជិក |
| - ឯកឧត្តម **មាន សុភា** | អនុរដ្ឋលេខាធិការរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| - ឯកឧត្តម **ម៉ាន សុគ្រី** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| - ឯកឧត្តម **អ៊ិត រ៉ាឌី** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| - ឯកឧត្តម **ស៊ឹម សួង** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| - លោកជំទាវ **ម៉ែន នារីសោភ័គ** | អគ្គលេខាធិការរងកាកបាទក្រហមកម្ពុជា | សមាជិក |
| - ឯកឧត្តម **រ៉ុត ឧទ្ទី** | អគ្គលេខាធិការរងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| - ឯកឧត្តម **សាន វឌ្ឍនា** | អគ្គលេខាធិការរងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ | សមាជិក |
| - ឯកឧត្តម **ខួន ម៉េងគិច** | អគ្គនាយកសភាពាណិជ្ជកម្មកម្ពុជា | សមាជិក |
| - លោកស្រី **ម៉ក់ វណ្ណាស៊ីថា** | អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញ | សមាជិក |
| - លោក **ជាវ តាយ** | អភិបាលរងនៃគណៈអភិបាលខេត្តកណ្តាល | សមាជិក |
| - លោកស្រី **ស៊ី វណ្ណាថា** | អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ចាម | សមាជិក |
| - លោកស្រី **ស៊ឹម ម៉ារី** | អភិបាលរងនៃគណៈអភិបាលខេត្តបាត់ដំបង | សមាជិក |
| - លោក **គឹម ឆៃហៀង** | អភិបាលរងនៃគណៈអភិបាលខេត្តសៀមរាប | សមាជិក |
| - លោក **ស៊ុយ សេរិទ្ធ** | អភិបាលរងនៃគណៈអភិបាលខេត្តព្រះវិហារ | សមាជិក |
| - លោកស្រី **កង សៅវឆន** | អភិបាលរងនៃគណៈអភិបាលខេត្តកំពត | សមាជិក |

| | | |
|---|---|---|
| - លោក **សុខ លូ** | អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ធំ | សមាជិក |
| - លោក **ភាន រិទ្ធី** | អភិបាលរងនៃគណៈអភិបាលខេត្តប៉ៃលិន | សមាជិក |
| - លោកស្រី **គង់ ស៊ីផា** | អភិបាលរងនៃគណៈអភិបាលខេត្តស្ទឹងត្រែង | សមាជិក |
| - លោក **សៀត គឹមលៀង** | អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង | សមាជិក |
| - លោកស្រី **កែវ សារឿន** | អភិបាលរងនៃគណៈអភិបាលខេត្តរតនគិរី | សមាជិក |
| - លោក **សឿ សុខណាល់** | អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ស្ពឺ | សមាជិក |
| - លោក **កែវ សែន** | អភិបាលរងនៃគណៈអភិបាលខេត្តពោធិ៍សាត់ | សមាជិក |
| - លោក **ស្រ៊ុន ស្រ៊ន់** | អភិបាលរងនៃគណៈអភិបាលខេត្តព្រះសីហនុ | សមាជិក |
| - លោក **សាយ សុជាតិ** | អភិបាលរងនៃគណៈអភិបាលខេត្តកោះកុង | សមាជិក |
| - លោកស្រី **ពៅ សុភាព** | អភិបាលរងនៃគណៈអភិបាលខេត្តស្វាយរៀង | សមាជិក |
| - លោក **ជាក់ ម៉េងហ៊ាង** | អភិបាលរងនៃគណៈអភិបាលខេត្តក្រចេះ | សមាជិក |
| - លោក **អៀង មួននី** | អភិបាលរងនៃគណៈអភិបាលខេត្តតាកែវ | សមាជិក |
| - លោក **អ៊ឹង ឆាយ** | អភិបាលរងនៃគណៈអភិបាលខេត្តកែប | សមាជិក |
| - លោក **ថង គឿន** | អភិបាលរងនៃគណៈអភិបាលខេត្តព្រៃវែង | សមាជិក |
| - លោក **អ៊ី ឡុង** | អភិបាលរងនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ | សមាជិក |
| - លោក **សាន វណ្ណា** | អភិបាលរងនៃគណៈអភិបាលខេត្តឧត្តរមានជ័យ | សមាជិក |
| - លោក **ស្វាយ សំអ៊ាង** | អភិបាលរងនៃគណៈអភិបាលខេត្តមណ្ឌលគិរី | សមាជិក |
| - លោក **ខិន សៅរ័ត្ន** | នាយកប្រតិបត្តិអង្គការជនពិការកម្ពុជា | សមាជិក |
| - លោក **មួន ម៉ៅ** | នាយកប្រតិបត្តិសមាគមនៃជនពិការភ្នែកកម្ពុជា | សមាជិក |
| - កញ្ញា **សុខ កុសល** | មន្ត្រីអង្គការជេស៊ីសបម្រើនៅកម្ពុជា ក្រុមយុទ្ធនាការកម្ពុជាលុបបំបាត់មីន | សមាជិក |
| - កញ្ញា **ស្រេង វណ្ណី** | គ្រូបង្រៀនគថ្លង់អង្គការគ្រួសារថ្មី | សមាជិក |
| - លោក **មិនយ៉ាមីន ឡៀន** | នាយកកម្មវិធីប្រចាំតំបន់អង្គការជនពិការអន្តរជាតិ | សមាជិក |

**ប្រការ២:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍
លេខៈ ០១៣ គសអ

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣

# សេចក្តីណែនាំ

គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍បានពិនិត្យឃើញថា គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍គ្រប់លំដាប់ថ្នាក់បានយកចិត្តទុកដាក់បញ្ជាដឹកនាំ ចាត់ចែងកម្លាំង និងចាត់វិធានការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ បំរើដល់ដំណើរការរៀបចំការបោះឆ្នោត ដែលបាននឹងកំពុងប្រព្រឹត្តទៅនាពេលនេះបានដោយរលូន និងទទួលបានជោគជ័យ ។ ប៉ុន្តែពេលថ្មីៗនេះលេចចេញនូវបាតុភាពមួយចំនួនឬអាចជាការរៀបចំពាក់ដែលមានចរិកធ្វើឲ្យល្អក់កករបរិយាកាសបោះឆ្នោត ដើម្បីយកលេសជាការគំរាមកំហែង បំភិតបំភ័យខាងនយោបាយ ធ្វើជាទល្លីករណ៍បំផ្លាញ ឬមិនទទួលស្គាល់លទ្ធផលបោះឆ្នោត ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ខាងមុខនេះ ។

អាស្រ័យហេតុនេះ ដើម្បីធានាឲ្យកាន់តែល្អប្រសើរបរិយាកាសសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយ សំរាប់កិច្ចដំណើរការបោះឆ្នោតទាំងមូល គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សូមធ្វើការណែនាំដូចខាងក្រោមៈ

១-បន្តជំរុញ អនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាពឲ្យក្លាយជាយុទ្ធនាការមួយព្រមៗគ្នាគ្រប់ភូមិ ឃុំ សង្កាត់ ទូទាំងប្រទេស ក្នុងគោលបំណងកៀងគរគ្រប់សមាសភាពទាំងអស់ក្នុងសង្គមចូលរួមឲ្យបានសកម្មក្នុងការរៀបចំសណ្តាប់ធ្នាប់សាធារណៈ ការបង្ការទប់ស្កាត់បទល្មើសគ្រប់ប្រភេទក៏ដូចជាបង្ការទប់ស្កាត់រាល់សកម្មភាពនានាដែលធ្វើឲ្យប៉ះពាល់ ឬបំផ្លិចបំផ្លាញដល់កិច្ចដំណើរការរៀបចំការបោះឆ្នោតដែលបាននឹងកំពុងប្រព្រឹត្តទៅនាពេលនេះ ។

២-អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ទោះក្នុងករណីណាក៏ដោយត្រូវខិតខំស្រាវជ្រាវស៊ើបអង្កេតឲ្យបានម៉ត់ចត់បទល្មើសនានាដែលកើតឡើង ជាពិសេសបទល្មើសព្រហ្មទណ្ឌដែលមានការចោទប្រកាន់ពាក់ព័ន្ធផ្នែកនយោបាយ និងឧប្បទ្ទវហេតុនានាដែលពាក់ព័ន្ធដល់បរិយាកាសនយោបាយដូចជាការគំរាមកំហែង បំភិតបំភ័យ ឬការទម្លាក់ផ្លាក ផ្តួលរំលំផ្លាក ការលាបពណ៌ផ្សេងៗលើស្លាកគណបក្សនានា ដែលមានចរិកជាការរៀបចំទុកជាមុនដូចជាករណីនៅខេត្តព្រៃវែង ខេត្តស្វាយរៀងកាលពីថ្ងៃទី១៨-១៩ ខែមិថុនា ឆ្នាំ២០១៣ ។ល។ ដើម្បីស្វែងរកចាប់ខ្លួនជនប្រព្រឹត្តបទល្មើសយកទៅផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

៣-ត្រូវចាត់វិធានការសកម្មក្នុងការប្រមែប្រមូលព័ត៌មានពីគ្រប់ប្រភព ដើម្បីពិចារណាវិភាគវាយតម្លៃ សន្និដ្ឋានរាល់ហេតុការណ៍ដែលកើតឡើង ពិសេសយកចិត្តទុកដាក់រាល់ទិន្នន័យទាំងអស់ដែលពាក់ព័ន្ធដល់សន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពនៃកិច្ចដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ។ ត្រូវយកចិត្តទុកដាក់ក្តាប់ជាប់រាល់បាតុភាពទំនាស់ផ្សេងៗ ក្នុងប្រជាពលរដ្ឋ ការប្រមូលផ្តុំតវ៉ា ឬការធ្វើបាតុកម្ម កូដកម្មនានារបស់កម្មករ ដោយត្រូវខិតខំសំរបសំរួល ដោះស្រាយមិនទុកឲ្យមានផលប៉ះពាល់ដល់ការបោះឆ្នោត នាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ខាងមុខនេះ ។

៤-គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍គ្រប់លំដាប់ថ្នាក់ និង អាជ្ញាធរមានសមត្ថកិច្ចត្រូវបន្តសហការចាត់វិធានការការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈសម្រាប់គ្រប់តំណាងភ្នាក់ងារ និងបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងប្រជាពលរដ្ឋ ដែលត្រូវចូលរួមក្នុងដំណើរការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣ ឲ្យបានមធ្យ័តបំផុតតាមដែនសមត្ថកិច្ចរបស់ខ្លួន ។

៥-ត្រូវបន្តយកចិត្តទុកដាក់សហការរៀបចំ និងចាត់វិធានការការពារសន្តិសុខ សុវត្ថិភាពនៅគ្រប់គោលដៅសំខាន់ៗ ជាអាទិ៍ ទីកន្លែងជួបជុំ ទីស្នាក់ការគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឧបករណ៍ មធ្យោបាយ សម្ភារៈឃោសនា ទីតាំងរក្សាទុក ឬក្បួនដឹកជញ្ជូនសម្ភារៈ និងឯកសារបោះឆ្នោតរបស់ គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

៦-ត្រូវយកចិត្តទុកដាក់ផ្តល់សេវាសន្តិសុខដោយស្មើភាពគ្នាជូនគ្រប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតទាំងអស់ ជាពិសេសក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត ត្រូវផ្តោតសំខាន់លើការបែងចែកកម្លាំងការពារគ្រប់ក្បួនឃោសនាឆ្នោះឆ្នោត ការពារនៅជុំវិញបរិវេណនៃអង្គពិធីឃោសនា ដោយធានារក្សាឲ្យបានសណ្តាប់ធ្នាប់សាធារណៈ សណ្តាប់ធ្នាប់ចរាចរ ព្រមទាំងបរិយាកាសនយោបាយល្អគ្មានការបំភិតបំភ័យ ការគំរាមកំហែង និងអំពើហិង្សា ចលាចល ឬការអុកឡុករំខានផ្សេងៗ ។

៧-អាជ្ញាធរមានសមត្ថកិច្ច ត្រូវសហការឲ្យបានល្អជាមួយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៣ ដែលជាថ្ងៃស្ងប់ស្ងៀមឲ្យបានត្រឹមត្រូវតាមច្បាប់បោះឆ្នោត និងបទបញ្ជារបស់គ.ជ.ប ។ ភ្នាក់ងារសន្តិសុខបោះឆ្នោត សហការជាមួយប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ធានាឲ្យបានដាច់ខាតសន្តិសុខការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមនីតិវិធី និងបទបញ្ជាដែលបានកំណត់ ។

៨-គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍តាមលំដាប់ថ្នាក់ត្រូវរៀបចំឲ្យមានក្រុមប្រចាំការអចិន្ត្រៃយ៍នៅតាមថ្នាក់របស់ខ្លួន ដើម្បីទទួលព័ត៌មាន និងដោះស្រាយព័ត៌មានពាក់ព័ន្ធដល់ការបោះឆ្នោតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ ទន្ទឹមនោះត្រូវរៀបចំឲ្យមានក្រុមប្រតិកម្មរហ័ស ដើម្បីឆ្លើយតបចំពោះបាតុភាព

ឬឧប្បទ្វេហេតុផ្សេងៗ ជៀសវាងការផ្ទៀតកេងចំណេញខាងផ្នែកនយោបាយ ឬក្នុងគោលបំណង បំផ្លាញការបោះឆ្នោត ។

៩-គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ ថ្នាក់រាជធានី ខេត្ត ត្រូវធានារបាយការណ៍១ថ្ងៃ០២ដង (ព្រឹកម៉ោង៨ និងរសៀលម៉ោង២) ចាប់ពីពេលនេះ រហូតដល់ការបោះឆ្នោតបានចប់សព្វគ្រប់ជាស្ថាពរ លើកលែងករណីបន្ទាន់ជះឥទ្ធិពលដល់ផ្នែកនយោបាយត្រូវរាយការណ៍ជាវិសាមញ្ញជូនមកលេខាធិការដ្ឋាននៃគ.ស.អ ដើម្បីមានវិធានការដោះស្រាយទាន់ពេលវេលា ។

ទទួលបានសេចក្តីណែនាំនេះ សូមគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍គ្រប់លំដាប់ថ្នាក់ ចាត់វិធានការអនុវត្តឲ្យមានប្រសិទ្ធភាព ។

**គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍**

**ប្រធាន**

**ស ខេង**

<u>**ចម្លងជូន ៖**</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-ក្រសួងការពារជាតិ
-ក្រសួងមហាផ្ទៃ
-សមាជិក គ.ស.អ
-អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ
-អគ្គស្នងការដ្ឋាននគរបាលជាតិ
-បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
-គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ រាជធានី ខេត្ត
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:....០១...គគស

# គោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល
# ស្តីពី
# ការគ្រប់គ្រងកម្លាំងពលកម្ម និងលំហូរពលករទេសន្តរប្រវេសន៍កម្ពុជា

ដោយមើលឃើញថា៖ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រជាជនយើងបាននាំគ្នាធ្វើចំណាកស្រុកនិងឆ្លងដែនទៅធ្វើការនៅប្រទេសក្រៅយ៉ាងគគ្រឹកគគ្រេង មានទាំងទៅតាមប្រព័ន្ធផ្លូវការ និងទាំងតាមប្រព័ន្ធមិនផ្លូវការដោយអាណាធិបតេយ្យ និងពុំមានការគ្រប់គ្រងច្បាស់លាស់ ។

នៅក្នុងសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការគ្រប់គ្រងទេសន្តរប្រវេសន៍ ដែលរៀបចំឡើងដោយគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ (ប.ជ.រ.ព.ភ) កាលពីថ្ងៃទី ២៦ ដល់ទី២៨ ខែមិនា ឆ្នាំ២០១៣ នៅក្រសួងមហាផ្ទៃ យើងបានឯកភាពគ្នាហើយថា៖ ចំណាកស្រុក ឬទេសន្តរប្រវេសន៍ គឺជាចរន្តធម្មជាតិរបស់មនុស្សដែលព្យាយាមត្រាច់ចរ ដើម្បីស្វែងរកភាពរីកចម្រើនក្នុងជីវិតរស់នៅ ។ ប៉ុន្តែចំណុចដែលគួរឲ្យព្រួយបារម្ភក្នុងពេលបច្ចុប្បន្ននេះ គឺ ភាពរងគ្រោះរបស់ប្រជាពលរដ្ឋក្នុងពេលធ្វើទេសន្តរប្រវេសន៍ និងភាពអាណាធិបតេយ្យនៃការធ្វើចំណាកស្រុក ចាំបាច់ត្រូវគ្រប់គ្រង និងការពារ ។

ចំណាកស្រុក និងបញ្ហាទេសន្តរប្រវេសន៍បានក្លាយជារបៀបវារៈមួយសម្រាប់ការគិតគូរក្នុងក្របខ័ណ្ឌគោលនយោបាយជាតិ និងអន្តរជាតិ ដែលប្រទេសទាំងឡាយលើសកលលោកកំពុងតែប្រឈមនឹងការរកដំណោះស្រាយដែលមានប្រសិទ្ធិភាព ជាពិសេសដើម្បីសម្របសម្រួលឲ្យមានភាពសុខុដុម និងកិច្ចសហការល្អរវាងប្រទេសបញ្ជូន និងប្រទេសទទួល ពោលគឺប្រទេសដែលមានកម្លាំងពលកម្ម និងប្រទេសដែលត្រូវការកម្លាំងពលកម្ម ។ កិច្ចការនេះ ត្រូវការភាពឈ្លាសវៃ និងអត់ធ្មត់ក្នុងការដោះស្រាយ ព្រោះថា ជាការប្រកួតប្រជែងផ្នែកនយោបាយសេដ្ឋកិច្ច និងសង្គម ដែលប្រទេសនីមួយៗ ចាំបាច់ត្រូវការពារផលប្រយោជន៍ជាតិ និងប្រជាជនរៀងៗខ្លួន ។ ទន្ទឹមនឹងនោះ ជនល្មើសតែងប្រើប្រាស់ភាពខ្វះចន្លោះនៃកិច្ចសហការ និងការអនុវត្តន៍ច្បាប់ ដើម្បីកេងយកផលចំណេញពីគ្រប់តំណាក់កាលនៃការធ្វើទេសន្តរប្រវេសន៍ ធ្វើឲ្យពលករទទួលរងនូវការខាតបង់ ការឈឺចាប់ និងការលំបាកច្រើនរាប់មិនអស់ ក្នុងនោះ

ក៏មានទាំងការជួញដូរមនុស្ស ការរត់ពន្ធមនុស្ស ការរំលោភបំពានសិទ្ធិ និងការកេងប្រវ័ញ្ចគ្រប់រូបភាព លើពលករផងដែរ ។ ការឈឺចាប់ និងការខាតបង់របស់ពលករ ក៏ជាការឈឺចាប់ និងការខាតបង់របស់រាជរដ្ឋាភិបាលដែរ ព្រោះពលករគឺជាធនធានសេដ្ឋកិច្ច និងសង្គមដ៏មានតម្លៃ ជាមនុស្សពេញវ័យ ពេញកម្លាំងការងារ ដែលចាំបាច់ត្រូវរក្សា និងអភិវឌ្ឍកម្លាំងពលកម្មទាំងនេះ សម្រាប់ផលិតកម្ម និងសេវាកម្មក្នុងស្រុកដែលកំពុងតែខ្វះខាត ។

យើងចង់ឲ្យប្រជាពលរដ្ឋមានការងារធ្វើ មានមុខរបរសមរម្យ និងខិតខំលើកកម្ពស់ជីវភាពនៅក្នុងស្រុកឲ្យអស់លទ្ធភាព ដោយចាត់ទុកការធ្វើចំណាកស្រុកជាជម្រើសចុងក្រោយ និងគ្រាន់តែជាតំណាក់កាលបណ្តោះអាសន្នប៉ុណ្ណោះ ។

ដូចនេះ **ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា** ខ្ញុំសូមអំពាវនាវដល់ថ្នាក់ដឹកនាំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អាជ្ញាធរ និងសមត្ថកិច្ចគ្រប់ថ្នាក់ទាំងអស់ គប្បីយកចិត្តទុកដាក់អនុវត្តភារកិច្ចតាមមុខសញ្ញារៀងៗខ្លួន និងសហការគ្នាឲ្យបានល្អតាមទិសដៅតែមួយ គឺ៖ "

រួមគ្នាកសាងនូវបរិស្ថានល្អ សម្រាប់ជាជម្រើសជូនប្រជាពលរដ្ឋឲ្យអាចរស់នៅក្នុងស្រុកក៏ល្អប្រសើរ បើចេញទៅធ្វើការងារនៅក្រៅប្រទេសក៏ថ្លៃថ្នូរ និងមានសុវត្ថិភាព"

និងគប្បីជម្រុញការយកចិត្តទុកដាក់ធ្វើឲ្យសម្រេច នូវភារកិច្ចជាគន្លឹះដូចខាងក្រោម៖

១. ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ គប្បី៖

- ផ្តល់នូវការសម្របសម្រួលតាមនីតិវិធីរៀបរយ សមស្រប ងាយស្រួល និងមានលក្ខណៈជាប្រព័ន្ធ ដែលធានាដល់ការការពារសិទ្ធិ និងផលប្រយោជន៍ប្រកបដោយសមធម៌ជូនពលករ ពលការិនី ក៏ដូចជានិយោជក និងរវាងប្រទេសបញ្ជូន និងប្រទេសទទួល ។
- ជម្រុញការដោះស្រាយបញ្ហាដែលសេសសល់ ពាក់ព័ន្ធនឹងពលករ ពលការិនីដែលបានរងគ្រោះក្នុងអំឡុងពេលធ្វើទេសន្តរប្រវេសន៍ការងារនៅក្រៅប្រទេស និងដែលកំពុងប្រឈមនឹងការមិនទទួលខុសត្រូវពីក្រុមហ៊ុនដែលត្រូវបានបិទ ឬផ្អាក ឬចៅកែរត់ចោលក្រុមហ៊ុនជាដើម ដោយសហការផ្តល់ព័ត៌មាន ឯកសារពាក់ព័ន្ធទៅតុលាការ ដើម្បីផ្តន្ទាទោសជនខិលខូច និងរកយុត្តិធម៌ជូនជនរងគ្រោះ ព្រមទាំងទាមទារសំណងតាមនីតិវិធី ។
- សម្របសម្រួលជាមួយសមាគមទីភ្នាក់ងារជ្រើសរើសពលករ ដើម្បីពិនិត្យបញ្ចុះតម្លៃសេវាដែលត្រូវកាត់ពីពលករទៅធ្វើការនៅប្រទេសថៃពី១០ខែ(២ម៉ឺនបាត) ទៅ៦ខែ (១ម៉ឺនពីរពាន់បាត) វិញ ។
- បញ្ជូន ឈ្មោះ និងអាសយដ្ឋានក្រុមហ៊ុនជ្រើសរើសពលករដែលទទួលការអនុញ្ញាតិទៅអាជ្ញាធរដែនដីពាក់ព័ន្ធឲ្យបានជ្រាប និងផ្សព្វផ្សាយឲ្យបានទូលំទូលាយជូនប្រជាពលរដ្ឋ រួមជាមួយឯកសារបញ្ជាក់និងលក្ខខ័ណ្ឌនានា ដែលជាការទទួលខុសត្រូវរបស់ក្រុមហ៊ុនចំពោះរដ្ឋ និងពលករ ដើម្បីជៀសវាងការក្លែងបន្លំពីជនខិលខូច។

- ឲ្យក្រុមហ៊ុនបញ្ជូនបញ្ជីឈ្មោះ រូបថតនិងអត្តសញ្ញាណរបស់ភ្នាក់ងារឬបុគ្គលិករបស់ខ្លួនដែលមានភារកិច្ចចុះជ្រើសរើសពលករក្នុងមូលដ្ឋានដែលមានការអនុញ្ញាត ទៅអាជ្ញាធរមូលដ្ឋានសាម៉ីឲ្យចុះបញ្ជី និងផ្សព្វផ្សាយ ។ រាល់ការផ្លាស់ប្តូរត្រូវជូនពត៌មានជាថ្មី ។
- ជម្រុញការតាមដាន ត្រួតពិនិត្យ វាយតម្លៃ ទៅលើនីតិវិធី និងការអនុវត្តន៍របស់ក្រុមហ៊ុនដែលមានភារកិច្ចជ្រើសរើស បណ្តុះបណ្តាល បញ្ជូន ដើម្បីធានាសុវត្ថិភាព និងផលប្រយោជន៍ពលករកម្ពុជា និងដើម្បីដោះស្រាយបញ្ហាឲ្យបានទាន់ពេលវេលា ។
- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ តាមដានការបើកកន្លែងបណ្តុះបណ្តាលមួយចំនួន ដែលសង្ស័យថា បោកប្រាស់យុវជន យុវនារី អំពីការធានារកការងារនៅប្រទេសកូរ៉េ ជប៉ុន ថៃដែលមានបៀវត្សរ៍ខ្ពស់ ដើម្បីប្រមូលប្រាក់ រួចបិទសាលា ឬប្តូរឈ្មោះ ប្តូរទីតាំងដើម្បីរកស៊ីជាថ្មី ។ មុខសញ្ញានេះ គប្បីរកឲ្យឃើញ និងផ្តន្ទាទោសតាមច្បាប់ ។
- សហការជាមួយក្រសួងពាក់ព័ន្ធ ពិនិត្យ និងជម្រុញការផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិលេខ ១៨៩ ដែលស្តីពីការងារសមរម្យសម្រាប់អ្នកធ្វើការតាមផ្ទះ ដើម្បីជាមូលដ្ឋានគតិយុត្តិសម្រាប់ការពារពលករ និងលិខិតូបករណ៍ដទៃទៀតដែលពាក់ព័ន្ធនឹងការគោរព សិទ្ធិពលករទេសន្តរប្រវេសន៍ និងក្រុមគ្រួសារ ។

២. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ គប្បីពិនិត្យលទ្ធភាពក្នុងការបង្កើនចំនួនមន្ត្រីឲ្យទទួលបន្ទុកកិច្ចការពលករទេសន្តរប្រវេសន៍ ជាពិសេសក្នុងប្រទេសដែលមានពលករកម្ពុជាកំពុងធ្វើការងារនៅទីនោះ និង សហការជាមួយក្រសួងពាក់ព័ន្ធដើម្បីការពារពលករពីការរំលោភបំពាន ការជួញដូរ និងការកេងប្រវ័ញ្ចគ្រប់រូបភាព ។

៣. បណ្តាក្រសួង ស្ថាប័នដែលត្រូវបង្កើតការងារ និងមុខរបរជូនប្រជាពលរដ្ឋ មានជាអាទិ៍ ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងពាណិជ្ជកម្ម ក្រសួងទេសចរណ៍ ក្រសួងកសិកម្ម និងក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត គប្បីៈ

- ជម្រុញឲ្យមានកិច្ចសហការល្អជាមួយរោងចក្រ សហគ្រាស ក្រុមហ៊ុន ក្នុងការកសាងបរិស្ថាននិងបរិយាកាសការងារល្អ ដែលផ្តល់នូវជាសុខភាព និងភាពសប្បាយរីករាយក្នុងការងារ
- ពិនិត្យលទ្ធភាពក្នុងការផ្តល់នូវការលើកទឹកចិត្ត ដល់អ្នកប្រឹងប្រែងធ្វើការងារ ពង្រឹងវិន័យនិងសីលធម៌វិជ្ជាជីវៈ យកចិត្តទុកដាក់ដល់ការស្នាក់នៅ ហូបចុក ការថែទាំសុខភាពអនាម័យនិងបៀវត្សរ៍សមរម្យ ដើម្បីឲ្យពលករនឹងនចិត្ត ទាក់ទាញពលករខ្មែរនៅក្រៅប្រទេសវិលត្រឡប់មកធ្វើការងារក្នុងស្រុក និងកាត់បន្ថយលំហូរចេញកម្លាំងពលកម្ម ។
- ពង្រីកការផ្សព្វផ្សាយ ឲ្យបានទូលំទូលាយអំពីពត៌មានទីផ្សារក្នុងស្រុក ដែលមានលក្ខខ័ណ្ឌល្អប្រសើរ ដើម្បីប្រជាពលរដ្ឋមានបូលដ្ឋានក្នុងការសម្រេចចិត្ត ជ្រើសរើសការងារដែលខ្លួនពេញចិត្ត និងពិនិត្យឡើងវិញ ឬផ្អាកជាបន្ទាន់ រាល់ការផ្សព្វផ្សាយបំផ្លើសដើម្បីទាក់ទាញឲ្យទៅធ្វើការងារក្រៅប្រទេស ដោយគ្មានការទទួលខុសត្រូវ ។

៤. ក្រសួងមហាផ្ទៃ ដែលរាប់ទាំងរដ្ឋបាលស៊ីវិល កងកម្លាំងនគរបាល ជំនាញពាក់ព័ន្ធនឹងការផ្តល់លិខិតបទដ្ឋាន អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន...។ល។ គប្បី៖

- ពង្រឹងការអនុវត្តន៍ និងពិនិត្យឡើងវិញនូវរបៀបរបបការងារដើម្បីកាត់បន្ថយភាពស្មុគស្មាញក្នុងនីតិវិធី កាត់បន្ថយភ្នាក់ងារកណ្តាល ដែលនាំឲ្យមានការចំណាយកម្រៃខ្ពស់ និងប្រើពេលវេលាយូរ ។
- ផ្តល់ការណែនាំដល់អាជ្ញាធរមូលដ្ឋាននូវនីតិវិធីសម្រាប់ការគ្រប់គ្រងភាពចល័តរបស់ប្រជាពលរដ្ឋ កសាងបញ្ជីចេញចូល និងទំនាក់ទំនងសាកសួរព័ត៌មាន អប់រំ ជៀសវាងការចាញ់បោកការអូសទាញរបស់មេខ្យល់ ។
- ពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការកសាងបណ្តាញសុវត្ថិភាពភូមិ ឃុំ និងការកសាងផែនការវិនិយោគឃុំសង្កាត់ ដែលឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ ។
- ពង្រឹងនីតិវិធីក្នុងខេត្តសំចត ដើម្បីគ្រប់គ្រងប្រជាជនចល័តមកពីខេត្តដទៃ ដោយចុះបញ្ជី និងត្រួតពិនិត្យឲ្យបានដិតដល់ យកចិត្តទុកដាក់សាកសួរអំពីគោលដៅនៃការធ្វើ ចំណាកស្រុកដើម្បីធ្វើការអប់រំ និងទប់ស្កាត់ការឆ្លងដែនដោយខុសច្បាប់ ។

៥. គណៈកម្មាធិការជាតិ គ.ជ.អ.ប ពិនិត្យលទ្ធភាពក្នុងការបង្កើតការិយាល័យច្រកចេញចូលតែមួយរួមទាំងការផ្តល់លិខិតឆ្លងដែននៅតាមបណ្តាខេត្តគោលដៅ ដើម្បីផ្តល់សេវាជាកញ្ចប់ជូនប្រជាពលរដ្ឋ ដែលឆាប់រហ័ស និងមានតម្លៃថោកតាមការកំណត់ ជាពិសេសសេវាកម្មពាក់ព័ន្ធនឹងការរកការងារធ្វើនៅក្រៅប្រទេស ដោយផ្សារភ្ជាប់ទំនាក់ទំនងសហការជាមួយមជ្ឈមណ្ឌលសេវាការងាររបស់ថៃដែលគ្រោងនឹងបង្កើតដែរនោះ ។

៦. សមត្ថកិច្ចព្រំដែន ទាំងនគរបាល ទាំងយោធា ត្រូវសហការគ្នាក្នុងការពង្រឹងការត្រួតពិនិត្យការចេញចូលតាមច្រករបៀង និងគប្បីពិនិត្យលទ្ធភាពបង្កើតជាក្រុមការងារចម្រុះមួយដែលមានស្ថាប័ន និងអង្គភាពគន្លឹះពាក់ព័ន្ធ មានភារកិច្ចគ្រប់គ្រងលំហូរពលករក្នុងគោលដៅការពារអាយុជីវិត សិទ្ធិ និងផលប្រយោជន៍របស់ពលរដ្ឋកម្ពុជា ជាពិសេស យកចិត្តទុកដាក់ចំពោះផលប៉ះពាល់ទៅលើស្ត្រី និងកុមារក្នុងដំណើរការនៃការធ្វើទេសន្តរប្រវេសន៍ ។

៧. លើសពីនេះទៅទៀត ក្រសួងមហាផ្ទៃ ក្រសួងព័ត៌មាន ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងធម្មការសាសនា ក៏ដូចជាអាជ្ញាធរដែនដី និងអង្គការសង្គមស៊ីវិលទាំងអស់ គប្បីរួមសហការគ្នាផ្សព្វផ្សាយនូវព័ត៌មានជាក់លាក់ គោលការណ៍ គោលនយោបាយ បទដ្ឋាន និងនីតិវិធីទាំងឡាយ ឲ្យប្រជាពលរដ្ឋបានដឹងដូចៗគ្នា និងជម្រុញការអនុវត្តឲ្យស៊ីសង្វាក់គ្នាដើម្បីផ្តល់ភាពជឿជាក់ពីប្រជាពលរដ្ឋ ។

៨. គណៈកម្មាធិការជាតិ ប.ជ.រ.ព.ភ គប្បី៖

- ពង្រឹងកិច្ចសហការផ្ទៃក្នុង រវាងក្រសួង ស្ថាប័នពាក់ព័ន្ធឲ្យបានជិតស្និទ្ធ និងជម្រុញឲ្យមានកិច្ចព្រមព្រៀង ឬអនុស្សរណៈ ជាមួយប្រទេស ពាក់ព័ន្ធ ដោយមានខ្លឹមសារគ្រប់គ្រាន់ នីតិវិធីច្បាស់លាស់ប្រកបដោយការទទួលខុសត្រូវ ដើម្បីធានាដល់ការការពារពលករផង និងកិច្ចសហប្រតិបត្តិការល្អផង ជាពិសេសជាមួយស្ថានទូតកម្ពុជានៅក្នុងប្រទេសពាក់ព័ន្ធ ។
- ជម្រុញឲ្យក្រុមការងារទេសន្តរប្រវេសន៍ ដែលមានក្រសួងមហាផ្ទៃ និងក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈជាស្នូល ពិនិត្យលទ្ធភាពក្នុងការកសាងនីតិវិធីសមស្រប និងកិច្ចសហការជាមួយប្រទេសពាក់ព័ន្ធ ដើម្បីការពារ និងគ្រប់គ្រងពលករដែលស្វែងរកការងារមិនតាមប្រព័ន្ធរៀបរយដែលមានបច្ចុប្បន្ន និងបង្វែរការផ្តល់ភាពស្របច្បាប់ក្រោយពេលចូលទៅធ្វើការងារដោយខុសច្បាប់ ទៅជាការធានាភាពស្របច្បាប់ តាំងពីមុនពេលឆ្លងដែន។
- ជម្រុញការតាមដានត្រួតពិនិត្យ វាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តគោលការណ៍នេះ និងរាយការណ៍ជូនគណៈរដ្ឋមន្ត្រីអំពីភាពរីកចំរើន ។

ទទួលបានគោលការណ៍ណែនាំនេះ សូមឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មាធិការ រដ្ឋមន្ត្រី ប្រធានស្ថាប័ន និងអង្គភាពពាក់ព័ន្ធទាំងអស់ យកចិត្តទុកដាក់អនុវត្តឲ្យមានប្រសិទ្ធភាពចាប់ពីពេលនេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
-គ្រប់ខុទ្ទកាល័យក្រសួងស្ថាប័ន
-គ្រប់សាលារាជធានីខេត្ត
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ...... សហវ.....

រាជធានីភ្នំពេញ ថ្ងៃទី១៧ខែមិថុនា ឆ្នាំ២០១៣

## ប្រកាសណែនាំ
## ស្តីពី
## ការរៀបចំ អនុម័ត និងអនុវត្តថវិកាក្រុង ស្រុក

- យោងច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់ទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១
- យោងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨
- យោងអនុក្រឹត្យលេខ៣៦ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក
- យោងអនុក្រឹត្យលេខ១៧២ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមធ្វើការណែនាំអំពីគោលការណ៍សំខាន់ៗ និងនីតិវិធីក្នុងការរៀបចំ អនុម័ត និងអនុវត្តថវិការបស់រដ្ឋបាលក្រុង ស្រុក ដូចខាងក្រោម ៖

### ១.និយមន័យនិងគោលបំណងថវិកា

១.១ ថវិកាគឺជាលិខិតគតិយុត្តដែលក្រុមប្រឹក្សាក្រុង ស្រុកមានសិទ្ធិអំណាចក្នុងការគ្រោងចំណូល និងចំណាយ និងមានសិទ្ធិអនុវត្តចំណូល និងចំណាយស្របតាមគម្រោងថវិកាដែលបានអនុម័ត។

១.២ ថវិកាមានគោលបំណងបង្ហាញអំពីហិរញ្ញវត្ថុប្រចាំឆ្នាំ សម្រាប់ការអនុវត្តគោលនយោបាយរបស់រដ្ឋបាលក្រុង ស្រុក និងការអនុវត្តតួនាទី ភារកិច្ចរបស់រដ្ឋបាលក្រុង ស្រុកនិងសម្រាប់ជាមធ្យោបាយអនុវត្តប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដើម្បីធានាឱ្យមានធនធានហិរញ្ញវត្ថុសម្រាប់ការចំណាយប្រកបដោយនិរន្តភាព ស្របតាមបទដ្ឋានគតិយុត្ត និងធានាឱ្យការចំណាយជាក់ស្តែងត្រូវស្ថិតក្នុងកម្រិតឥណទានថវិកាដែលបានអនុម័ត។

### ២.គោលការណ៍ទូទៅ

ថវិការដ្ឋបាលក្រុង ស្រុក ត្រូវរៀបចំនិងអនុវត្តតាមគោលការណ៍ដូចខាងក្រោម ៖



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh. CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

២.១ ថវិការបស់រដ្ឋបាលក្រុង ស្រុកត្រូវបានរៀបចំឡើងជាពីរផ្នែក ៖

I. ផ្នែកថវិកាចរន្ត ៖ ផ្នែកនេះរួមមានចំណូលចរន្ត និងចំណាយចរន្ត។ ចំណាយចរន្តត្រូវរ៉ាប់រងដោយចំណូលចរន្ត។

II. ផ្នែកថវិកាមូលធន៖ ផ្នែកនេះរួមមានចំណូលមូលធន និងចំណាយមូលធន។ ចំណាយមូលធនត្រូវរ៉ាប់រងដោយចំណូលមូលធន។

- ក្នុងផ្នែកនីមួយៗ គម្រោងចំណាយសរុបមិនត្រូវលើសគម្រោងចំណូលសរុបឡើយ។

- អតិរេកចរន្តគឺជាលទ្ធផលវិជ្ជមាននៃផលដករវាងចំណូលចរន្តនឹងចំណាយចរន្ត។

- អតិរេកចរន្តត្រូវបានប្រើប្រាស់ជាប្រយោជន៍ដល់ថវិកាមូលធន។

- ក្នុងផ្នែកថវិកាមូលធន សរុបចំណាយត្រូវស្មើសរុបចំណូលមូលធនបូកនឹងអតិរេកចរន្ត (បើមាន)។

- ចំណូលមូលធនមិនអាចប្រើសម្រាប់ចំណាយចរន្តបានឡើយលើកលែងតែមានការកំណត់ដោយបទប្បញ្ញត្តិដោយឡែក។

២.២ ការរៀបចំប្រភេទចំណូល និងចំណាយរបស់រដ្ឋបាលក្រុង ស្រុកត្រូវធ្វើឡើងដោយផ្អែកតាមទម្រង់ និងចំណាត់ថ្នាក់នៃមាតិកាថវិកាដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

២.៣ ថវិការបស់រដ្ឋបាលស្រុកត្រូវរួមបញ្ចូលរាល់ចំណូល ចំណាយរបស់រដ្ឋបាលស្រុកដោយមិនគិតដល់ប្រភពដើម ឬចរិតលក្ខណៈឡើយ។

២.៤ ថវិការបស់រដ្ឋបាលក្រុងត្រូវរួមបញ្ចូលរាល់ចំណូល និងចំណាយទាំងអស់របស់រដ្ឋបាលក្រុង និងរដ្ឋបាលសង្កាត់នានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដោយមិនគិតដល់ប្រភពដើម ឬចរិតលក្ខណៈឡើយ។

២.៥ ថវិកា របស់រដ្ឋបាលក្រុងគឺជាកញ្ចប់ថវិកាដែលរួមបញ្ចូលទាំងថវិការបស់រដ្ឋបាលសង្កាត់ចំណុះក្រុង។

២.៦ ថវិការបស់រដ្ឋបាលក្រុង ស្រុកត្រូវឆ្លុះបញ្ចាំងរាល់ការចំណាយជាអាទិភាពនៃផែនការអភិវឌ្ឍន៍៥ឆ្នាំ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល។

២.៧ ឆ្នាំថវិការបស់រដ្ឋបាលក្រុង ស្រុកត្រូវចាប់ផ្តើមពីថ្ងៃទី០១ ខែមករា និងបញ្ចប់ត្រឹមថ្ងៃទី៣១ ខែធ្នូនៃឆ្នាំ។

២.៨ រាល់ចំណូលនិងចំណាយទាំងអស់ត្រូវតែជាផ្នែកនៃថវិកាឯកភាពមួយរបស់រដ្ឋបាលក្រុង ស្រុក។

២.៩ ថវិការបស់រដ្ឋបាលក្រុង ស្រុក ត្រូវបញ្ចូលនូវរាល់ចំណូល និងចំណាយទាំងអស់របស់រដ្ឋបាលក្រុង ស្រុកនីមួយៗ។

២.១០ សរុបគម្រោងចំណាយត្រូវធានាទាំងស្រុងដោយសរុបគម្រោងចំណូល។

២.១១ ចំណូលបានពីមុខសញ្ញាមួយមិនអាចគ្រោងសម្រាប់ទូទាត់តែលើចំណាយរបស់មុខសញ្ញានោះទេ លើកលែងតែការគ្រោងនោះត្រូវបានអនុញ្ញាតដោយបទប្បញ្ញត្តិដោយឡែក និងកិច្ចសន្យាដែលបានព្រមព្រៀង។

២.១២ ចំណូលត្រូវបានប្រមូល និងចំណាយត្រូវបានប្រើប្រាស់តាមខ្ទង់ថវិកាដែលបានអនុម័ត។

២.១៣ ចំណូលត្រូវប្រមូល និងបង្ហាញជាទឹកប្រាក់សរុប ដោយគ្មានការកាត់កងចំណាយណាមួយឡើយ។

## ៣.ចំណូល និងចំណាយរបស់រដ្ឋបាលក្រុង ស្រុក

### ៣.១ ចំណូល

ក. ធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក រួមមាន ៖

- ចំណូលពីប្រភពនៅមូលដ្ឋាន (សារពើពន្ធ និងមិនមែនសារពើពន្ធ)
- ចំណូលពីថ្នាក់ជាតិ
- ចំណូលផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តដទៃទៀត ។

ក.១ ចំណូលពីថ្នាក់ជាតិ រួមមាន ៖

- ចំណូលចែករំលែក
- មូលនិធិផ្ទេរពីថវិកាជាតិ និង
- ថ្លៃសេវាបានមកពីមុខងារជាភ្នាក់ងារដែលអនុវត្តដោយរដ្ឋបាលក្រុង ស្រុក ក្នុងនាមក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ។
- រដ្ឋបាលក្រុង ស្រុកមានសិទ្ធិទទួលពីថវិកាជាតិប្រចាំឆ្នាំនូវមូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ និងមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌ ។
- ចំណូលចែករំលែកជាមួយរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រុង ស្រុក ត្រូវចាត់ទុកជាចំណូលមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌ ។ ប្រភេទចំណូល និងសមាមាត្របែងចែកត្រូវកំណត់ដោយអនុក្រឹត្យ ។
- នៅពេលដែលប្រព័ន្ធផ្ទេរមូលនិធិឃុំ សង្កាត់មិនទាន់បានកែសម្រួល ការវិភាជន៍និងការផ្ទេរមូលនិធិឃុំ សង្កាត់ទៅឱ្យរដ្ឋបាលសង្កាត់ចំណុះរដ្ឋបាលក្រុង ត្រូវបានវិភាជន៍និងផ្ទេរក្នុងនាមជាអង្គភាពថវិការួមតែមួយសម្រាប់រដ្ឋបាលក្រុង (រដ្ឋបាលក្រុង និងរដ្ឋបាលសង្កាត់នានាចំណុះរដ្ឋបាលក្រុង) ។
- ប្រាក់កម្រៃ និងចំណូលដែលបានពីការអនុវត្តមុខងារជាភ្នាក់ងារ ត្រូវចាត់ទុកថាជាការផ្ទេរមូលនិធិមានភ្ជាប់លក្ខខណ្ឌ ។
- រាល់ចំណូលសម្រាប់ការអនុវត្តមុខងារជាកាតព្វកិច្ចដែលត្រូវបានប្រគល់ដោយរដ្ឋបាលថ្នាក់ជាតិ ត្រូវចាត់ទុកថា ជាចំណូលពីការផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌ ។

ក.២ ចំណូលពីប្រភពនៅមូលដ្ឋាន

**ចំណូលសារពើពន្ធនៅមូលដ្ឋាន** ៖ ជាចំណូលពន្ធ និងអាករដែលត្រូវបង្កើត និងកំណត់ដោយច្បាប់ក្នុងក្របខណ្ឌច្បាប់ស្តីពីសារពើពន្ធ ដើម្បីជាគុណប្រយោជន៍ទាំងស្រុងដល់ថវិការបស់រដ្ឋបាលក្រុង ស្រុក ។

ការបែងចែកប្រភេទ និងសមាមាត្រចំណូលពន្ធ និងអាករនៅមូលដ្ឋានរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវកំណត់ដោយអនុក្រឹត្យ ។

**ចំណូលមិនសារពើពន្ធនៅមូលដ្ឋាន** រួមមាន ៖

- ចំណូលដែលបានមកពីការជួលទ្រព្យសម្បត្តិរបស់រដ្ឋបាលក្រុង ស្រុក
- ចំណូលពីកម្រៃសេវាដែលត្រូវបង់ដោយអ្នកប្រើប្រាស់សេវាដែលបានផ្តល់ដោយរដ្ឋបាលក្រុង ស្រុក

- ចំណូលពីថ្លៃសេវារដ្ឋបាលលើការផ្តល់លិខិតអនុញ្ញាត អាជ្ញាប័ណ្ណ ការផ្តល់ឯកសាររដ្ឋបាល និងការផ្តល់សេវារដ្ឋបាលផ្សេងៗទៀត
- អំណោយដែលបានមកពីប្រភពខាងក្នុង និងខាងក្រៅដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ស្រុកនីមួយៗ
- កម្រៃសេវា និងចំណូលផ្សេងៗដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិដទៃទៀត។

ចំណូលចែករំលែករវាងរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត គឺជាចំណូលពីប្រភពនៅមូលដ្ឋាន។

ខ. ចំណូលចរន្តអាចបានមកពីប្រភពដូចខាងក្រោម ៖

ខ.១ ចំណូលសារពើពន្ធ ៖ គឺជាចំណូលដែលរដ្ឋបាលក្រុង ស្រុកទទួលបានតាមការកំណត់ដោយលិខិតបទដ្ឋានគតិយុត្តិដទៃទៀត។

**ខ.២ ចំណូលមិនមែនសារពើពន្ធរួមមាន៖**

- ផលទុននៃទ្រព្យសម្បត្តិក្រុង ស្រុក គឺជាចំណូលទទួលបានពីការជួល និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលក្រុង ស្រុកផលនៃសម្បទាន ផលទុនពីសហគ្រាសរបស់រដ្ឋបាលក្រុង ស្រុក និងផលទុនពីទ្រព្យសម្បត្តិផ្សេងៗទៀត។
- ផលទុនពីសេវា គឺជាចំណូលទទួលបានពីសេវារដ្ឋបាល សេវាសុរិយោដី សេវាផ្តល់អាជ្ញាប័ណ្ណធុរកិច្ច សេវាសំណង់ និងសេវាផ្សេងៗទៀត។
- ចំណូលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម គឺជាចំណូលទទួលបានពីការផាកពិន័យ ការដាក់ទណ្ឌកម្ម និងចំណូលដែលរដ្ឋបាលក្រុង ស្រុកបានចូលរួមក្នុងការបង្ក្រាបបទល្មើសផ្សេងៗទៀត ។
- ចំណូលពីការឧបត្ថម្ភកធន ឬអំណោយគឺជាចំណូលទទួលបានពីឧបត្ថម្ភកធនពីរដ្ឋគ្មានភ្ជាប់លក្ខខណ្ឌ (ការផ្ទេរពីមូលនិធិក្រុង ស្រុក) ឧបត្ថម្ភកធនពីរដ្ឋមានភ្ជាប់លក្ខខណ្ឌ ឧបត្ថម្ភកធនពីក្រសួងនានា (មុខងារប្រតិភូកម្ម) ឧបត្ថម្ភកធនពីខេត្ត ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ បដិភាគពីប្រជាពលរដ្ឋ សប្បុរសជន ចំណូលឧបត្ថម្ភពីប្រភពផ្សេងៗ។
- ចំណូលផ្សេងទៀត៖ ចំណូលទទួលបានពីការលក់ឡាយឡុងចលនៈនិងអចលនវត្ថុដែលលែងត្រូវការប្រើប្រាស់ និងចំណូលផ្សេងៗទៀត។

គ. ចំណូលមូលធនរបស់រដ្ឋបាលក្រុង ស្រុកបានមកពីប្រភពទាំងឡាយដូចខាងក្រោម ៖

- អតិរេកពីផ្នែកថវិកាចរន្ត ៖ ដូចដែលបានបញ្ជាក់ក្នុងចំណុចទី២ នៃគោលការណ៍ទូទៅខាងលើ។

- ឧបត្ថម្ភកធនមូលធនដែលជាចំណូលទទួលបានពីការឧបត្ថម្ភសម្រាប់ចូលរួមចំណែកក្នុងការវិនិយោគដូចជា ៖ ឧបត្ថម្ភកធនពីរដ្ឋគ្មានភ្ជាប់ល័ក្ខខ័ណ្ឌ (ការផ្ទេរពីមូលនិធិក្រុង ស្រុកមួយផ្នែកនៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន) ឧបត្ថម្ភកធនពីរដ្ឋ (មានភ្ជាប់ល័ក្ខខ័ណ្ឌ) ឧបត្ថម្ភកធនពីក្រសួងនានា (មុខងារប្រតិភូកម្ម) ឧបត្ថម្ភកធនពីខេត្ត ឧបត្ថម្ភកធនពីគម្រោងកម្មវិធីនានា ឧបត្ថម្ភកធនមិនមែនថវិកា និងឧបត្ថម្ភកធនផ្សេងៗទៀត។

៣.២ ចំណាយ

ក. ឥណទានចំណាយនានាក្នុងគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុកត្រូវបានគ្រោងឡើងសម្រាប់រដ្ឋបាលក្រុង ស្រុក បំពេញសកម្មភាពដូចខាងក្រោម ៖

- ចំណាយប្រតិបត្តិការរដ្ឋបាល ដោយរួមបញ្ចូលទាំងចំណាយប្រតិបត្តិការរបស់ក្រុមប្រឹក្សា
- ចំណាយក្នុងការបំពេញមុខងារជាកាតព្វកិច្ចដែលត្រូវបានប្រគល់ ឬបានធ្វើប្រតិភូកម្មស្របតាមមាត្រា២២២ មាត្រា២២៣ មាត្រា២២៥ និងមាត្រា២២៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ចំណាយក្នុងការបំពេញមុខងារជាជម្រើស ដែលមុខងារនេះត្រូវអនុវត្តផ្អែកតាមឆន្ទានុសិទ្ធិរបស់ក្រុមប្រឹក្សា
- ចំណាយក្នុងការអនុវត្តតួនាទី ភារកិច្ចផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តដទៃទៀត ។

រដ្ឋបាលក្រុង ស្រុក ត្រូវប្រើប្រាស់ធនធានមូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌសម្រាប់រ៉ាប់រងចំណាយក្នុងគោលបំណង ដូចខាងក្រោម ៖

- គ្រប់គ្រង ចាត់ចែងនិងអនុវត្តមុខងារជាកាតព្វកិច្ចដែលបានប្រគល់ ឬដែលបានធ្វើប្រតិភូកម្ម
- បន្តគ្រប់គ្រង ឬចាត់ចែងនិងអនុវត្តមុខងារជាជម្រើសដែលក្រសួងស្ថាប័នធ្លាប់បានអនុវត្ត ។

រដ្ឋបាលក្រុង ស្រុក ត្រូវប្រើប្រាស់ធនធានមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌសម្រាប់រ៉ាប់រងចំណាយក្នុងគោលបំណង ដូចខាងក្រោម ៖

- បំពេញភារកិច្ចតាមផ្លូវច្បាប់
- បំពេញមុខងារភារកិច្ចក្នុងការបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចំណាយផ្នែករដ្ឋបាលរបស់ខ្លួន និង
- គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសនានា ។

ធនធានវិភាជន៍នៃសមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅ និងសមាសភាគអភិវឌ្ឍន៍មូលដ្ឋានរបស់មូលនិធិក្រុង ស្រុក ដូចមានចែងក្នុងមាត្រា១២ នៃអនុក្រឹត្យលេខ៣៦ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក ត្រូវកត់ត្រាជាចំណូលចរន្តនិងជាចំណូលមូលធនដែលត្រូវរ៉ាប់រងលើចំណាយចរន្ត និងចំណាយមូលធនដូចខាងក្រោម ៖

ក.១ ចំណាយចរន្តទាំងឡាយដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់ធនធានមូលនិធិនៃសមាភាគប្រតិបត្តិការរដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុកមានជាអាទិ៍ដូចខាងក្រោម ៖

- ចំណាយប្រាក់បៀវត្ស និងបន្ទុកផ្សេងៗទៀតនៃអភិបាល អភិបាលរងនៃគណៈអភិបាលក្រុង ស្រុក
- ចំណាយប្រាក់បៀវត្ស និងបន្ទុកផ្សេងៗទៀតនៃបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក
- ចំណាយប្រាក់ឧបត្ថម្ភសមាជិកក្រុមប្រឹក្សាក្រុង ស្រុក
- ចំណាយកិច្ចប្រតិបត្តិការរដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុក ដោយរួមបញ្ចូលទាំងចំណាយប្រតិបត្តិការរបស់ក្រុមប្រឹក្សា
- ចំណាយជួសជុល ថែទាំសម្ភារៈបរិក្ខារ និងអគាររដ្ឋបាល
- ចំណាយលើថ្លៃឈ្នួល ទឹក ភ្លើង សម្ភារៈការិយាល័យ គមនាគមន៍និងដឹកជញ្ជូន

- ចំណាយចរន្តផ្សេងៗទៀតរបស់រដ្ឋបាលក្រុង ស្រុក។

ក.២ ចំណាយចរន្តដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់ធនធានមូលនិធិនៃសមាភាគអភិវឌ្ឍន៍មូលដ្ឋានរបស់ក្រុង ស្រុកជាចំណាយចរន្តទាំងឡាយដែលពាក់ព័ន្ធទៅនឹងការផ្តល់សេវាមូលដ្ឋានកិច្ចប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និង បរិក្ខារផ្សេងៗទៀត ដែលត្រូវបានប្រើប្រាស់សម្រាប់ការផ្តល់សេវាទាំងនោះ រួមមាន ៖

- ចំណាយជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធដែលបានកសាង ឬគ្រប់គ្រងដោយរដ្ឋបាលក្រុង ស្រុក
- ចំណាយថ្លៃជួលពលកម្ម ឬចំណាយចរន្តផ្សេងៗ ដែលទាក់ទងក្នុងកិច្ចប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និង ការផ្តល់សេវាពាក់ព័ន្ធនានា
- ចំណាយលើការផ្តល់សេវាគាំពារសង្គមសម្រាប់ប្រជាពលរដ្ឋមូលដ្ឋានដែលក្រីក្រនិងងាយរងគ្រោះបំផុត
- ចំណាយអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស
- ចំណាយគាំទ្រដល់កម្មវិធីអភិវឌ្ឍន៍របស់អង្គការ និងសហគមន៍មូលដ្ឋាន
- ចំណាយមិនមែនមូលធនផ្សេងៗ ទៀតជាប្រយោជន៍ដល់សុខមាលភាពនៃសហគមន៍មូលដ្ឋានឬគាំទ្រដល់ការ អភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាននិងការគ្រប់គ្រងធនធានធម្មជាតិដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ក្រុង ស្រុក។

ក.៣ ចំណាយមូលធនដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់ធនធានមូលនិធិនៃសមាភាគប្រតិបត្តិការរដ្ឋបាលរបស់ ក្រុង ស្រុក ជាចំណាយដែលពាក់ព័ន្ធទៅនឹងកិច្ចអភិវឌ្ឍ ឬលទ្ធកម្មលើអចលនទ្រព្យ ដូចជាអគារ បរិក្ខារការិយាល័យ គ្រឿងសង្ហារឹម មធ្យោបាយដឹកជញ្ជូនសម្រាប់ប្រើប្រាស់ក្នុងបុព្វហេតុរដ្ឋបាល។

ក.៤ ចំណាយមូលធនដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់ធនធានមូលនិធិនៃសមាភាគអភិវឌ្ឍន៍មូលដ្ឋានរបស់ក្រុង ស្រុកជាចំណាយដែលពាក់ព័ន្ធទៅនឹងការវិនិយោគក្នុងកិច្ចអភិវឌ្ឍមូលដ្ឋានរួមមាន ៖

- កិច្ចអភិវឌ្ឍនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដែលមិនមែនជាគម្រោងស្ថិតក្រោមការទទួលខុសត្រូវរបស់ភ្នាក់ងារ សាធារណៈផ្សេងៗទៀត
- គាំទ្រកិច្ចអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានក្នុងភាពជាដៃគូជាមួយអង្គការសហគមន៍មូលដ្ឋាន និងដៃគូឯកជននានា
- ផ្តល់សហហិរញ្ញប្បទានសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសង្គម សេដ្ឋកិច្ច ឬការផ្តល់សេវាផ្សេងៗក្នុងភាពជា ដៃគូជាមួយក្រុង ស្រុកដទៃទៀត ឬជាមួយភ្នាក់ងារថ្នាក់ជាតិនានា
- ចំណាយមូលធនផ្សេងៗទៀត ជាគុណប្រយោជន៍ដល់សុខុមាលភាពសហគមន៍មូលដ្ឋាន ឬគាំទ្រដល់ការ អភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុង ស្រុក។

ក.៥ រដ្ឋបាលក្រុង ស្រុកត្រូវគ្រោងឥណទានថវិកាចំពោះការប្រើប្រាស់ធនធាននៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន របស់ខ្លួន សម្រាប់ប្រភេទចំណាយក្នុងចំនុច «ក២» និងចំនុច «ក៤» ខាងលើ យ៉ាងហោចណាស់មានចំនួនស្មើនឹងធនធាន របស់ខ្លួនដែលផ្ទេរពីសមាសភាគអភិវឌ្ឍន៍មូលដ្ឋាននៃមូលនិធិក្រុង ស្រុក។

ខ. ចំណាយចរន្តរួមមាន ៖

- ការទិញ៖ ចំណាយលើការទិញសំភារៈសម្រាប់ការងារថែទាំទាំងឡាយដែលធ្វើដោយក្រុង ស្រុក ដូចជាសម្ភារៈ ផ្គត់ផ្គង់ថែទាំ សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈ បរិក្ខារ ថាមពល ទឹក និង សម្ភារៈផ្គត់ផ្គង់ផ្សេងៗ។

- **សេវាខាងក្រៅ៖** ចំណាយលើសេវាខាងក្រៅដែលផ្តល់ដោយសហគ្រាស អង្គភាពរដ្ឋ ឬក្រុមហ៊ុនឯកជនជារូបវន្តបុគ្គល និងនីតិបុគ្គលដូចជា កិច្ចសន្យានៃការផ្តល់សេវា ការជួល សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក ការថែទាំ និងការជួសជុល សោហ៊ុយធានារ៉ាប់រង សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ សោហ៊ុយដឹកជញ្ជូន និងចំណាយពាក់ព័ន្ធផ្សេងៗទៀត។
- **សេវាខាងក្រៅផ្សេងៗ៖** ចំណាយលើសេវាខាងក្រៅផ្សេងៗ ក្រៅពីចំណាយដូចបានបញ្ជាក់ខាងលើរួមមាន ៖ ការជួលបុគ្គលិកខាងក្រៅ ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស សោហ៊ុយប្រៃសណីយ៍និងទូរគមនាគមន៍ សោហ៊ុយធនាគារ និងសោហ៊ុយផ្សេងៗ។
- **បន្ទុកបុគ្គលិក៖** ចំណាយលើបន្ទុកបុគ្គលិក ដូចជាប្រាក់បៀវត្ស លាភការ ប្រាក់ឧបត្ថម្ភ រង្វាន់ផ្សេងៗ និងប្រាក់វិភាជន៍សង្គមសម្រាប់គណៈអភិបាល ក្រុមប្រឹក្សា បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ បុគ្គលិកមិនមែនក្របខ័ណ្ឌ និងបុគ្គលិកអណ្តែត និងចំណាយបុគ្គលិកផ្សេងទៀត។
- **ឧបត្ថម្ភកធននិងជំនួយសង្គម៖** ចំណាយសម្រាប់ជាការឧបត្ថម្ភកធនដល់ឃុំ សង្កាត់ ជំនួយសង្គម និងប្រាក់វិភាជន៍ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌ និងចំណាយជាការឧបត្ថម្ភកធននិងជំនួយផ្សេងទៀត។
- **ចំណាយមិនបានគ្រោងទុក៖** ចំណាយសម្រាប់ថវិកាខ្ទង់នេះមិនត្រូវមានចំនួនលើសពី៥%នៃថវិកាសរុបទេ។ ថវិកាចំណាយមិនបានគ្រោងទុក អាចត្រូវបានប្រើប្រាស់សម្រាប់រ៉ាប់រងលើការទទួលខុសត្រូវរបស់រដ្ឋបាលក្រុង ស្រុក ដែលចំណាយទាំងនោះមានឥណទានគ្រោងនៅក្នុងថវិកាដំបូង ប៉ុន្តែមិនមានឥណទានគ្រប់គ្រាន់ ឬមិនបានគ្រោងឥណទាន។

អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន ពេលមាន តម្រូវការប្រើប្រាស់ឥណទានចំណាយថវិកាមិនបានគ្រោងទុកដោយពុំចាំបាច់កែតម្រូវថវិកាឡើយ។

**គ. ចំណាយមូលធនរួមមានដូចខាងក្រោម ៖**

- **អចលកម្មអរូបី ៖** ចំណាយលើសោហ៊ុយសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ សោហ៊ុយការធ្វើអង្កេត សោហ៊ុយការរៀបចំគ្រោងការ ការធ្វើសម្បទាន ប៉ាតង់ អាជ្ញាប័ណ្ណ និងប្រភេទស្រដៀងគ្នា
- **អចលកម្មរូបី ៖** ចំណាយលើការទិញនិងកែលំអដីធ្លី និងធនធានធម្មជាតិ ចំណាយលើការសាងសង់ អាគារ និងហេដ្ឋារចនាសម្ព័ន្ធ ចំណាយលើបរិក្ខារ បច្ចេកទេស សំភារៈ និងឧបករណ៍ និងចំណាយលើការទិញអចលកម្មផ្សេងៗទៀតដែលត្រូវបានចាត់ថ្នាក់នៅក្នុងចំណាយជាមូលធន។ ចំណាយលើអចលកម្មអរូបី និងអចលកម្មរូបីគឺជាចំណាយលើការវិនិយោគផ្នែកប្រតិបត្តិការរដ្ឋបាល និងការវិនិយោគអភិវឌ្ឍន៍មូលដ្ឋានរបស់ក្រុង ស្រុក។

## ៤. ដំណើរការរៀបចំ និងអនុម័តថវិការបស់រដ្ឋបាលក្រុង ស្រុក

### ៤.១ គោលការណ៍ពាក់ព័ន្ធនឹងការរៀបចំថវិការបស់រដ្ឋបាលក្រុង ស្រុក

ការរៀបចំថវិការបស់រដ្ឋបាលក្រុង ស្រុក ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម ៖

៤.១.១ ការរៀបចំថវិការបស់រដ្ឋបាលក្រុង ស្រុកត្រូវផ្អែកលើគោលការណ៍ចែងក្នុងចំណុចទី១ អំពីគោលការណ៍ទូទៅ។

៤.១.២ ថវិការបស់រដ្ឋបាលក្រុង ស្រុកត្រូវបានរៀបចំ អនុម័ត ដោយផ្សព្វផ្សាយជាសាធារណៈ។

៤.១.៣ ចំណាយចរន្តសម្រាប់កិច្ចប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធនានានៃពេលបច្ចុប្បន្ន និងពេលអនាគតត្រូវគ្រោងឱ្យបានត្រឹមត្រូវនៅក្នុងផ្នែកថវិកាចរន្ត។

៤.១.៤ ការគ្រោងចំណូលត្រូវធ្វើឡើងដោយផ្អែកលើការប៉ាន់ប្រមាណដោយមានភាពប្រាកដប្រជានៃការរំពឹងទុក និងត្រូវពិចារណាលើរាល់កត្តាទាំងអស់ដែលអាចមានផលប៉ះពាល់ដល់ទំហំនៃចំណូលដែលត្រូវប្រមូលក្នុងឆ្នាំថវិកា។

៤.១.៥ ក្នុងករណីដែលគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុកមិនត្រូវបានអនុម័តមុនថ្ងៃទី០១ ខែមករា នៃឆ្នាំ សម្រាប់ការិយបរិច្ឆេទដែលត្រូវអនុវត្តទេនោះ អភិបាលនៃគណៈអភិបាលក្រុង ស្រុកមានសិទ្ធិ ៖

- ចំណាយប្រចាំខែក្នុងកម្រិត**១ភាគ១២** នៃថវិកាឆ្នាំមុនទៅតាមលទ្ធភាពធនធានដែលមាន
- ប្រមូលចំណូលតាមលក្ខខណ្ឌដែលបានអនុម័តដូចឆ្នាំមុន។

## ៤.២ ដំណើរការរៀបចំថវិការបស់រដ្ឋបាលក្រុង ស្រុក

ផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុកត្រូវរៀបចំដោយអភិបាលនៃគណៈអភិបាល និងអនុម័តដោយក្រុមប្រឹក្សាទៅតាមនីតិវិធីដូចខាងក្រោម ៖

### ក. <u>ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា</u>

**ក.១** បន្ទាប់ពីទទួលបានសេចក្តីណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដែលបានដាក់ចេញដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវចាប់ផ្តើមរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ថវិកាឆ្នាំបន្តបន្ទាប់ ដោយមានប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុជាជំនួយការ។ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកានេះ ត្រូវផ្អែកលើឯកសារមួយចំនួនដូចជា ៖

- សេចក្តីណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាដែលចេញដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលក្រុង ស្រុក
- ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

**ក.២** ផែនការយុទ្ធសាស្ត្រថវិកាត្រូវកំណត់អំពីគោលបំណងរួមសម្រាប់ឆ្នាំថវិកាបន្តបន្ទាប់ ដោយផ្អែកលើចំណាយជាអាទិភាពនានា (ទាំងមូលធន និងចរន្ត) ក្នុងកម្រិតនៃចំណូលដែលបានព្យាករណ៍ថានឹងប្រមូល ឬទទួលបានដោយរដ្ឋបាលក្រុង ស្រុក។

**ក.៣** អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវដាក់ជូនកិច្ចប្រជុំគណៈអភិបាលនូវសេចក្តីព្រាងផែនការយុទ្ធសាស្ត្រថវិកា ដើម្បីពិនិត្យ និងផ្តល់យោបល់ជូនក្រុមប្រឹក្សារបស់ខ្លួន។

**ក.៤** ក្រុមប្រឹក្សាក្រុង ស្រុកត្រូវពិនិត្យ និងអនុម័តផែនការយុទ្ធសាស្ត្រថវិកានៅក្នុងកិច្ចប្រជុំជាសាធារណៈ **យ៉ាងយូរបំផុតត្រឹមថ្ងៃទី០៧ ខែឧសភា**។

អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវធ្វើការកែតម្រូវសេចក្តីព្រាងផែនការយុទ្ធសាស្ត្រ ដោយផ្អែកទៅតាមលទ្ធផលកិច្ចប្រជុំពិភាក្សារបស់គណៈអភិបាល និងក្រុមប្រឹក្សា។

ក.៥ បន្ទាប់ពីផែនការយុទ្ធសាស្ត្រថវិកាត្រូវបានអនុម័តដោយក្រុមប្រឹក្សារួចហើយ អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវដាក់ជូនទៅអភិបាលនៃគណៈអភិបាលខេត្ត នូវផែនការយុទ្ធសាស្ត្រថវិកា ដើម្បីចាត់ចែងឱ្យមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តធ្វើការបូកសរុប និងផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ ខែឧសភា។

ខ. <u>ការរៀបចំគម្រោងថវិកា</u>

ខ.១ បន្ទាប់ពីបានទទួលសារាចរណែនាំស្ដីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុកដែលបានដាក់ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវរៀបចំគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុករបស់ខ្លួន ដោយមានប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុជាជំនួយការ។

ការរៀបចំគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុក ត្រូវផ្អែកលើឯកសារមួយចំនួនដូចខាងក្រោម ៖

- សារាចរណែនាំស្ដីពីបច្ចេកទេស នៃការរៀបចំគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុក
- ផែនការយុទ្ធសាស្ត្រថវិកា
- ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម
- របាយការណ៍ហិរញ្ញវត្ថុឆ្នាំមុន
- ព័ត៌មានថ្មីៗបំផុតស្ដីអំពីការអនុវត្តថវិកាឆ្នាំបច្ចុប្បន្ន
- សេចក្ដីជូនដំណឹងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការវិភាជន៍ធនធានមូលនិធិក្រុង ស្រុកប្រចាំឆ្នាំ និងការវិភាជន៍ធនធានមូលនិធិឃុំ សង្កាត់ប្រចាំឆ្នាំជូនដល់រដ្ឋបាលសង្កាត់នានាចំណុះរដ្ឋបាលក្រុង។
- ចំណូលផ្សេងៗទៀតដែលរដ្ឋបាលក្រុង ស្រុកនឹងទទួលបានដោយផ្អែកលើលិខិតបទដ្ឋាននានា។

ចំពោះថវិការបស់រដ្ឋបាលសង្កាត់ចំណុះរបស់រដ្ឋបាលក្រុង ក្រុមប្រឹក្សាក្រុងត្រូវកំណត់ថវិកាសម្រាប់សង្កាត់នានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងជូនដំណឹងដល់ក្រុមប្រឹក្សាសង្កាត់ឱ្យបានមុនថ្ងៃទី១៥ ខែឧសភា។ ក្រុមប្រឹក្សាសង្កាត់នីមួយៗត្រូវរៀបចំនិងអនុម័តកញ្ចប់ថវិកាក្នុងកម្រិតថវិកាដែលបានកំណត់ដោយក្រុមប្រឹក្សាក្រុងឱ្យបានមុន ថ្ងៃទី៣០ ខែឧសភា។ កញ្ចប់ថវិការបស់រដ្ឋបាលសង្កាត់នីមួយៗ ត្រូវឆ្លុះបញ្ចាំងអំពី ៖

- ចំណាយលើប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាសង្កាត់ និងមន្ត្រីភូមិ
- ចំណាយលើរដ្ឋបាលទូទៅ
- បញ្ជីសកម្មភាព និងគម្រោងវិនិយោគជាអាទិភាព

សង្កាត់ត្រូវផ្ញើកញ្ចប់ថវិការបស់ខ្លួនទៅរដ្ឋបាលក្រុង ដើម្បីដាក់បញ្ចូលទៅក្នុងថវិការបស់រដ្ឋបាលក្រុង។

អភិបាលនៃគណៈអភិបាលក្រុង ត្រូវបូកសរុបកញ្ចប់ថវិកាសង្កាត់នានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនជាមួយនឹងថវិការបស់ខ្លួន ដើម្បីឱ្យទៅជាថវិកាតែមួយរបស់រដ្ឋបាលក្រុង ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។

ខ.២ អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវធ្វើការពិគ្រោះយោបល់ទៅលើគម្រោងថវិកាជាមួយនឹងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមាររបស់ក្រុមប្រឹក្សា អំពីមធ្យោបាយ និងរបៀបដែលត្រូវដោះស្រាយបញ្ហាសមភាពយេនឌ័រនិងតម្រូវការជាក់ស្ដែងរបស់ស្ត្រី និងកុមារ ដើម្បីដាក់បញ្ចូលទៅក្នុងគម្រោងថវិកាក្រុង ស្រុករបស់ខ្លួន។

ក្រុមប្រឹក្សាក្រុង ស្រុកត្រូវធានាថាគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារបានចូលរួម និងពិភាក្សា ក្នុងដំណើរការរៀបចំគម្រោងថវិកា។

ខ.៣ ក្នុងគោលបំណងធ្វើឱ្យមានភាពប្រទាក់ក្រឡាគ្នា និងបំពេញឱ្យគ្នាទៅវិញទៅមករវាងសកម្មភាពដែលបានគ្រោងក្នុងថវិការបស់រដ្ឋបាលក្រុង ស្រុកជាមួយនឹងផែនការសកម្មភាពរបស់ក្រសួង ស្ថាប័នដែលនឹងត្រូវអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងការរៀបចំគម្រោងថវិកានេះ អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវធានាថា គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាក្រុង ស្រុក បានធ្វើការសិក្សានិងផ្តល់យោបល់អំពីការសម្របសម្រួលជាមួយនឹងផែនការសកម្មភាពនិងថវិការបស់ក្រសួង ស្ថាប័ន ឬមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័នដែលផ្តល់សេវា សម្ភារៈ ឬហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្នុងន័យនេះ អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវពិគ្រោះយោបល់ជាមួយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាក្រុង ស្រុកដើម្បីជាមូលដ្ឋានសម្រាប់រៀបចំគម្រោងថវិកា។

ខ.៤ គម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុកត្រូវមានឯកសារមួយចំនួនដូចខាងក្រោម ៖

- គម្រោងថវិកាប្រចាំឆ្នាំ
- អនុស្សរណៈនៃការបង្ហាញថវិកា
- តារាងសង្ខេបកម្មវិធីវិនិយោគប្រចាំឆ្នាំនៃកម្មវិធីវិនិយោគបីឆ្នាំរំកិល
- កម្មវិធីប្រតិបត្តិការលើការផ្តល់សេវាប្រចាំឆ្នាំ
- របាយការណ៍ឆមាសទី១ស្តីពីថវិកានៃឆ្នាំអនុវត្ត

អនុស្សរណៈនៃការបង្ហាញថវិកាត្រូវមាន ៖ ការប៉ាន់ស្មានផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលជាមូលដ្ឋាននៃគម្រោងថវិកា ការផ្សារភ្ជាប់ទៅនឹងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ និងការចូលរួមរបស់ប្រជាជនមូលដ្ឋាន។

តារាងសង្ខេបកម្មវិធីវិនិយោគប្រចាំឆ្នាំនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលភ្ជាប់មកជាមួយ ត្រូវលម្អិតអំពីព័ត៌មានស្តីពីគម្រោងនានាដែលរដ្ឋបាលក្រុង ស្រុកមានបំណងផ្តល់ហិរញ្ញប្បទាន និងអនុវត្តនៅឆ្នាំបន្ទាប់។ គម្រោងនីមួយៗត្រូវគូសបញ្ជាក់អំពីគោលបំណងនៃការវិនិយោគ និងបង្ហាញព័ត៌មានអំពីផលប្រយោជន៍រំពឹងទុកតម្លៃប៉ាន់ស្មាននិងកាលវិភាគនៃការអនុវត្ត ព្រមទាំងតម្លៃប្រតិបត្តិការប៉ាន់ស្មាននិងចំណូលដែលត្រូវប្រមូលបានពីកិច្ចប្រតិបត្តិគម្រោងនេះ។

កម្មវិធីប្រតិបត្តិការផ្តល់សេវាប្រចាំឆ្នាំដែលភ្ជាប់មកជាមួយ ត្រូវបង្ហាញព័ត៌មានលម្អិតអំពីគុណភាព និងបរិមាណនៃកិច្ចប្រតិបត្តិការ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធនានារបស់រដ្ឋបាលក្រុង ស្រុកនៅឆ្នាំបន្ទាប់ ដោយរួមបញ្ចូលទាំងលទ្ធផលរំពឹងទុកចំណាយប្រតិបត្តិការនិងផែនការថែទាំ។

ខ.៥ អភិបាលនៃគណៈអភិបាលក្រុងស្រុកក្នុងនាមក្រុមប្រឹក្សាត្រូវផ្សព្វផ្សាយ និងពិគ្រោះយោបល់ជាសាធារណៈនូវគម្រោងថវិកាយ៉ាងតិច២សប្តាហ៍មុនពេលកិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុង ស្រុក ដើម្បីប្រមូលយោបល់ចូលរួមរបស់ប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធនានាក្នុងដែនសមត្ថកិច្ចតាមវិធានការរបស់ខ្លួន និងត្រូវពិនិត្យកែសម្រួលឡើងវិញនូវគម្រោងថវិកានេះដោយផ្អែកលើមតិយោបល់ចូលរួមរបស់ប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធនានា។ អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវផ្សព្វផ្សាយជាសាធារណៈនូវគម្រោងថវិកាតាមរយៈយន្តការដូចខាងក្រោម ៖

- បិទលើក្តារព័ត៌មានសាធារណៈរបស់រដ្ឋបាលក្រុង ស្រុក
- បោះពុម្ពជាច្បាប់ចម្លងសម្រាប់ពិគ្រោះយោបល់ក្នុងសាលាក្រុង ស្រុក
- ផ្សព្វផ្សាយតាមមធ្យោបាយផ្សេងៗទៀតដែលក្រុមប្រឹក្សាក្រុង ស្រុកយល់ឃើញថាអាចជំរុញឱ្យប្រជាពលរដ្ឋ

ចូលរួមកាន់តែច្រើន ដើម្បីពិនិត្យលើគម្រោងថវិការបស់ខ្លួន។

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ត្រូវរៀបចំរបាយការណ៍ស្តីពីដំណើរការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ អំពីការរៀបចំថវិការបស់រដ្ឋបាលក្រុង ស្រុក។

ខ.៦ អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវដាក់ជូនកិច្ចប្រជុំគណៈអភិបាលនូវគម្រោងថវិកា និងឯកសារពាក់ព័ន្ធដើម្បីពិនិត្យ និងផ្តល់យោបល់មុននឹងដាក់ជូនក្រុមប្រឹក្សារបស់ខ្លួន **យ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ ខែមិថុនា**។ អភិបាលនៃគណៈអភិបាល ក្រុង ស្រុកត្រូវធ្វើការកែសម្រួលគម្រោងថវិកា ដោយផ្អែកទៅតាមលទ្ធផលកិច្ចប្រជុំពិភាក្សារបស់គណៈអភិបាល។

ចំពោះកិច្ចប្រជុំគណៈអភិបាលក្រុង ស្រុកលើគម្រោងថវិកាប្រចាំឆ្នាំ ត្រូវមានសមាសភាពចូលរួមដូចខាងក្រោម៖

- គណៈអភិបាលក្រុង ស្រុក
- នាយករដ្ឋបាល និងប្រធានការិយាល័យរដ្ឋបាលនិង ហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក
- អ្នកពាក់ព័ន្ធដទៃទៀត
- ចៅសង្កាត់ និងតំណាងគណៈកម្មាធិការកសាងផែនការ និងថវិកាសង្កាត់ (ចំពោះគម្រោងថវិកាក្រុង)។

ដោយឡែក ចំពោះកិច្ចប្រជុំគណៈអភិបាលក្រុងលើគម្រោងថវិកាប្រចាំឆ្នាំនេះមានគោលបំណង៖

- បង្ហាញអំពីសំណើគម្រោងចំណាយរបស់ក្រុមប្រឹក្សាសង្កាត់
- បង្កើតឱកាសសហប្រតិបត្តិការទៅវិញទៅមករវាងក្រុមប្រឹក្សាសង្កាត់ជិតខាងគ្នា
- កំណត់មុខងារ ឬសកម្មភាពដែលរដ្ឋបាលក្រុងអាចធ្វើប្រតិភូកម្មឱ្យក្រុមប្រឹក្សាសង្កាត់
- បញ្ហាផ្សេងទៀតដែលទាក់ទងនឹងដំណើររៀបចំថវិកាប្រចាំឆ្នាំ។

ខ.៧ ក្រុមប្រឹក្សា ស្រុកត្រូវប្រជុំជាសាធារណៈ ដើម្បីពិនិត្យពិភាក្សា និងអនុម័តទៅលើគម្រោងថវិកា **យ៉ាងយូរបំផុត ត្រឹមថ្ងៃទី៣០ ខែមិថុនា**។

ក្នុងការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាក្រុង ស្រុក ដើម្បីអនុម័តទៅលើគម្រោងថវិកា ក្រុមប្រឹក្សានិងអភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវដំណើរការដូចខាងក្រោម៖

- រៀបចំសេចក្តីថ្លែងហេតុស្តីពីការរៀបចំគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុក
- ធានាថា កាលបរិច្ឆេទនិងទីកន្លែងប្រជុំរបស់ក្រុមប្រឹក្សាត្រូវបានផ្សព្វផ្សាយជាសាធារណៈយ៉ាងហោច២សប្តាហ៍មុនកាលបរិច្ឆេទនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។
- ធានាថា ទីកន្លែងសម្រាប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា អាចផ្តល់លទ្ធភាពឱ្យអ្នកចូលរួមបានចំនួនច្រើនតាមដែលអាចធ្វើទៅបាន។
- អញ្ជើញប្រជាពលរដ្ឋ ដែលរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្នុងនាមជាអ្នកសង្កេតការណ៍។
- ធានាឱ្យមានកំណត់ហេតុកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។
- ក្រុមប្រឹក្សាត្រូវធានាថា ក្នុងដំណើរការពិនិត្យ ពិភាក្សានិងអនុម័តនេះ អនុសាសន៍របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារត្រូវបានឆ្លុះបញ្ចាំងនៅក្នុងគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុក។

- ក្រុមប្រឹក្សាត្រូវធានាថា ប្រជាពលរដ្ឋមូលដ្ឋានដែលមានការចាប់អារម្មណ៍អាចចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្តីពីការពិនិត្យ និងអនុម័តគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុក។
- ក្រុមប្រឹក្សាមានសិទ្ធិផ្លាស់ប្តូរគម្រោងថវិកាដែលដាក់ជូនដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ក្នុងករណីការផ្លាស់ប្តូរនោះមិនរំលោភច្បាប់ បទបញ្ញា ឬគោលការណ៍នៃការរៀបចំថវិកា។
- អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ប៉ុន្តែមិនមានសិទ្ធិបោះឆ្នោតអនុម័តទេ។
- អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវធ្វើការកែសម្រួលគម្រោងថវិកា ដោយផ្អែកទៅតាមលទ្ធផលនៃកិច្ចប្រជុំពិភាក្សារបស់ក្រុមប្រឹក្សា។

ខ.៨ បន្ទាប់ពីគម្រោងថវិកាត្រូវបានអនុម័តដោយក្រុមប្រឹក្សា អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវផ្ញើគម្រោងថវិកានិងឯកសារពាក់ព័ន្ធនានាទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងអភិបាលនៃគណៈអភិបាលខេត្ត ក្នុងសប្តាហ៍ទី១នៃខែកក្កដា។ គម្រោងថវិកា និងឯកសារពាក់ព័ន្ធដែលត្រូវផ្ញើជូននោះ រួមមានដូចខាងក្រោម ៖

- គម្រោងថវិកា
- ផែនការយុទ្ធសាស្រ្តថវិកា
- តារាងសង្ខេបកម្មវិធីវិនិយោគប្រចាំឆ្នាំនៃកម្មវិធីវិនិយោគបីឆ្នាំរំកិល
- កម្មវិធីប្រតិបត្តិការលើការផ្តល់សេវាប្រចាំឆ្នាំ
- កំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាស្តីពីការពិនិត្យ ពិភាក្សា និងអនុម័តគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុក
- របាយការណ៍ស្តីពីការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋលើដំណើរការរៀបចំថវិកា ដោយឡែកសម្រាប់ក្រុង របាយការណ៍នេះត្រូវរួមបញ្ចូលនូវការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសង្កាត់។

ខ.៩ បន្ទាប់ពីទទួលបានគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុក អភិបាលនៃគណៈអភិបាលខេត្តត្រូវធានាថា មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តធ្វើការបូកសរុបគម្រោងថវិកាក្រុង ស្រុកទាំងអស់នៅក្នុងខេត្ត រួចផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ ខែកក្កដា។

ក្នុងអំឡុងខែសីហា អភិបាលនៃគណៈអភិបាលខេត្តអមដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការសម្របសម្រួលជាមួយនាយករដ្ឋបាលសាលាខេត្ត ដើម្បីរៀបចំកម្មវិធី ពិនិត្យអនុលោមភាពនិងបញ្ជាក់លើគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុកទាំងអស់។

## គ. ការពិនិត្យអនុលោមភាព

គ.១ ក្នុងដំណើរការ ត្រួតពិនិត្យអនុលោមភាព អភិបាលនៃគណៈអភិបាលខេត្តអមដោយប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវពិនិត្យផ្ទៀងផ្ទាត់ តាមគោលការណ៍ដូចខាងក្រោម ៖

- គម្រោងថវិកាត្រូវបានរៀបចំឡើងទៅតាមទម្រង់ចំណាត់ថ្នាក់ថវិកា បែបបទនិងនីតិវិធីដែលបានកំណត់
- គម្រោងថវិកាត្រូវបានរៀបចំទៅតាមល័ក្ខខ័ណ្ឌដែលភ្ជាប់ទៅនឹងការប្រើប្រាស់ធនធានពីប្រភពជាក់លាក់
- ការគ្រោងឥណទានទៅតាមគោលការណ៍ចំណាយចាំបាច់របស់រដ្ឋបាលក្រុង ស្រុក
- គម្រោងថវិកាមានតុល្យភាពពិតប្រាកដរវាងចំណូល និងចំណាយថវិកា
- ប្រជាពលរដ្ឋមូលដ្ឋានបានចូលរួមក្នុងកិច្ចដំណើរការរៀបចំគម្រោងថវិកាក្រុង ស្រុក

- ក្រុមប្រឹក្សាក្រុង ស្រុកបានពិភាក្សា និងអនុម័តលើគម្រោងថវិកានៅក្នុងកិច្ចប្រជុំជាសាធារណៈ
- ល័ក្ខខ័ណ្ឌផ្សេងៗទៀតដែលតម្រូវដោយច្បាប់ ឬបទប្បញ្ញត្តិនានាត្រូវបានបំពេញ ។

គ.២ ការត្រួតពិនិត្យអនុលោមភាព ត្រូវដំណើរការដូចខាងក្រោម ៖

- អភិបាលនៃគណៈអភិបាលខេត្ត អមដោយប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនាយកទីចាត់ការហិរញ្ញវត្ថុ ត្រូវពិនិត្យគម្រោងថវិកា និងឯកសារពាក់ព័ន្ធ ដោយអនុវត្តទៅតាមគោលការណ៍នៃការពិនិត្យអនុលោមភាព ដូចមានចែងក្នុងចំណុច គ.១ ខាងលើនេះ ដោយមានការចូលរួមពីអភិបាលនៃគណៈភិបាលក្រុង ស្រុកសាមី និងអ្នកពាក់ព័ន្ធនានា ។
- អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវចូលរួមក្នុងកិច្ចប្រជុំនេះក្នុងនាមក្រុមប្រឹក្សា ហើយត្រូវរាយការណ៍ពីលទ្ធផលកិច្ចប្រជុំនេះជូនក្រុមប្រឹក្សារបស់ខ្លួនវិញ ។

គ.៣ ក្នុងករណីគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុករៀបចំមិនស្របទៅតាមគោលការណ៍នៃការ ពិនិត្យអនុលោមភាព អភិបាលនៃគណៈអភិបាលខេត្ត ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដោយបញ្ជាក់អំពីមូលហេតុ ចំណុចខ្វះខាតនិងអនុសាសន៍ជាក់លាក់ដល់អភិបាលនៃគណៈអភិបាលក្រុង ស្រុកដើម្បីរៀបចំកែសម្រួលឡើងវិញតាមនីតិវិធីជាធរមានឱ្យបានមុនថ្ងៃទី១៥ ខែកញ្ញា ដើម្បីឱ្យមានសង្គតិភាពជាមួយនឹងតម្រូវការនានានៃការពិនិត្យអនុលោមភាព ។

អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវពិនិត្យកែតម្រូវគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុកស្របតាមការជូនដំណឹងរបស់អភិបាលនៃគណៈអភិបាលខេត្ត ហើយរៀបចំដាក់ជូនក្រុមប្រឹក្សាក្រុង ស្រុកដើម្បីពិនិត្យនិងអនុម័តទៅតាមនីតិវិធីជាធរមានឱ្យបានមុនថ្ងៃទី៣០ ខែកញ្ញា ។

ប្រសិនបើគម្រោងថវិកាត្រូវបានបំពេញតាមលក្ខខណ្ឌនៃការពិនិត្យអនុលោមភាព អភិបាលនៃគណៈអភិបាលខេត្ត អមដោយប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបញ្ជាក់ទទួលស្គាល់លើឯកសារគម្រោងថវិកានិងចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ។ សេចក្តីជូនដំណឹងត្រូវភ្ជាប់ជាមួយឯកសារថវិកាដែលមានហត្ថលេខាសង្ខេបរបស់អភិបាលនៃគណៈអភិបាលខេត្ត ហើយបោះត្រាខេត្តលើគ្រប់ទំព័រនីមួយៗ ។

អភិបាលនៃគណៈអភិបាលខេត្ត ត្រូវថតចម្លងសេចក្តីជូនដំណឹង និងឯកសារថវិកាដែលបានបញ្ជាក់ទទួលស្គាល់ ជូនដល់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគារខេត្ត ។

### ឃ. ការអនុម័តគម្រោងថវិកា

គម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុកទាំងអស់ត្រូវបានបូកសរុបទៅជាផ្នែកមួយនៃគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងដាក់បញ្ចូលជាជំពូកមួយនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលនឹងត្រូវបានពិនិត្យសម្រេចដោយគណៈរដ្ឋមន្ត្រី និងបញ្ជូនទៅរដ្ឋសភានិងព្រឹទ្ធសភាដើម្បីពិនិត្យនិងអនុម័ត ។

បន្ទាប់ពីច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវបានអនុម័ត រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងចេញសេចក្តីប្រកាសបែងចែកកញ្ចប់ថវិកាក្រុង ស្រុកនីមួយៗដើម្បីអនុវត្ត ដោយចម្លងជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រធានរតនាគារខេត្ត ដើម្បីដំណើរការអនុវត្ត ។

## ៤.៣ ប្រតិទិននៃការរៀបចំនិងការអនិម័តថវិកាក្រុង ស្រុក

រដ្ឋបាលក្រុង ស្រុកត្រូវរៀបចំ និងអនុម័តថវិកាប្រចាំរបស់ខ្លួនតាមប្រតិទិនដូចខាងក្រោម ៖

| ជំហាន | ដំណើរការ ឬសកម្មភាព | ពេលវេលា |
|---|---|---|
| ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា | • អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកា<br>• ក្រុមប្រឹក្សាក្រុង ស្រុកអនុម័តផែនការយុទ្ធសាស្ត្រថវិកា<br>• អភិបាលនៃគណៈអភិបាលក្រុង ស្រុកដាក់ជូនផែនការយុទ្ធសាស្ត្រថវិកាទៅអភិបាលនៃគណៈអភិបាលខេត្ត។ | ថ្ងៃទី០១ ខែមីនា ដល់ថ្ងៃទី១៥ ខែឧសភា |
| ការរៀបចំគម្រោងថវិកា | • អភិបាលនៃគណៈអភិបាលក្រុង ស្រុករៀបចំគម្រោងថវិកា<br>• អភិបាលនៃគណៈអភិបាលក្រុង ស្រុកផ្សព្វផ្សាយជាសាធារណៈនូវគម្រោងថវិកាដំបូង ដើម្បីប្រមូលយោបល់ចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន<br>• អភិបាលនៃគណៈអភិបាលក្រុង ស្រុកកែសម្រួលគម្រោងថវិកាដំបូងដោយផ្អែកលើយោបល់ចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន<br>• អភិបាលនៃគណៈអភិបាលក្រុង ស្រុកដាក់ជូនក្រុមប្រឹក្សានូវគម្រោងថវិកា ក្រុង ស្រុក ដើម្បី ពិនិត្យ និងអនុម័ត។<br>• អភិបាលនៃគណៈអភិបាលក្រុង ស្រុកដាក់ជូនអភិបាលខេត្តនូវគម្រោងថវិការបស់ក្រុង ស្រុក ដើម្បីពិនិត្យអនុលោមភាព។ | ថ្ងៃទី០១-៣០ ខែមិថុនា |
| បូកសរុបគម្រោងថវិកា | • មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តបូកសរុបគម្រោងថវិការបស់ខេត្ត និងគម្រោងថវិការបស់ក្រុង ស្រុកក្នុងខេត្តឱ្យទៅជាទម្រង់ឯកសារមួយដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុហើយដាក់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ថ្ងៃទី០១-១៥ ខែកក្កដា |
| ការពិនិត្យអនុលោមភាព | • អភិបាលនៃគណៈអភិបាលខេត្តពិនិត្យអនុលោមភាពលើគម្រោងថវិកា<br>• អភិបាលនៃគណៈអភិបាលខេត្តបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកានិងចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អភិបាលនៃគណៈអភិបាលក្រុងស្រុក | ថ្ងៃទី០១-៣១ ខែសីហា |
| ការកែតម្រូវគម្រោងថវិកា | • អភិបាលនៃគណៈអភិបាលខេត្តជូនដំណឹងជាលាយលក្ខណ៍ដល់អភិបាលនៃគណៈអភិបាលក្រុងស្រុកពីភាពមិនបំពេញបានតាមគោលការណ៍ពិនិត្យអនុលោមភាព<br>• រដ្ឋបាលក្រុង ស្រុកកែតម្រូវ ពិនិត្យ និងអនុម័តគម្រោងថវិកាឡើងវិញ | មុនថ្ងៃទី១៥ ខែកញ្ញា<br>មុនថ្ងៃទី៣០ ខែកញ្ញា |
| ការបែងចែកកញ្ចប់ថវិកា | • អភិបាលនៃគណៈអភិបាលខេត្តជូនដំណឹងដល់អភិបាលនៃគណៈអភិបាលក្រុង ស្រុកអំពីកញ្ចប់ថវិការបស់រដ្ឋបាលក្រុង ស្រុកដែលត្រូវអនុវត្តប្រចាំឆ្នាំ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ | ពីថ្ងៃទី០១ ដល់ ៣១ ខែមករា |

## ៥. ការអនុវត្តថវិកា

### ៥.១ គោលការណ៍ពាក់ព័ន្ធនឹងការអនុវត្តថវិកា

ការអនុវត្តថវិការបស់រដ្ឋបាលក្រុង ស្រុក ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម ៖

៥.១.១ អភិបាលនៃគណៈអភិបាលក្រុង ស្រុក នាមក្រុមប្រឹក្សា គឺជាអាណាប័កនៃថវិការបស់រដ្ឋបាលក្រុង ស្រុក។ អភិបាលនៃគណៈអភិបាលក្រុង ស្រុកមានសិទ្ធិអនុវត្តការប្រមូលចំណូល ការសន្យាចំណាយ និងការទូទាត់នានានៅក្នុងកម្រិតនៃថវិកាដែលបានអនុម័ត។

៥.១.២ ចៅសង្កាត់ចំណុះក្រុងគឺជាអាណាប័កផ្ទេរសិទ្ធិនៃកញ្ចប់ថវិកាដែលអភិបាលនៃគណៈអភិបាលក្រុងបានធ្វើប្រតិភូកម្ម។ ចៅសង្កាត់មានសិទ្ធិទទួលចំណូល ធ្វើការសន្យាចំណាយ និងទូទាត់ក្នុងកម្រិតនៃថវិកាដែលបាន អនុម័ត ដោយក្រុមប្រឹក្សាសង្កាត់ និងបានធ្វើប្រតិភូកម្មដោយអភិបាលនៃគណៈអភិបាលក្រុង ហើយចៅសង្កាត់ដែលជាអាណាប័កផ្ទេរសិទ្ធិត្រូវតម្កល់គំរូហត្ថលេខាដល់គណនេយ្យករមុខការនៅរតនាគារខេត្ត។ រាល់ប្រតិបត្តិការចំណូល និងចំណាយរបស់រដ្ឋបាលសង្កាត់ត្រូវធ្វើឡើងតាមរយៈគណនីប្រាក់បញ្ញើរបស់រដ្ឋបាលសង្កាត់ដែលបើកនៅរតនាគារខេត្ត។

៥.១.៣ អភិបាលនៃគណៈអភិបាលក្រុង ស្រុក អាចផ្ទេរសិទ្ធិជាលាយល័ក្ខណ៍អក្សរក្នុងការសម្រេចលើការអនុវត្តថវិកាឱ្យទៅអភិបាលរងណាម្នាក់ជាអាណាប័កផ្ទេរសិទ្ធិ។ អភិបាលរង ក្រុង ស្រុកនោះ ត្រូវបំពេញតួនាទីក្រោមការទទួលខុសត្រូវ និងការត្រួតពិនិត្យរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក។ អភិបាលនិងអភិបាលរងត្រូវតម្កល់គំរូហត្ថលេខាដល់គណនេយ្យករមុខការនៅរតនាគារខេត្ត។

៥.១.៤ រតនាគារខេត្ត ត្រូវបំពេញមុខងារជាគណនេយ្យករក្រុង ស្រុក និងត្រូវអនុវត្តភារកិច្ចទាំងឡាយដូចខាងក្រោម ៖

- ប្រមូល ឬទទួលចំណូលរបស់រដ្ឋបាលក្រុង ស្រុក
- ពិនិត្យ និងទូទាត់ចំណាយតាមអាណត្តិបើកប្រាក់ដែលចេញដោយអាណាប័ក ឬអាណាប័កផ្ទេរសិទ្ធិ
- អនុវត្តប្រព័ន្ធគណនេយ្យហិរញ្ញវត្ថុក្រុង ស្រុកស្របតាមគោលការណ៍ និងបទប្បញ្ញត្តិជាធរមាន
- រៀបចំរបាយការណ៍គណនេយ្យហិរញ្ញវត្ថុតាមកាលកំណត់ និង
- ថែរក្សាទុកដាក់រាល់ឯកសារ លិខិតយុត្តិកានៃប្រតិបត្តិការ និងបញ្ជីគណនេយ្យរបស់ក្រុង ស្រុក សម្រាប់រយៈពេលមិនតិចជាង១០ឆ្នាំ។

៥.១.៥ អភិបាលនៃគណៈអភិបាលក្រុង ស្រុកនីមួយៗត្រូវបើកគណនីប្រាក់បញ្ញើនៅរតនាគារខេត្ត។ រដ្ឋបាលក្រុង ស្រុកត្រូវប្រើប្រាស់គណនីប្រាក់បញ្ញើនេះ ដើម្បីគ្រប់គ្រងប្រតិបត្តិការចំណូល ចំណាយថវិការបស់ខ្លួន។

៥.១.៦ អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវធានានូវការតាមដានការអនុវត្តថវិកាស្របតាមនីតិវិធីនៃប្រព័ន្ធគណនេយ្យ និងទូទាត់ថវិការបស់រដ្ឋបាលក្រុង ស្រុក។

## ៥.២ ការគ្រប់គ្រងចំណូល

- ចំណូលផ្ទាល់របស់រដ្ឋបាលក្រុង ស្រុកត្រូវកំណត់ និងប្រមូលតាមបទប្បញ្ញត្តិ ច្បាប់ដោយឡែក។
- ចំណូលពីការផ្ទេរមូលនិធិគ្មានភ្ជាប់លក្ខខណ្ឌ និងមូលនិធិមានភ្ជាប់លក្ខខណ្ឌ នឹងត្រូវទទួលបានតាមលក្ខខណ្ឌដូចបានកំណត់ក្នុងអនុក្រឹត្យស្តីពីការផ្ទេរមូលនិធិគ្មានភ្ជាប់លក្ខខណ្ឌ និងមូលនិធិមានភ្ជាប់លក្ខខណ្ឌដល់ ក្រុង ស្រុក នីមួយៗ។

## ៥.៣.ការគ្រប់គ្រងចំណាយ

៥.៣.១ រដ្ឋបាលក្រុង ស្រុកត្រូវអនុវត្តចំណាយរបស់ខ្លួនស្របតាម និងក្នុងកម្រិតឥណទានក្នុងជំពូក គណនីនិង អនុគណនីនៅក្នុងថវិកាប្រចាំឆ្នាំដែលបានអនុម័ត។

៥.៣.២ ដំណើរការចំណាយរបស់រដ្ឋបាលក្រុង ស្រុកត្រូវអនុវត្តតាមដំណាក់កាលដូចខាងក្រោម ៖

- ការសន្យាចំណាយ
- កិច្ចដម្រះបញ្ជី
- អាណត្តិកិច្ច និង
- ការទូទាត់។

ការសន្យាចំណាយ កិច្ចដម្រះបញ្ជី អាណត្តិកិច្ច និងការទូទាត់ ត្រូវអនុវត្តន៍តាមបទប្បញ្ញត្តិ និងនីតិវិធីដែល កំណត់ក្នុងសារាចរណែនាំស្តីពីការអនុវត្តនីតិវិធីប្រព័ន្ធទូទាត់ និងប្រព័ន្ធគណនេយ្យរបស់រដ្ឋបាលក្រុង ស្រុក។

៥.៣.៣ ចំពោះការទូទាត់ថវិការបស់សង្កាត់ចំណុះក្រុងត្រូវអនុវត្តតាមអនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ឃុំ សង្កាត់ និងប្រកាសណែនាំស្តីពីប្រព័ន្ធទូទាត់និងប្រព័ន្ធគណនេយ្យឃុំ សង្កាត់ លើកលែងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនិងច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ បន្ទាប់ពីចៅសង្កាត់ បានចេញអាណត្តិបើកប្រាក់ដោយភ្ជាប់ជាមួយឯកសារពាក់ព័ន្ធទៅគណនេយ្យករក្រុងរួចហើយ ចៅសង្កាត់ត្រូវជូន ដំណឹងជាលាយលក្ខណ៍អក្សរនៃការបញ្ចេញអាណត្តិទូទាត់ ដល់អគ្គាហាគៈ និងរដ្ឋបាលក្រុង។

៥.៣.៤ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ត្រូវធ្វើអធិការកិច្ចក្រោយពេលការសន្យាចំណាយ កិច្ចដម្រះបញ្ជី និង ការទូទាត់នានារបស់រដ្ឋបាលក្រុង ស្រុកនៅនឹងកន្លែងតាមកាលកំណត់។ អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវ ធានាថា អ្នកធ្វើអធិការកិច្ចនានាមានសិទ្ធិគ្រប់គ្រាន់ក្នុងការពិនិត្យឯកសារ និងរបាយការណ៍ហិរញ្ញវត្ថុ និងសមិទ្ធផល នានាព្រមទាំងធានាថា មានកិច្ចសហការពេញលេញពីបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក។

## ៥.៤.ការកែតម្រូវថវិកាដំបូង

ថវិកាដំបូងអាចនឹងត្រូវកែសម្រួលក្នុងអំឡុងពេលនៃឆ្នាំថវិកា ដោយកែតម្រូវឥណទានចំណាយ និងចំណូល ដែល បានគ្រោងដោយផ្អែកតាមការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងហិរញ្ញវត្ថុ ដែលប៉ះពាល់ដល់ការព្យាករណ៍ ដំបូងនៃចំណូល និងឬចំណាយ ឬឆ្លើយតបនឹងតម្រូវការជាបន្ទាន់នានាក្នុងឆ្នាំថវិកា។

៥.៤.១ ក្នុងការកែតម្រូវថវិកាដំបូង រដ្ឋបាលក្រុង ស្រុកមានសិទ្ធិ ៖

- កាត់បន្ថយឥណទានចំណាយដែលបានគ្រោង ក្នុងករណីចំណូលដែលបានគ្រោងមិនអាចសម្រេចបាន។
- បង្កើនឥណទានចំណាយទៅលើសកម្មភាពនានាដែលបានគ្រោងរួចមកហើយ ឬសម្រាប់សកម្មភាពថ្មីនានាក្នុង ករណីចំណូលជាក់ស្តែងរបស់ថវិការបស់រដ្ឋបាលក្រុង ស្រុកបានកើនលើសពីគម្រោងចំណូលប្រចាំឆ្នាំដែលបាន គ្រោងទុក។
- ចលនាឥណទានផ្ទៃក្នុងនៃថវិការបស់រដ្ឋបាលក្រុង ស្រុកពីផ្នែកថវិកាចរន្តមកផ្នែកថវិកាមូលធននៃថវិកា ដំបូង ដោយពុំមានការផ្លាស់ប្តូរថវិកាសរុបនៅក្នុងថវិកាដំបូងឡើយ។

៥.៤.២ ការកែតម្រូវថវិកា ត្រូវអនុវត្តដូចគ្នាទៅនឹងដំណើរការរៀបចំថវិកាដំបូងផងដែរ។ ប៉ុន្តែប្រសិនបើជា ចលនាឥណទានដើម្បីបំពេញតម្រូវការចាំបាច់ក្នុងការអនុវត្តថវិការបស់រដ្ឋបាលក្រុង ស្រុកត្រូវកំណត់ដូចខាងក្រោម៖

- ការផ្ទេរនិយ័តកម្មឥណទានពីអនុគណនីមួយទៅអនុគណនីមួយ ឬពីគណនីមួយទៅគណនីមួយ នៃថវិការបស់រដ្ឋបាលក្រុង ស្រុក អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវស្នើសុំការអនុម័ត និងមានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្រុង ស្រុក និងផ្ញើជូនទៅអភិបាលនៃគណៈភិបាលខេត្ត ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រធានរតនាគារខេត្ត។
- ការផ្ទេរនិយ័តកម្មឥណទានពីជំពូកមួយទៅជំពូកមួយនៃថវិការបស់រដ្ឋបាលក្រុង ស្រុកត្រូវការបញ្ជាក់ទទួលស្គាល់ពីអភិបាលនៃគណៈអភិបាលខេត្តអមប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោយពីការពិនិត្យអនុម័តនិងមានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្រុង ស្រុក។

៥.៤.៣ អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវផ្តល់ឯកសារកែតម្រូវឬនិយ័តកម្មឥណទាននៃថវិការបស់រដ្ឋបាលក្រុង ស្រុក ទៅអភិបាលនៃគណៈអភិបាលខេត្ត ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រធានរតនាគារខេត្តក្នុងរយៈពេលយ៉ាងយូរ១០ថ្ងៃ បន្ទាប់ពីការកែតម្រូវឬការធ្វើនិយ័តកម្មត្រូវបានអនុម័តដោយក្រុមប្រឹក្សា។

## ៥.៥.ការបិទបញ្ជីថវិកា

នៅដំណាច់ឆ្នាំថវិកា អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវរៀបចំបិទបញ្ជីថវិកា ដើម្បីដាក់ជូនក្រុមប្រឹក្សាក្រុង ស្រុកពិនិត្យនិងអនុមត័។ ការរៀបចំបិទបញ្ជីថវិកាត្រូវដំណើរការដូចខាងក្រោម ៖

៥.៥.១ គណនេយ្យករក្រុង ស្រុកត្រូវរៀបចំសេចក្តីព្រាងរបាយការណ៍បិទបញ្ជីគណនេយ្យប្រចាំឆ្នាំ។

គណនេយ្យករក្រុង ស្រុកត្រូវដាក់ជូនសេចក្តីព្រាងរបាយការណ៍បិទបញ្ជីគណនេយ្យនេះដល់អភិបាលនៃគណៈអភិបាលក្រុង ស្រុក។

អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវធានាថារបាយការណ៍បិទបញ្ជីគណនេយ្យហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវបានរៀបចំឱ្យបានមុនថ្ងៃទី១៥ ខែកុម្ភៈ នៃឆ្នាំបន្ទាប់។

៥.៥.២ នៅដំណាច់ឆ្នាំថវិកា អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវទទួលខុសត្រូវលើការផ្តល់ផ្តងរបាយការណ៍ហិរញ្ញវត្ថុ ដែលរៀបចំដោយគណនេយ្យករក្រុង ស្រុកជាមួយនឹងសលាកប័ត្រតាមដានការប្រើប្រាស់ឥណទាន និងសលាកប័ត្រតាមដានចំណូល ដែលគ្រប់គ្រងដោយការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក។

៥.៥.៣ ប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុក្រុង ស្រុក និងគណនេយ្យករក្រុង ស្រុកត្រូវផ្ទុផ្តងរបាយការណ៍នានារបស់ខ្លួន។ ក្នុងករណីចាំបាច់ត្រូវស្រាវជ្រាវអំពីភាពខុសគ្នារវាងបញ្ជីកាគណនេយ្យថវិកាដែលគ្រប់គ្រងដោយការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ជាមួយនឹងបញ្ជីកាគណនេយ្យហិរញ្ញវត្ថុដែលគ្រប់គ្រងដោយគណនេយ្យករក្រុង ស្រុកនៅរតនាគារខេត្ត។

៥.៥.៤ អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវដាក់ជូនកិច្ចប្រជុំគណៈអភិបាល នូវរបាយការណ៍បិទបញ្ជីគណនេយ្យ និងរបាយការណ៍លម្អិតអំពីការអនុវត្តថវិកា ដើម្បីពិនិត្យនិងផ្តល់យោបល់មុននឹងដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងអនុម័ត។

៥.៥.៥ អភិបាលនៃគណៈអភិបាលក្រុង ស្រុកដាក់របាយការណ៍បិទបញ្ជីគណនេយ្យនិងរបាយការណ៍លម្អិតអំពីការអនុវត្តថវិកាជូនក្រុមប្រឹក្សារបស់ខ្លួននូវដើម្បីពិនិត្យនិងអនុម័តយ៉ាងយឺតបំផុតក្នុងរយៈពេល៣ខែ បន្ទាប់ពីកាលបរិច្ឆេទបិទនៃឆ្នាំថវិកានីមួយៗ។

៥.៥.៦ អភិបាលអភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវធ្វើរបាយការណ៍បិទបញ្ជីថវិកា និងសេចក្តីសម្រេចស្តីពីការបិទបញ្ជីថវិការបស់ក្រុមប្រឹក្សាក្រុង ស្រុកជូនទៅអភិបាលនៃគណៈអភិបាលខេត្ត និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យបញ្ជាក់នីត្យានុកូលភាព ហើយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវធ្វើការបូកសរុប និងបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែមេសានៃឆ្នាំបន្ទាប់ ។

៥.៥.៧ អភិបាលនៃគណៈអភិបាលខេត្ត ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការ ពិនិត្យបញ្ជាក់នីត្យានុកូលភាពទៅអភិបាលនៃគណៈអភិបាលក្រុង ស្រុកវិញយ៉ាងយឺតបំផុត២០ថ្ងៃ បន្ទាប់ពីទទួលបាននូវសេចក្តីសម្រេចបិទបញ្ជីថវិកាពីអភិបាលនៃគណៈអភិបាលក្រុង ស្រុក។

ក្រុមប្រឹក្សាខេត្ត អភិបាលនៃគណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក អភិបាលនៃគណៈអភិបាលក្រុង ស្រុក ក្រុមប្រឹក្សាសង្កាត់ ចៅសង្កាត់ ត្រូវអនុវត្តប្រកាសណែនាំនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន**÷
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ

«ដើម្បីជូនជ្រាប»
- រដ្ឋបាលខេត្ត
- រដ្ឋបាលក្រុង ស្រុក
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត
- រតនាគារខេត្ត

»ដើម្បីអនុវត្ត«
- ឯកសារកាលប្បវត្តិ-

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០២ សហវ.ជាក

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣

# សារាចរណែនាំ

## ស្តីពី

## ការអនុវត្តនីតិវិធីប្រព័ន្ធទូទាត់ និង ប្រព័ន្ធគណនេយ្យរបស់រដ្ឋបាលក្រុង ស្រុក

- យោងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨
- យោងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨
- យោងច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១
- យោងច្បាប់ស្តីពីលទ្ធកម្មសាធារណៈដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១២
- យោងអនុក្រឹត្យលេខ១៧២ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហរិញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក
- យោងអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត ការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វាយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- យោងអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- យោងប្រកាសលេខ២៨៥ សហវ.ប្រកបម ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីគោលការណ៍សំខាន់ៗនៃនីតិវិធីប្រព័ន្ធទូទាត់ និងប្រព័ន្ធគណនេយ្យរបស់រដ្ឋបាល ក្រុង ស្រុកដូចតទៅ៖

## ១. គោលការណ៍ទូទៅ

នីតិវិធីនៃប្រព័ន្ធទូទាត់ និងប្រព័ន្ធគណនេយ្យរបស់រដ្ឋបាលក្រុង ស្រុកត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

១.១ អភិបាលនៃគណៈអភិបាលក្រុង ស្រុកជាអាណាប័កក្នុងនាមក្រុមប្រឹក្សា និងមានសិទ្ធិពេញលេញ លើការអនុវត្តចំណូល ចំណាយស្របតាមថវិកាដែលបានអនុម័ត។

១.២ អភិបាលនៃគណៈអភិបាលក្រុង ស្រុកអាចផ្ទេរសិទ្ធិជាលាយល័ក្ខអក្សរក្នុងការសម្រេចលើថវិកាឱ្យទៅអភិបាលរងណាម្នាក់ជាអាណាប័កផ្ទេរសិទ្ធិ។ អាណាប័កផ្ទេរសិទ្ធិ ត្រូវធ្វើសកម្មភាពដោយស្ថិតក្នុងការទទួលខុសត្រូវ និងត្រួតពិនិត្យរបសអភិបាលនៃគណៈអភិបាលក្រុង ស្រុក។

១.៣ ចៅសង្កាត់ចំណុះក្រុងជាអាណាបក័ផ្ទេរសិទ្ធិពីអភិបាលនៃគណៈអភិបាលក្រុង ចំពោះកញ្ចប់ថវិកា ដែលក្រុងបានធ្វើប្រតិភូកម្មជូន។ ចៅសង្កាត់ត្រូវអនុវត្តកញ្ចប់ថវិកានេះ ដោយស្ថិតក្នុងការទទួលខុសត្រូវចំពោះមុខអភិបាលនៃគណៈអភិបាលក្រុង ។

១.៤ អភិបាលនៃគណៈអភិបាលក្រុង ស្រុក និងអាណាប័កផ្ទេរសិទ្ធិ (អភិបាលរងនិងចៅសង្កាត់ ដែលជាអាណាប័កផ្ទេរសិទ្ធិ) ត្រូវផ្តល់គំរូហត្ថលេខាដល់គណនេយ្យករមុខការ។

១.៥ អភិបាលនៃគណៈអភិបាល អាណាប័កផ្ទេរសិទ្ធិ និងមន្ត្រីនៃរដ្ឋបាលក្រុង ស្រុកទាំងអស់មិនត្រូវបានអនុញ្ញាតឱ្យកាន់កាប់ប្រាក់កាស ឬធ្វើការទូទាត់លើការចំណាយណាមួយឡើយ លើកលែងតែរដ្ឋទេយ្យករបុរេប្រទាន រដ្ឋទេយ្យករចំណូល និងភ្នាក់ងារបើកផ្តល់។

១.៦ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកធ្វើការត្រួតពិនិត្យថវិការបស់រដ្ឋបាលក្រុង ស្រុក ក្រោយពេលបោះផ្សាយអាណត្តិ មិនឱ្យលើសពីរយៈពេលបីថ្ងៃនៃថ្ងៃធ្វើការ។

១.៧ រតនាគារខេត្តត្រូវបំពេញមុខងារជាគណនេយ្យករក្រុង ស្រុក និងត្រូវអនុវត្តភារកិច្ចទាំងឡាយដូចខាងក្រោម ៖

- ប្រមូល ឬទទួលចំណូលរបស់រដ្ឋបាលក្រុង ស្រុក
- ពិនិត្យ និងទូទាត់ចំណាយតាមអាណត្តិបើកប្រាក់ដែលចេញដោយអាណាប័ក ឬ អាណាប័កផ្ទេរសិទ្ធិ អនុវត្តប្រព័ន្ធគណនេយ្យហិរញ្ញវត្ថុក្រុង ស្រុក ស្របតាមគោលការណ៍ និងបទប្បញ្ញត្តិជាធរមាន
- រៀបចំរបាយការណ៍គណនេយ្យហិរញ្ញវត្ថុតាមកាលកំណត់ និង

- ថែរក្សាទុកដាក់រាល់ឯកសារ លិខិតយុត្តិកានៃប្រតិបត្តិការ និងបញ្ជីគណនេយ្យរបស់ក្រុង ស្រុក សម្រាប់រយៈពេលមិនតិចជាង ១០ឆ្នាំ។

១.៨ អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវបើកគណនីប្រាក់បញ្ញើថវិការបស់រដ្ឋបាលក្រុង ស្រុក នៅរតនាគារខេត្ត ដែលគណនីនេះត្រូវប្រើប្រាស់សម្រាប់ប្រតិបត្តិការ ចំណូល ចំណាយរបស់រដ្ឋបាលក្រុង ស្រុក។ ដោយឡែក សង្កាត់ចំណុះក្រុងត្រូវបើកគណនីប្រាក់បញ្ញើថវិការបស់សង្កាត់នៅរតនាគារខេត្ត សម្រាប់ប្រតិបត្តិការចំណូល ចំណាយដែលបានទទួលប្រតិភូកម្មពីរដ្ឋបាលក្រុង។

១.៩ រដ្ឋបាលក្រុង ស្រុក អាចបើកគណនីនៅធនាគារពាណិជ្ជប្រតិស្រុតណាមួយ ដែលមានការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

១.១០ រដ្ឋបាលក្រុង ស្រុកមានកាតព្វកិច្ចតាមដាន បូកសរុប ផ្ទៀងផ្ទាត់ និងវិភាគ ជាលក្ខណៈប្រព័ន្ធទៅលើប្រតិបត្តិការថវិកា ហិរញ្ញវត្ថុនានា និងរៀបចំរបាយការណ៍តាមការកំណត់។

## ២. ប្រព័ន្ធទូទាត់របស់រដ្ឋបាលក្រុង ស្រុក

### ២.១ ការគ្រប់គ្រងកម្មវិធីចំណូល ចំណាយ

កម្មវិធីចំណូល ចំណាយគឺជាផែនការនៃការប្រមូលចំណូល និងការអនុវត្តចំណាយក្នុងឆ្នាំថវិកាស្របតាមថវិកាអនុម័ត ដែលបង្ហាញអំពីរបៀប និងកំណត់កាលបរិច្ឆេទនៃការកៀរគរ ការប្រមូល និងការទទួលចំណូលដែលបានមកពីការផ្ទេរ និងការប្រមូល និងកំណត់អំពីដំណាក់កាល ព្រមទាំងបង្ហាញអំពីរបៀប និងកំណត់កាលបរិច្ឆេទនៃការទូទាត់សម្រាប់ការអនុវត្ត ចំណាយថវិកា។

ក. <u>ការរៀបចំកម្មវិធីចំណូល ចំណាយ</u>

ក.១ ផ្អែកលើគម្រោងថវិកាប្រចាំឆ្នាំ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ត្រូវរៀបចំកម្មវិធីចំណូល ចំណាយប្រចាំត្រីមាសនីមួយៗ និងផ្ញើទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត និងរតនាគារខេត្ត។

ក.២ មុនដំណើរការរៀបចំកម្មវិធីចំណូល ចំណាយប្រចាំត្រីមាសនីមួយៗ អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវប្រមូលព័ត៌មានពីការិយាល័យចំណុះ និងអង្គភាពពាក់ព័ន្ធនានាដើម្បីកំណត់ពីពេលវេលានៃការទទួលបានចំណូល និងពីពេលវេលានៃការទូទាត់ចំណាយ។

ក.៣ ការរៀបចំកម្មវិធីចំណូល ចំណាយប្រចាំត្រីមាសនីមួយៗត្រូវផ្អែកលើថវិកាប្រចាំឆ្នាំដែលបានអនុម័តផែនការយុទ្ធសាស្ត្រថវិកា និងផែនការលទ្ធកម្មប្រចាំឆ្នាំ ដោយ៖

- បង្ហាញអំពីចំណូលដែលរំពឹងថាទទួលបាន (ចំណូលផ្ទាល់របស់ក្រុង ស្រុក និងចំណូលបានមកពីការផ្ទេរ)
- កំណត់អំពីកាលបរិច្ឆេទនិងចំនួនទឹកប្រាក់ ចំណូលដែលនឹងទទួលបាន និងដែលត្រូវប្រមូល
- កំណត់អំពីកាលបរិច្ឆេទនិងចំនួនទឹកប្រាក់ចំណាយដែលនឹងត្រូវទូទាត់

ឧ. <u>ការអនុវត្តកម្មវិធីចំណូល ចំណាយ</u>

ឧ.១ កម្មវិធីចំណូល ចំណាយ ត្រូវបានផ្សព្វផ្សាយដល់ការិយាល័យចំណុះ និងអង្គភាពពាក់ព័ន្ធនានា

ឧ.២ អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវធ្វើបច្ចុប្បន្នភាពបញ្ចូលកម្មវិធីចំណូល ចំណាយដែលមិនបានអនុវត្តទៅក្នុងកម្មវិធីចំណូល ចំណាយនៃត្រីមាសបន្ទាប់ ឬនៅពេលណាដែលអភិបាលនៃគណៈអភិបាលក្រុង ស្រុកទទួលបានព័តិមានបន្ថែមស្តីពីចំណូល ឬការសន្យាចំណាយ ។

ឧ.៣ អភិបាលនៃគណៈអភិបាល ក្រុង ស្រុក ត្រូវអនុវត្តកម្មវិធីចំណូល ចំណាយទៅតាមវិធានដូចខាងក្រោម ៖

- ការទូទាត់ត្រូវបានធ្វើឡើងក្នុងអំឡុងពេល និងកម្រិតដែលបានកំណត់
- ការប្រមូល និងការទទួលចំណូលត្រូវបានធ្វើឡើងក្នុងអំឡុងពេល និងកម្រិតដែលបានកំណត់
- វិធានការជាក់លាក់ត្រូវបានរៀបចំឡើង ដើម្បីដោះស្រាយរាល់បញ្ហាដោយសារការគ្រោងមិនបានត្រឹមត្រូវរវាងចំណូល និងចំណាយ

## ២.២ ខួបនៃការចំណាយ

២.២.១ ចំណាយរបស់រដ្ឋបាលក្រុង ស្រុក និងសង្កាត់ចំណុះក្រុង ត្រូវបំពេញលក្ខខណ្ឌពីរដូចខាងក្រោម ៖

- ចំណាយត្រឹមត្រូវតាមថវិកាដែលបានអនុម័ត
- ចំណាយត្រូវស្របតាមលិខិតបទដ្ឋាន-ជាធរមាន ។

២.២.២ ដំណើរការនៃចំណាយរបស់រដ្ឋបាលក្រុង ស្រុក និងសង្កាត់ចំណុះក្រុងរួមមានដំណាក់កាលដូចខាងក្រោម៖

- ការសន្យាចំណាយ
- ការជម្រះបញ្ជី
- ការបោះផ្សាយអាណត្តិបើកប្រាក់
- ការទូទាត់

អភិបាលនៃគណៈអភិបាលក្រុង ស្រុកនិងចៅសង្កាត់ចំណុះក្រុងត្រូវទទួលខុសត្រូវលើការសន្យាចំណាយ ការជម្រះបញ្ជី និងការបោះផ្សាយ អាណត្តិបើកប្រាក់ ។

គណនេយ្យករក្រុង ស្រុក និងសង្កាត់ត្រូវទទួលខុសត្រូវលើការទូទាត់ ។

ក. <u>ការសន្យាចំណាយ</u>

ការសន្យាចំណាយគឺជាការសម្រេចរបស់អាណាប័ក ឬអាណាប័កផ្ទេរសិទ្ធិដែលកំណត់នូវកាតព្វកិច្ចត្រូវទូទាត់គ្រប់រូបភាពចំណាយរបស់រដ្ឋបាលក្រុង ស្រុក និងសង្កាត់ចំណុះក្រុង ជូនអត្ថគាហក ។

ឃ. ការទូទាត់

គណនេយ្យករក្រុង ស្រុកត្រូវធ្វើការទូទាត់ដោយបើកជាសាច់ប្រាក់ ឬចេញមូលប្បទានប័ត្រ ដល់អ្នកទទួលការ អ្នកផ្គត់ផ្គង់ ឬអ្នកទទួលសិទ្ធិ។ មុនពេលទូទាត់ គណនេយ្យករក្រុង ស្រុកត្រូវធ្វើការត្រួតពិនិត្យលើចំណុចដូចខាងក្រោម ៖

- អាណត្តិបើកប្រាក់ត្រូវបានចុះហត្ថលេខាដោយអាណាប័កដែលមានលក្ខណៈសម្បត្តិត្រឹមត្រូវ
- សំណើទូទាត់ពិតជាត្រឹមត្រូវតាមប្រភេទចំណាយ និងមានឥណទានទំនេរគ្រប់គ្រាន់ក្នុងប្រភេទចំណាយនេះ
- ទំនិញ សំណង់ សេវា មានការបញ្ជាក់ថា បានទទួល ឬ ផ្តល់ពិតជាត្រឹមត្រូវ
- វិក្កយប័ត្រ និងឯកសារទាំងឡាយសម្រាប់ធ្វើការទូទាត់ពិតជាត្រឹមត្រូវនិងគ្រប់គ្រាន់
- ឥណទាយកពិតជាត្រឹមត្រូវតាមកិច្ចសន្យា
- ស្ថានភាពគណនីប្រាក់បញ្ញើក្រុង ស្រុកមានលទ្ធភាពទូទាត់បាន
- សុពលភាពនៃឥណទេយ្យត្រឹមត្រូវ
- ការហួតទុកនិងជំទាស់ ។

ក្នុងករណីមិនបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ដូចចែងខាងលើ គណនេយ្យករក្រុង ស្រុកមានសិទ្ធិផ្អាកការទូទាត់ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ដោយបញ្ជាក់ពីមូលហេតុ និងសំណូមពរបំពេញបន្ថែម។ អភិបាលនៃគណៈអភិបាលក្រុង ស្រុក និងគណនេយ្យករត្រូវពិភាក្សា ដើម្បីរកដំណោះស្រាយស្របតាមនីតិវិធីនៃការទូទាត់ ។

បន្ទាប់ពីបានទទួលការជូនដំណឹងពីគណនេយ្យករក្រុង ស្រុក អភិបាលនៃគណៈអភិបាលក្រុង ស្រុក ត្រូវ៖

- ធ្វើការកែតម្រូវ
- ចាត់វិធានការចាំបាច់ដើម្បីឆ្លើយតបទៅតាមការកំណត់នានារបស់គណនេយ្យករក្រុង ស្រុក និងបញ្ជូនលិខិតយុត្តិការដែលបានកែតម្រូវ ឬបំពេញបន្ថែមទៅគណនេយ្យករក្រុង ស្រុកវិញ។

មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត រតនាគារខេត្ត និងទីចាត់ការហិរញ្ញវត្ថុខេត្ត ត្រូវជួយ និងផ្តល់ការគាំទ្រដល់ក្រុង ស្រុកលើការអនុវត្តចំណាយថវិកា។

អភិបាលនៃគណៈអភិបាលក្រុង ដោយមានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុក្រុងជាជំនួយការត្រូវជួយ និងផ្តល់ការគាំទ្រដល់សង្កាត់ចំណុះ ក្រុងលើការអនុវត្ត ថវិកា ។

នៅរៀងរាល់ខែគណនេយ្យករក្រុង ស្រុកត្រូវផ្តល់ជូនទៅអភិបាលនៃគណៈអភិបាលក្រុង ស្រុក នូវរបាយការណ៍ចំណូល ចំណាយថវិកានិងបញ្ជីវិភាគនៃគណនីប្រាក់បញ្ញើថវិកាដែលបានអនុវត្ត។

## ២.៣ ការទូទាត់ប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ

អភិបាលនៃគណៈអភិបាលក្រុង ស្រុក និងចៅសង្កាត់ចំណុះក្រុងក្នុងនាមក្រុមប្រឹក្សា ឬអាណាប័កផ្ទេរសិទ្ធិជាអ្នកមានសិទ្ធិសម្រេចលើការសន្យាចំណាយ។ មុនពេលសន្យាលើចំណាយណាមួយ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ឬអាណាប័កផ្ទេរសិទ្ធិត្រូវធានាថា៖

- គម្រោងចំណាយដែលបានស្នើពិតជាត្រឹមត្រូវទៅតាមប្រភេទថវិកា
- ភាពទំនេរនៃឥណទានដែលមាននៅក្នុងសៀវភៅថវិកា និងភាពត្រឹមត្រូវតាមមាតិកាថវិកា និង
- គម្រោងចំណាយដែលត្រូវអនុវត្តកិច្ចលទ្ធកម្មត្រូវមាននៅក្នុងផែនការលទ្ធកម្ម។

ខ. <u>ការជម្រះបញ្ជី</u>

ការជម្រះបញ្ជីត្រូវធ្វើឡើងបន្ទាប់ពីទំនិញ សំណង់ សេវាត្រូវបានប្រគល់-ទទួលពីអ្នកទទួលការ អ្នកផ្គត់ផ្គង់ ឬអ្នកផ្តល់សេវា។ ការជម្រះបញ្ជីមានគោលបំណងធានាឱ្យកាតព្វកិច្ចនៃការទូទាត់មានសុពលភាព និងបញ្ជាក់ចំនួនទឹកប្រាក់ដែលត្រូវចំណាយពិតប្រាកដ និងការជម្រះបញ្ជីត្រូវដំណើរការដូចខាងក្រោម៖

- ការត្រួតពិនិត្យលើកាតព្វកិច្ចសម្រាប់ការទូទាត់ គឺអ្នកទទួលការ អ្នកផ្គត់ផ្គង់ ឬ អ្នកផ្តល់សេវា មានសិទ្ធិទាមទារការទូទាត់ នៅពេលការងារសម្រេចបានតាមលក្ខខណ្ឌនានាដែលមានចែងក្នុងកិច្ចសន្យា និងសុពលភាពនៃឥណទេយ្យ ។
- ការបញ្ជាក់ចំនួនទឹកប្រាក់ដែលត្រូវចំណាយពិតប្រាកដ គជាការផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវនៃវិក្កយបត្រ កិច្ចសន្យា របាយការណ៍ប្រគល់ ទទួល ទំនិញ សំណង់ សេវា របស់អ្នកទទួលការ ឬអ្នកផ្គត់ផ្គង់ វិក្កយបត្រត្រូវបញ្ជាក់ទទួលស្គាល់ដោយអាណាប័ក។

គ. <u>ការបោះផ្សាយអាណត្តិបើកប្រាក់</u>

បន្ទាប់ពីបានពិនិត្យត្រឹមត្រូវតាមចំនុចខាងលើ ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុក្រុង ស្រុក ត្រូវរៀបចំបោះផ្សាយអាណត្តិបើកប្រាក់ ដោយភ្ជាប់ជាមួយនូវលិខិតយុត្តិការនានា ដើម្បីដាក់ជូនអភិបាលនៃគណៈអភិបាលក្រុង ស្រុក ចុះហត្ថលេខហើយត្រូវបញ្ជូនទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីត្រួតពិនិត្យថវិកា បន្ទាប់មកត្រូវបញ្ជូនទៅគណនេយ្យករក្រុង ស្រុកនៅរតនាគារខេត្ត។ អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវជូនដំណឹងពីការបោះផ្សាយអាណត្តិបើកប្រាក់ ដល់អ្នកដែលត្រូវទទួលការទូទាត់ (អ្នកទទួលការ ឬអ្នកផ្គត់ផ្គង់)។

ចំពោះការទូទាត់ថវិការបស់សង្កាត់ចំណុះក្រុង ត្រូវអនុវត្តតាមអនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់។ បន្ទាប់ពីចៅសង្កាត់បានបោះផ្សាយអាណត្តិបើកប្រាក់ដោយភ្ជាប់ជាមួយនូវលិខិតយុត្តិការនានាទៅគណនេយ្យករសង្កាត់រួចហើយ ចៅសង្កាត់ត្រូវជូនដំណឹងពីការបោះផ្សាយអាណត្តិបើកប្រាក់ដល់អ្នកដែលត្រូវទទួលការទូទាត់ (អ្នកទទួលការ ឬអ្នកផ្គត់ផ្គង់) ។

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ត្រូវតាមដានអាណត្តិបើកប្រាក់ ដែលបានបញ្ជូនទៅឱ្យរតនាគារខេត្តដើម្បីទូទាត់ តាមរយៈសលាកបត្រតាមដានការប្រើប្រាស់ឥណទាន។

ភ្នាក់ងារបើកផ្តល់របស់រដ្ឋបាលក្រុង ស្រុកមានភារកិច្ច បើកផ្តល់ប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់ក្រុមប្រឹក្សា ដោយអនុវត្តតាមនីតិវិធី ដូចខាងក្រោម ៖

២.៣.១ អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវចេញសេចក្តីសម្រេចតែងតាំងមន្ត្រីក្នុងការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុរបស់សាលាក្រុង ស្រុក ជាភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួស ។

២.៣.២ ភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួសត្រូវបើកគណនីនិងតម្កល់គំរូហត្ថលេខានៅរតនាគារខេត្ត។

២.៣.៣ ភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួសត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ អភិបាលនៃគណៈអភិបាលក្រុង ស្រុក និង គណនេយ្យករ ក្រុង ស្រុក។

២.៣.៤ ភ្នាក់ងារបើកផ្តល់និងភ្នាក់ងារបើកផ្តល់ជំនួសមានភារកិច្ចដូចខាងក្រោម ៖

- រៀបចំតារាងសម្រាប់ទូទាត់ បៀវត្ស ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗនិងលិខិតយុត្តិការ ដើម្បីដាក់ជូនអភិបាលនៃគណៈអភិបាលក្រុង ស្រុកចុះហត្ថលេខា
- រៀបចំអាណត្តិបើកប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ ដោយភ្ជាប់ជាមួយតារាងសម្រាប់ទូទាត់ប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់ក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិក
- រៀបចំប័ណ្ណដកប្រាក់ពីគណនីប្រាក់បញ្ញើរបស់ភ្នាក់ងារបើកផ្តល់
- រក្សាទុកដាក់សាច់ប្រាក់នៅកន្លែងមានសុវត្ថិភាពដែលស្ថិតក្នុងសាលាក្រុង ស្រុក
- ភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួសមានការទទួលខុសត្រូវផ្ទាល់ខ្លួន និងជាប្រាក់កាស
- ផ្ញើតារាងទូទាត់បៀវត្ស ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ ដែលសមាជិកក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិកបានចុះហត្ថលេខាទៅរតនាគារខេត្ត។ ក្នុងករណីមានសំណេះចំណាយ ត្រូវបង្វែរប្រាក់ដែលនៅសល់ទៅក្នុងគណនីប្រាក់បញ្ញើក្រុង ស្រុកវិញ។

## ២.៤ រជ្ជទេយ្យបុរេប្រទាន

រជ្ជទេយ្យបុរេប្រទាននឹងត្រូវបង្កើតឡើងនៅដើមឆ្នាំថវិកា បន្ទាប់ពីគម្រោងថវិកាត្រូវបានអនុម័តសម្រាប់ការចំណាយដំណើរការរដ្ឋបាលដែលមានលក្ខណៈជាប្រចាំបន្ទាន់ មានចំនួនទឹកប្រាក់តិច ដែលមិនអាចរង់ចាំបោះផ្សាយអាណត្តិបើកប្រាក់តាមនីតិវិធីធម្មតាបាន រួមមានៈ ប្រាក់ជំនួយសង្គ្រោះបន្ទាន់ពិសេស ប្រាក់ចំណាយចាំបាច់ជាប្រចាំ ប្រាក់ធ្វើដំណើរ ប្រាក់បេសកកម្ម ចំណាយទិញសម្ភារៈតូចតាច។ រដ្ឋបាលក្រុង ស្រុកមានសិទ្ធិគ្រប់គ្រង និងចាត់ចែងរជ្ជទេយ្យបុរេប្រទានតាមនីតិវិធីដូចខាងក្រោម ៖

២.៤.១ រជ្ជទេយ្យបុរេប្រទានត្រូវបង្កើតដោយសេចក្តីសម្រេចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុកដោយមានការចូលរួមយោបល់ពីរតនាគារខេត្ត ហើយត្រូវបញ្ជូនមករតនាគារខេត្តវិញដើម្បីអនុវត្ត ដោយ

ភ្ជាប់មកជាមួយនូវតារាងឧបសម្ព័ន្ធ ដែលបានកំណត់ជុំនៃវជ្ជទេយ្យបុរេប្រទាន។ តារាងឧបសម្ព័ន្ធត្រូវបង្កើតឡើងដោយជ្រើសរើសយកមាតិកាចំណាយតាមអនុគណនី គណនី នៃជំពូក ៦០, ៦១, ៦២, ៦៥ ដែលជាចំណាយចាំបាច់សម្រាប់កិច្ចដំណើរការរដ្ឋបាល ដោយគិតក្នុងកំរិតមួយជាអតិបរិមាស្មើនឹង៣០ភាគរយ នៃឥណទានតាមជំពូកដែលជ្រើសរើសយកមកបង្កើតវជ្ជទេយ្យបុរេប្រទាន។ ចំពោះសមាមាត្រផ្ទៃក្នុងតារាង ពុំតម្រូវឱ្យគិតចំនួន៣០ភាគរយ ស្មើៗនោះទេគឺអាចតិច ឬច្រើនទៅតាមតម្រូវការចាំបាច់នៃការចំណាយ ប៉ុន្តែមិនឱ្យលើសពី៣០ភាគរយ នៃឥណទានសរុបដែលជ្រើសរើសយកមកបង្កើតវជ្ជទេយ្យបុរេប្រទាននោះឡើយ។

២.៤.២ ទឹកប្រាក់នៃជុំបង្វិលត្រូវគិត ១/៨ លើ៣០ភាគរយ នៃឥណទានដែលជ្រើសរើសយកមកបង្កើតវជ្ជទេយ្យបុរេប្រទាន។

២.៤.៣ អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវចេញសេចក្តីសម្រេចតែងតាំងមន្ត្រីក្នុងការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុរបស់សាលាក្រុង ស្រុក ជាវជ្ជទេយ្យករបុរេប្រទាននិងវជ្ជទេយ្យកររងបុរេប្រទានក្រុង ស្រុកដោយមានការចូលរួមយោបល់ពីរតនាគារខេត្ត។ វជ្ជទេយ្យករ និងវជ្ជទេយ្យកររងបុរេប្រទាន ត្រូវបើកគណនីនិងតម្កល់គំរូហត្ថលេខានៅរតនាគារខេត្ត។

វជ្ជទេយ្យករបុរេប្រទាននិងវជ្ជទេយ្យកររងបុរេប្រទានក្រុង ស្រុកមានការទទួលខុសត្រូវផ្ទាល់ខ្លួន និងជាប្រាក់កាស។

២.៤.៤ ដើម្បីទទួលបានប្រាក់វជ្ជទេយ្យបុរេប្រទានដើមដំបូង វជ្ជទេយ្យករបុរេប្រទានក្រុង ស្រុកត្រូវចុះហត្ថលេខាលើ ប័ណ្ណសុំដកប្រាក់ ហើយបញ្ជូន ទៅគណនេយ្យករក្រុង ស្រុកនៅរតនាគារខេត្ត ដោយពុំចាំបាច់មានភ្ជាប់ឯកសារអ្វីឡើយ។

២.៤.៥ វជ្ជទេយ្យបុរេប្រទានត្រូវរៀបចំតារាងតុល្យភាពគណនីវជ្ជទេយ្យបុរេប្រទានប្រចាំខែដើម្បីដាក់ជូន អាណាប័កចុះហត្ថលេខាហើយបញ្ជូនទៅរតនាគារខេត្ត។

២.៤.៦ ការចំណាយមួយប័ណ្ណៗចេញពីបេឡារបស់វជ្ជទេយ្យករបុរេប្រទានមិនត្រូវលើសពី ១.000.000 រៀល (មួយលានរៀលគត់)។

២.៤.៧ រាល់ការចំណាយមួយលើកៗ វជ្ជទេយ្យករបុរេប្រទានក្រុង ស្រុក ត្រូវរៀបចំសំណើសុំគោលការណ៍ចំណាយពីអាណាប័ក។

២.៤.៨ វជ្ជទេយ្យករបុរេប្រទានក្រុង ស្រុកត្រូវកត់ត្រារាល់ប្រតិបត្តិការចំណូល ចំណាយទៅក្នុងសៀវភៅបេឡាសាច់ប្រាក់តាមគំរូដែលផ្តល់ជូនដោយរតនាគារខេត្ត។

២.៤.៩ វជ្ជទេយ្យករបុរេប្រទានមានសិទ្ធិស្នើសុំបំពេញសាច់ប្រាក់វជ្ជទេយ្យបុរេប្រទាន នៅក្រោយពេលដែលរដ្ឋបាលក្រុង ស្រុក បានរៀបចំអាណត្តិបើកប្រាក់ដើម្បីទូទាត់ប្រាក់វជ្ជទេយ្យបុរេប្រទានលើកមុនដែលបានចំណាយរួច ដោយភ្ជាប់ជាមួយនូវឯកសារដូចខាងក្រោម ៖

- សំណើសុំទូទាត់
- សលាកប័ត្រកត់ត្រាចំណាយ និងត្រួតពិនិត្យថវិកា
- ដីកាអមបញ្ជូនអាណត្តិបើកប្រាក់
- ដីកាអមលិខិតយុត្តិការ
- គោលការណ៍ចំណាយដែលសម្រេចដោយអាណាប័ក
- របាយការណ៍ចំណាយរជ្ជទេយ្យបុរេប្រទានតាមខ្ទង់ចំណាយនីមួយៗ
- ប័ណ្ណចំណាយ
- វិក្កយបត្រដែលមានការបញ្ជាក់ទទួលស្គាល់ពីអាណាប័ក ។

២.៤.១០ អាណាប័កអាចបោះផ្សាយអាណត្តិបើកប្រាក់មានទឹកប្រាក់តូចជាង ឬស្មើនឹងទឹកប្រាក់ដែលបានដកពីរតនាគារខេត្ត។ អាណត្តិបើកប្រាក់ត្រូវបានបោះផ្សាយទៅតាមមាតិកាចំណាយដូចមានចែងនៅក្នុងតារាងឧបសម្ព័ន។ ប៉ុន្តែមិនអនុញ្ញាតអោយធ្វើការបោះផ្សាយអាណត្តិបើកប្រាក់ ស្មើនឹងទឹកប្រាក់មួយដុំសម្រាប់តែអនុគណនី ឬគណនីណាមួយឡើយ ។

២.៤.១១ មិនអនុញ្ញាតឱ្យរជ្ជទេយ្យករបុរេប្រទានយកប្រាក់មួយចំណែក ឬទាំងអស់ទៅផ្ញើទុកនៅធនាគារឯកជនឬធនាគាររដ្ឋណាមួយឡើយ។

២.៤.១២ រជ្ជទេយ្យករបុរេប្រទានទាំងអស់ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អាណាប័ក និងគណនេយ្យករមុខការ។ ទន្ទឹមនឹងនេះរជ្ជទេយ្យករត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ ផ្ទៀងផ្ទាត់នៅនឹងកន្លែងពីអគ្គាធិការដ្ឋានហិរញ្ញវត្ថុ និងពីអាជ្ញាធរត្រួតពិនិត្យដែលមានសមត្ថកិច្ច។ ការត្រួតពិនិត្យត្រូវប្រព្រឹត្តទៅដោយមិនប្រាប់ឱ្យដឹងជាមុន ។ អាណាប័ក និងគណនេយ្យករមុខការអាចចាត់តាំងភ្នាក់ងារនៅក្រោមឱវាទ ដើម្បីធ្វើការត្រួតពិនិត្យផ្ទាល់នៅនឹងកន្លែងឱ្យបានញឹកញាប់។ ការត្រួតពិនិត្យសាច់ប្រាក់ត្រូវធ្វើយ៉ាងតិចក្នុងមួយត្រីមាសម្តង។ រាល់ការត្រួតពិនិត្យមួយលើកៗ ត្រូវមានរបាយការណ៍ ឬកំណត់ហេតុត្រឹមត្រូវច្បាស់លាស់ដែលក្នុងនោះត្រូវកត់សំគាល់នូវកិច្ចការដែលបានពិនិត្យឃើញ។ របាយការណ៍ ឬកំណត់ហេតុទាំងនោះ ត្រូវផ្តល់ឱ្យរជ្ជទេយ្យករបុរេប្រទានពិនិត្យ និងឯកភាពហើយត្រូវផ្ញើត្រលប់ទៅភ្នាក់ងារត្រួតពិនិត្យ និងអាណាប័កវិញ។ មន្ត្រីត្រួតពិនិត្យ និងរជ្ជទេយ្យករបុរេប្រទានត្រូវចុះហត្ថលេខាលើតារាងរាប់សាច់ប្រាក់នៃបេឡារជ្ជទេយ្យបុរេប្រទាន។

២.៤.១៣ ដើម្បីទទួលបាននូវប្រាក់រជ្ជទេយ្យបុរេប្រទាន បុគ្គលិកដែលពាក់ព័ន្ធត្រូវដាក់សំណើសុំគោលការណ៍ចំណាយទៅអាណាប័កតាមរយៈប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុក្រុង ស្រុក ។

២.៤.១៤ ក្រោយពីមានគោលការណ៍ចំណាយ រជ្ជទេយ្យករបុរេប្រទានត្រូវធ្វើប័ណ្ណចំណាយ និងបើកផ្តល់ប្រាក់ជូនបុគ្គលិកដែលពាក់ព័ន្ធ ដោយតម្រូវឱ្យបុគ្គលិកនោះចុះហត្ថលេខាលើប័ណ្ណចំណាយដើម្បីបញ្ជាក់ពីការទទួលប្រាក់។

២.៤.១៥ រជ្ជទេយ្យករបុរេប្រទានត្រូវប្រមូលសក្ខីប័ត្រចំណាយ ដើម្បីធ្វើការទូទាត់ជម្រះប្រាក់រជ្ជទេយ្យបុរេប្រទាន ដោយដាក់ជូនទៅអាណាប័កដើម្បីពិនិត្យ និងបញ្ជាក់៖

- ក្នុងករណីដែលចំនួនទឹកប្រាក់ចំណាយជាក់ស្តែងមានចំនួន លើសពីប្រាក់ដែលបានបុរេប្រទាន រជ្ជទេយ្យករបុរេ ប្រទានត្រូវធ្វើប័ណ្ណចំណាយប្រាក់បន្ថែម ផ្ទុយមកវិញ ករណីដែលចំនួនទឹកប្រាក់ចំណាយជាក់ស្តែងមានចំនួន តិចជាងប្រាក់ដែលបានបុរេប្រទាន រជ្ជទេយ្យករបុរេប្រទានត្រូវធ្វើប័ណ្ណចំណូលប្រាក់ដែលនៅសល់។
- រាល់ប្រតិបត្តិការចំណូល ចំណាយប្រាក់រជ្ជទេយ្យបុរេប្រទានត្រូវកត់ត្រាក្នុងបញ្ជីបេឡា។
- **នៅដំណាច់ឆ្នាំថវិកា** រជ្ជទេយ្យករបុរេប្រទានត្រូវប្រមូលលិខិតយុត្តិការចំណាយ ផ្ញើជូនអាណាប័ក បោះផ្សាយអាណត្តិបើកប្រាក់ដើម្បីទូទាត់ ហើយសាច់ប្រាក់ដែលនៅសល់ត្រូវបង់ចូល បេឡារបស់រតនាគារខេត្ត ឬបង់ចូលគណនីចរន្តរបស់រតនាគារខេត្តនៅសាខាធនាគារយ៉ាងយូរបំផុតត្រឹមថ្ងៃទី ៣១ ខែធ្នូ។

## ២.៥.រជ្ជទេយ្យចំណូល

ជាគោលការណ៍ រាល់ចំណូលថវិការបស់ក្រុង ស្រុក ដែលប្រមូលបានត្រូវបង់ចូលភ្លាមទៅក្នុងគណនីប្រាក់បញ្ញើថវិការបស់រដ្ឋបាលក្រុង ស្រុក នៅរតនាគារខេត្ត ដោយឡែកចំណូលមិនមែនសារពើពន្ធដែលមានចំនួនតិច និងត្រូវប្រមូលជាប្រចាំ ត្រូវបានអនុញ្ញាតឱ្យប្រមូល និងរក្សាទុកតាមរយៈរជ្ជទេយ្យករចំណូលដើម្បីបង់ចូលទៅរតនាគារខេត្តទៅតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្នុងន័យនេះអភិបាលនៃគណៈអភិបាលក្រុង ស្រុកអាចចេញសេចក្តីសម្រេចតែងតាំងមន្ត្រីក្នុងការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុជារជ្ជទេយ្យករចំណូល និងរជ្ជទេយ្យករចំណូលរងក្នុងករណីចាំបាច់។ អភិបាលនៃគណៈអភិបាលក្រុង ស្រុកមានសិទ្ធិគ្រប់គ្រងនិងចាត់ចែងរជ្ជទេយ្យចំណូលតាមនីតិវិធីដូចខាងក្រោម៖

### ២.៥.១ ការបង្កើតរជ្ជទេយ្យចំណូល

ការបង្កើតរជ្ជទេយ្យចំណូលត្រូវធ្វើជារៀងរាល់ដើមឆ្នាំថវិកា។ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ត្រូវបញ្ជូនលិខិតស្នើសុំបង្កើតរជ្ជទេយ្យចំណូល ដោយភ្ជាប់មកជាមួយនូវសេចក្តីសម្រេចបង្កើតរជ្ជទេយ្យចំណូល និងតារាងឧបសម្ព័ន្ធដោយជ្រើសរើសយកមាតិកាចំណូលថវិកាតាមគណនី អនុគណនីដែលពាក់ព័ន្ធ លើកលែងតែចំណូលដែលត្រូវប្រមូលតាមកិច្ចសន្យា ហើយដាក់ជូនទៅរតនាគារខេត្តដើម្បីពិនិត្យនិងមានយោបល់ រួចប្រគល់ជូនអភិបាលនៃគណៈអភិបាលក្រុង ស្រុកវិញដើម្បីចុះហត្ថលេខា និងបញ្ជូនមករតនាគារខេត្តវិញដើម្បីអនុវត្ត។

### ២.៥.២ ការតែងតាំងរជ្ជទេយ្យករចំណូលៈ

អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវធ្វើសេចក្តីសម្រេចតែងតាំងរជ្ជទេយ្យករចំណូល និងរជ្ជទេយ្យករចំណូលរង ដោយជ្រើសរើសមន្ត្រីក្នុងការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុរបស់សាលាក្រុង ស្រុកដែលមាន

លក្ខណៈសម្បត្តិល្អ មានកំរិតយល់ដឹងលើកិច្ចការគណនេយ្យ ហើយបញ្ជូនទៅរតនាគារខេត្តដើម្បីអនុវត្ត។ រដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរងត្រូវបើកគណនី និងតំកល់គំរូហត្ថលេខានៅរតនាគារខេត្ត។

**២.៥.៣ ការប្រមូលចំណូល**

រដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរង ត្រូវប្រមូលចំណូលជាសាច់ប្រាក់ ឬជាមូលប្បទានប័ត្រ ដោយផ្អែកលើតារាងតំលៃដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**២.៥.៤ រដ្ឋទេយ្យករចំណូល ឬរដ្ឋទេយ្យករចំណូលរង**

រដ្ឋទេយ្យករចំណូល ឬរដ្ឋទេយ្យករចំណូលរងអាចរក្សាទុកសាច់ប្រាក់ក្នុងបេឡារបស់ខ្លួនមិន លើសពី ២.០០០.០០០ (ពីរលានរៀលគត់) និងហាមយកសាច់ប្រាក់ចំណូលដែលទទួលបានយកមកចំណាយ។ ក្នុងករណីលើសពីចំនួននេះ រដ្ឋទេយ្យករចំណូល ឬរដ្ឋទេយ្យករចំណូលរងត្រូវយកសាច់ប្រាក់ដែលប្រមូលបានទាំងអស់បង់ចូលរតនាគារខេត្ត ឬសាខាធនាគារ ។

- រៀងរាល់ថ្ងៃទី២៥ ខែមករា ដល់ខែវិច្ឆិកា និងថ្ងៃទី៣១ ខែធ្នូ រដ្ឋទេយ្យករត្រូវធ្វើសលាកប័ត្រចំណូលទៅតាមមាតិកាថវិកានូវចំនួនទឹកប្រាក់ចំណូលដែលប្រមូលបានរយៈពេលមួយខែ គឺគិតពីថ្ងៃទី២៦ ខែមុនដល់ថ្ងៃទី ២៥ ខែនេះ ចំនួនបីច្បាប់ជូនទៅអាណាប័ក
- អាណាប័កត្រូវចុះហត្ថលេខាលើសលាកប័ត្រចំណូល ក្រោយពីពិនិត្យឃើញថាកិច្ចបញ្ជិកាថវិកាត្រឹមត្រូវរួចហើយបញ្ជូនទៅគណនេយ្យមុខការ
- គណនេយ្យករមុខការក្រោយពីពិនិត្យឃើញថាត្រឹមត្រូវរួចហើយ ត្រូវចុះហត្ថលេខាលើសលាកប័ត្រចំណូល និងបញ្ជូនមករដ្ឋទេយ្យករចំណូលវិញ

**២.៥.៥ ការទទួលខុសត្រូវរបស់រដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរង**

រដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរងរបស់រដ្ឋបាលក្រុង ស្រុកមានការទទួលខុសត្រូវ៖

- ផ្នែករដ្ឋបាល
- ផ្នែកព្រហ្មទណ្ឌ
- ដោយផ្ទាល់ចំពោះប្រាក់កាស និងមូលនិធិទាំងឡាយ។

**២.៥.៦ កិច្ចបញ្ជិកាគណនេយ្យនៃរដ្ឋទេយ្យករចំណូល**

ជាគោលការណ៍ទូទៅ រដ្ឋទេយ្យករចំណូល ត្រូវកាន់កាប់បញ្ជីទ្វេភាគរួមមាន៖

- បញ្ជីបេឡា
- ទិន្នានុប្បវត្តិ-សៀវភៅធំ
- តារាងតុល្យភាពគណនី

**២.៥.៧ ការរៀបចំនិងកិច្ចដំណើរការគណនីរបស់រជ្ជទេយ្យករចំណូល**

គណនីដែលប្រើប្រាស់ដោយ រជ្ជទេយ្យករចំណូលរួមមាន៖

- គណនីប្រាក់បញ្ញើមូលនិធិរជ្ជទេយ្យចំណូលនៅរតនាគារ (លេខ៤៦)
- គណនីចំណូលបណ្តោះអាសន្ន (លេខ ៤៧)
- គណនីមូលប្បទានប័ត្រធ្វើបេឡានិច្ច័យ (លេខ ៥១)
- គណនីបេឡា (លេខ ៥៣)

**២.៥.៨ ការត្រួតពិនិត្យរជ្ជទេយ្យចំណូល**

រជ្ជទេយ្យករចំណូលត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យនៃ អាណាប័ក គណនេយ្យករមុខការ អាគារធិការដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ អាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត។ ការត្រួតពិនិត្យអាចធ្វើនៅនឹងកន្លែង និងទៅលើឯកសារ។

**២.៥.៩ ការកំណត់រយៈពេលនៃការត្រួតពិនិត្យ**

ជាគោលការណ៍ទូទៅ ការត្រួតពិនិត្យដោយអាណាប័ក ឬអ្នកតំណាងត្រូវធ្វើឱ្យបានញឹកញាប់បំផុត និងការត្រួតពិនិត្យរបស់គណនេយ្យករមុខការត្រូវធ្វើយ៉ាងហោចណាស់មួយឆ្នាំម្តង

**២.៥.១០ ឯកសារដែលត្រូវបង្កើតឡើង**

ការផ្ទៀងផ្ទាត់ត្រូវមានរបាយការណ៍ ឬកំណត់ហេតុដែលធ្វើឡើងដោយអ្នកផ្ទៀងផ្ទាត់ ឯកសារត្រូវបានប្រគល់ទៅឱ្យរជ្ជទេយ្យករធ្វើការកត់សំគាល់ និងផ្តល់ចំម្លើយរួចផ្ញើរត្រឡប់ទៅភ្នាក់ងារផ្ទៀងផ្ទាត់វិញ។

## ៣. ប្រព័ន្ធគណនេយ្យរបស់រដ្ឋបាលក្រុង ស្រុក

រដ្ឋបាលក្រុង ស្រុកត្រូវមានកាតព្វកិច្ចតាមដាន ផ្ទៀងផ្ទាត់ បូកសរុប និងវិភាគដែលមានលក្ខណៈជាប្រព័ន្ធទៅលើ ប្រតិបត្តិការថវិកា និងហិរញ្ញវត្ថុ និងរៀបចំរបាយការណ៍តាមការកំណត់ប្រកបដោយភាពត្រឹមត្រូវ និងសង្គតិភាពដោយ អនុវត្តតាមរយៈប្រព័ន្ធគណនេយ្យរបស់រដ្ឋបាលក្រុង ស្រុក។

ប្រព័ន្ធគណនេយ្យរបស់រដ្ឋបាលក្រុង ស្រុក មានយន្តការពីរដូចខាងក្រោម៖

- គណនេយ្យថវិកា ៖ តាមដាន និងធ្វើរបាយការណ៍អំពីការអនុវត្តថវិការបស់រដ្ឋបាលក្រុង ស្រុកនិង
- គណនេយ្យហិរញ្ញវត្ថុ ៖ ចុះបញ្ជី និងធ្វើរបាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ។

### ៣.១ គណនេយ្យថវិកា

រដ្ឋបាលក្រុង ស្រុកត្រូវអនុវត្តគណនេយ្យថវិកា ក្នុងការតាមដាន និងរាយការណ៍អំពីការអនុវត្តថវិកា ដើម្បីធានាថា ការចំណាយត្រូវបានធ្វើឡើងនៅកម្រិតឥណទានថវិកាដែលបានអនុញ្ញាត និងចំណូលត្រូវមាន

សង្គតិភាពជាមួយនឹងថវិកាដែលគ្រោង។ ប្រព័ន្ធគណនេយ្យថវិកាត្រូវដំណើការដូចខាងក្រោម ៖

៣.១.១ អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវទទួលខុសត្រូវតាមដានការអនុវត្តគណនេយ្យថវិកា

៣.១.២ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ត្រូវរៀបចំសលាកប័ត្រតាមដានការប្រើប្រាស់ឥណទាន ដោយផ្អែកតាមថវិកាដែលបានអនុម័ត ត្រូវរៀបចំសលាកប័ត្រតាមដានការប្រើប្រាស់ឥណទាន និង សលាកប័ត្រតាមដានចំណូលសម្រាប់ខ្ទង់គណនីថវិកានីមួយៗ។

**៣.១.២.១ សលាកប័ត្រតាមដានការប្រើប្រាស់ឥណទាន**

សលាកប័ត្រតាមដានការប្រើប្រាស់ឥណទានថវិកាប្រើសម្រាប់៖

- ស្រង់ចំនួនទឹកប្រាក់ដែលបានចំណាយ ទៅក្នុងសលាកប័ត្រតាមដានការប្រើប្រាស់ឥណទាន ជាប្រចាំបន្ទាប់ពីការសន្យាចំណាយ ឬចេញអាណត្តិបើកប្រាក់ (សាលាកប័ត្រតាមដានការប្រើប្រាស់ឥណទានសម្រាប់ការសន្យាចំណាយ និងការទូទាត់)។
- បន្ទាប់ពីស្រង់ការសន្យាចំណាយ ឬការទូទាត់នីមួយៗដាក់ទៅក្នុងសលាកប័ត្រតាមដានការប្រើប្រាស់ឥណទាន ត្រូវគណនាឥណទានថវិកាដែលមិនទាន់បានប្រើប្រាស់។

សលាកប័ត្រតាមដានការប្រើប្រាស់ឥណទាន ត្រូវបង្ហាញអំពីព័ត៌មានតាមខ្ទង់ថវិកានីមួយៗដូចខាងក្រោម៖

- ឥណទានអនុម័ត
- ថវិកាបូកយោងដែលបានសន្យាចំណាយ និង ឬចំណាយដែលបានជម្រះបញ្ជីរួចហើយ (សម្រាប់អាណត្តិបើកប្រាក់ដែលបានផ្ញើទៅគណនេយ្យករក្រុង ស្រុកនៅរតនាគារខេត្ត) និង
- ឥណទាននៅសល់។

**៣.១.២.២ សលាកប័ត្រតាមដានចំណូល**

សលាកប័ត្រតាមដានចំណូលប្រើសម្រាប់៖

- ស្រង់ចំណូលជាក់ស្តែងទៅក្នុងសលាកប័ត្រតាមដានចំណូល នៅពេលដែលចំណូលទាំងនោះត្រូវបានប្រមូលដោយរដ្ឋបាលក្រុង ស្រុក (ចំណូលផ្ទាល់) ឬទទួលបានពីការផ្ទេរពីថ្នាក់ជាតិ និងពីប្រភពផ្សេងៗទៀត។
- បន្ទាប់ពីការស្រង់ចំណូលដែលទទួលបានទៅក្នុងសលាកប័ត្រតាមដានចំណូល ត្រូវគណនាចំណូលនៅសល់ដែលនឹងត្រូវបន្តប្រមូល ឬនឹងត្រូវទទួល ។

សលាកប័ត្រតាមដានចំណូលត្រូវបង្ហាញអំពីព័ត៌មាននៃចំណូលតាមខ្ទង់ថវិកានីមួយៗដូចខាងក្រោម ៖

- ចំណូលដែលបានគ្រោង
- ចំណូលដែលប្រមូលបាន ឬ ទទួលបានជាក់ស្តែង

- ចំណូលដែលនឹងត្រូវបន្តប្រមូល ឬនឹងត្រូវទទួល ។

៣.១.២.៣ នៅដំណាច់ខែ អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវធានាថាព័ត៌មានដែលបានបង្ហាញក្នុងសលាកប័ត្រតាមដានចំណូល និង សលាកប័ត្រតាមដានការប្រើប្រាស់ឥណទាន ត្រូវបានផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវជាមួយនឹងរបាយការណ៍ ស្តីពីការអនុវត្តថវិកាប្រចាំខែដែលរៀបចំដោយគណនេយ្យករក្រុង ស្រុក ។

### ៣.២ គណនេយ្យហិរញ្ញវត្ថុ

គណនេយ្យហិរញ្ញវត្ថុត្រូវអនុលោមទៅតាមគោលការណ៍ដូចខាងក្រោម៖

៣.២.១ កិច្ចបញ្ជិកាគណនេយ្យផ្អែកលើមូលដ្ឋានគណនេយ្យបង្គរដែលត្រូវអនុវត្តជាជំហានៗ ។

៣.២.២ ប្រតិបត្តិការគណនេយ្យត្រូវកត់ត្រាតាមគោលការណ៍ទ្វេភាគដែល ៖

- ប្រតិបត្តិការនីមួយៗត្រូវឆ្លុះបញ្ចាំងយ៉ាងតិចក្នុងគណនីពីរផ្សេងគ្នា និង
- ចំនួនទឹកប្រាក់ដែលបានកត់ត្រានៅខាងផ្នែកឥណពន្ធ ត្រូវស្មើនឹងចំនួនទឹកប្រាក់ដែលបានកត់ត្រានៅខាងផ្នែកឥណទានសម្រាប់ប្រតិបត្តិការនីមួយៗ ។

៣.២.៣ មាតិកាគណនីត្រូវអនុលោមតាមប្លង់គណនេយ្យសាធារណៈ និងចំណាត់ថ្នាក់នៃមាតិកាថវិកាដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

៣.២.៤ នៅរាល់ដំណាច់ឆ្នាំ គណនីចំណូលចរន្ត គណនីចំណាយចរន្ត និងគណនីដទៃទៀត ត្រូវបិទដើម្បីរៀបចំរបាយការណ៍ ។ គណនីចំណូលចរន្ត និងគណនីចំណាយចរន្តត្រូវមានសមតុល្យស្មើនឹងសូន្យ និងបើកឡើងវិញនៅដើមឆ្នាំបន្ទាប់ រីឯគណនីដទៃទៀតទោះបីជាមានសមតុល្យ ឬមានសមតុល្យស្មើនឹងសូន្យ ក៏ត្រូវបើកឡើងវិញដែរ ។ សមតុល្យត្រូវយោងទៅឆ្នាំបន្ទាប់ចំពោះគណនីដែលមានសមតុល្យ ។

## ៤. របាយការណ៍ថវិកា ហិរញ្ញវត្ថុ របស់រដ្ឋបាលក្រុង ស្រុក

របាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ប្រើដើម្បីធ្វើជាមូលដ្ឋានសម្រាប់៖

- អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រួតពិនិត្យលើការអនុវត្តថវិកា ដោយប្រៀបធៀប ទៅនឹងថវិកាអនុម័ត
- វាយតម្លៃអំពីស្ថានភាពហិរញ្ញវត្ថុក្រុង ស្រុក ដោយផ្តល់ព័ត៌មានអំពីកម្រិតនិងប្រភពធនធាន និងរបៀបប្រើប្រាស់ឱ្យសម្រេចបាននូវគោលបំណងរបស់ក្រុង ស្រុក
- ក្រុមប្រឹក្សាក្រុង ស្រុកវាយតម្លៃលើការបំពេញការងាររបស់គណៈអភិបាលក្រុង ស្រុក និង
- ធ្វើសវនកម្មលើប្រតិបត្តិការគណនេយ្យ និងការអនុវត្តថវិការបស់រដ្ឋបាលក្រុង ស្រុក ។

### ក. របាយការណ៍ថវិកា

អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវរៀបចំឯកសារមួយចំនួនខាងក្រោម ៖

- របាយការណ៍អនុវត្តចំណូល ចំណាយថវិកាប្រចាំខែ និងប្រចាំឆ្នាំសម្រាប់ផ្ទៀងផ្ទាត់ជាមួយគណនេយ្យករមុខការ
- របាយការណ៍ស្តីពីទ្រព្យសម្បត្តិ
- របាយការណ៍លម្អិតស្តីពីសកម្មភាពប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ដែលត្រូវពិពណ៌នា និងវាយតម្លៃអំពីការបំពេញការងារ ការផ្តល់សេវាសាធារណៈ ដោយប្រៀបធៀបជាមួយនឹងទិសដៅនៃផែនការល័ក្ខខ័ណ្ឌសង្គម សេដ្ឋកិច្ចក្នុងមូលដ្ឋាន និងផលប៉ះពាល់លើសុខមាលភាពរបស់ប្រជាពលរដ្ឋពីប្រតិបត្តិការរបស់រដ្ឋបាលក្រុង ស្រុក ។
- របាយការណ៍ផ្សេងៗទៀតដែលជាតម្រូវការរបស់ក្រុមប្រឹក្សាក្រុង ស្រុក ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ខ.របាយការណ៍ហិរញ្ញវត្ថុ**

គណនេយ្យករក្រុង ស្រុក ត្រូវរៀបចំរបាយការណ៍ដូចខាងក្រោម ៖

- របាយការណ៍ស្តីពីចំណូល និងចំណាយតាមកាលកំណត់ប្រចាំខែ ឆ្នាំ
- តារាងតុល្យភាពគណនីប្រចាំខែ ឆ្នាំ
- តារាងតុល្យការប្រចាំឆ្នាំ
- របាយការណ៍លទ្ធផលនៃការអនុវត្តថវិកាប្រចាំឆ្នាំ
- តារាងផ្ទៀងផ្ទាត់គណនីប្រាក់បញ្ញើថវិការបស់ក្រុង ស្រុកនៅរតនាគារ និង
- តារាងឧបសម្ព័ន្ធទៅតាមតម្រូវការចាំបាច់ ។

៤.១ គណនេយ្យករក្រុង ស្រុកត្រូវផ្ញើរបាយការណ៍ខាងលើជូនទៅអភិបាលក្រុង ស្រុកដើម្បីធ្វើការផ្ទៀងផ្ទាត់ជាមួយតារាងតាមដានថវិកា និងបញ្ជាក់ទទួលស្គាល់ ។

៤.២ អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវពិនិត្យ និងដាក់របាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំជូនកិច្ចប្រជុំគណៈអភិបាលទៅតាមប្រតិទិនដូចខាងក្រោម ៖

- របាយការណ៍ចំណូល ចំណាយប្រចាំខែយ៉ាងយូរត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់
- របាយការណ៍ចំណូល ចំណាយប្រចាំឆ្នាំនិងរបាយការណ៍លម្អិតស្តីពីការអនុវត្តផែនការសកម្មភាព ប្រចាំឆ្នាំយ៉ាងយូរត្រឹថ្ងៃទី៣១ ខែមករា នៃឆ្នាំបន្ទាប់

៤.៣ អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវដាក់របាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំ ជូនអង្គប្រជុំក្រុមប្រឹក្សាក្រុង ស្រុកពិភាក្សា និងអនុម័តតាមប្រតិទិនដូចខាងក្រោម ៖

- របាយការណ៍ចំណូល ចំណាយប្រចាំខែយ៉ាងយូរត្រឹមថ្ងៃទី២០ នៃខែបន្ទាប់
- របាយការណ៍ចំណូលចំណាយប្រចាំឆ្នាំនិងរបាយការណ៍លម្អិតស្តីពីការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំយ៉ាងយូរត្រឹមថ្ងៃទី២៨ ខែកុម្ភៈ នៃឆ្នាំបន្ទាប់ ។

- ក្រោយពីក្រុមប្រឹក្សាក្រុង ស្រុកបានពិភាក្សា អនុម័តរួច យ៉ាងយូរមួយសប្តាហ៍ អភិបាលនៃគណៈអភិបាលក្រុង ស្រុកត្រូវធ្វើរបាយការណ៍ចំណូល ចំណាយប្រចាំខែ ប្រចាំឆ្នាំ និងរបាយការណ៍លម្អិតស្តីពីការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ ជូនសាលាខេត្ត មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត រតនាគារខេត្ត និងធ្វើការផ្សព្វផ្សាយជាសាធារណៈ។

អភិបាលនៃគណៈអភិបាលខេត្ត អភិបាលនៃគណៈអភិបាលក្រុង ស្រុក ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ប្រធានរតនគារខេត្ត ត្រូវអនុវត្ត សារាចរណែនាំនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ÷**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- សាលាខេត្ត

«ដើម្បីជូនជ្រាប»

- សាលាក្រុង ស្រុក
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត
- រតនាគារខេត្ត

«ដើម្បីអនុវត្ត»

- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៤៨៦ ឧរថ.ភ.ន.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០១៣

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញលិខិតលេខ១០៣ /១៣ គ.វ.ក ចុះថ្ងៃទី១១.០១.២០១៣ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ស៊ូ អ៉ីភែរ៉ឺល (ខេមបូឌា) ចុះថ្ងៃទី១៧.១២.២០១២

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុនស៊ូ អ៉ីភែរ៉ឺល (ខេមបូឌា) ( SOO APPAREL (CAMBODIA) CO., LTD.) តំណាងដោយ លោក CHUNG CHONG SIK សញ្ជាតិកូរ៉េ អាយុ៥៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ M45491593 ចុះថ្ងៃទី០២.០២.២០១០ មានអាសយដ្ឋានបច្ចុប្បន្ន៖ 606 -303 Hyndol-Maul, 1191 Backsuk-dong, Ilsan-donggu, Goyang-si, Kyunggi-do, Korea. ឲ្យធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

- **ផ្លាកឈ្មោះរោងចក្រ ៖** *" រោងចក្រកាត់ដេរសម្លៀកបំពាក់ ស៊ូ អ៊ីកែរីល (ខេមបូឌា) "*
- **ទីតាំងរោងចក្រ ៖** *" ភូមិត្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗបានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ស៊ុយ សែម**

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤,,"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**
**Ministry of Industry, Mines and Energy**
លេខ : ៤៨៧ ឧរថ.ក‌ឧ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញលិខិតលេខ២៥០៧/១២ គ.វ.ក ចុះថ្ងៃទី១៨.១២.២០១២ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ណានុកស៍ (ខេមបូឌា) អ៊ីន ចុះថ្ងៃទី០៧.១២.២០១២

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ណានុកស៍ (ខេមបូឌា) អ៊ីន (NANUX (CAMBODIA) INC.) តំណាងដោយ លោក JOONHWAN, KIM សញ្ជាតិកូរ៉េ អាយុ៥៦ឆ្នាំ កាន់លិខិតឆ្លងដែនលេខ M67863412 ចុះថ្ងៃទី០៣.០៨.២០០៩ មានអាសយដ្ឋានបច្ចុប្បន្ន ៖ 125-17, Baek Rok-Ro, Habuk-Myeon, Yangsan-Si, Gyeongsangnam-Do, Korea ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ស្បែកជើង | ១៥២០ |
| ថង់ប្លាស្ទិក | ២២២០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone: 855-23-211141, Fax: 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** *" រោងចក្រ ផលិតស្បែកជើង និងថង់ប្លាស្ទិក ណានុកស៍ (ខេមបូឌា) អ៊ីន "*

**ទីតាំងរោងចក្រ ៖** *" ផ្លូវជាតិលេខ៣ ភូមិព្រៃស្តេច ឃុំវាល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ សែម

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តកំពង់ស្ពឺ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បី អនុវត្ត"
-ឯកសារ-កាលប្បវត្តិ